00438479

D97/14/5

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ៣៥)
ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី
ដាក់ជូន: អង្គបុរេជំនុំជម្រះ
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ មទួល (Date of receipt/date de reception): 22 / 01 / 2010
ម៉ោង (Time/Heure) : 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public CR
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

<u>ផ្ញើជូន</u>៖

**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន៉ី ថុល
ចៅក្រម ហ្វូត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 28 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

អនុលោមទៅតាមវិធាន ៧៤(៣)(ក), ៥៥(១០), ៧៤(៣)(ខ) និង ២១ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") លោក **អៀងសារី** តាមរយៈមេធាវីការពារក្តីរបស់ខ្លួន សូមដាក់បណ្តឹងឧទ្ធរណ៍នេះ[1] ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស អំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម ("ដីកាសម្រេចJCE")[2]។

## I. សេចក្តីសង្ខេបដីកាសម្រេចJCE

១. បន្ទាប់ពីក.ស.ច.សបានទទួលស្គាល់ថា ការទទួលខុសត្រូវនៃសហកម្មឧក្រិដ្ឋកម្មរួម ("JCE") *មិនមែន*ជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានអត្ថិភាពនៅក្នុងប្រទេសកម្ពុជានោះ[3] ក.ស.ច.ស បានសន្និដ្ឋានដូចខាងក្រោមនេះ៖

ក. JCE គឺជាទម្រង់មួយនៃ "ការប្រព្រឹត្តិបទល្មើស" ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុង*រឿងក្តី Tadic* ហើយ JCE មានចំនួនបីប្រភេទ។ ប្រភេទនីមួយៗមាន*អំពើជាសម្ភារៈ ឬធាតុផ្សំសត្យានុម័ត (actus reus)* ដូចគ្នា ប៉ុន្តែអ្វីដែលធ្វើឱ្យទម្រង់JCE មួយខុសពីទម្រង់មួយទៀតនោះ គឺនៅត្រង់*ចេតនាប្រព្រឹត្តបទល្មើស ឬធាតុផ្សំអត្តនោម័ត* (*mens rea*) របស់JCE។ ទម្រង់ នៃJCE II គឺជាការវិវត្តចេញជាចំបងពីទម្រង់នៃJCE I[4]។

ខ. ដើម្បីអាចឱ្យការទទួលខុសត្រូវ JCE ត្រូវបានគេប្រើប្រាស់បាននៅក្នុងដំណើរការនីតិវិធីតុលាការគោលការណ៍នីត្យានុកូលភាពតម្រូវឱ្យមានការវាយតម្លៃ ថាតើ ការទទួលខុសត្រូវ JCE នោះគឺជាច្បាប់ជាធរមាន ដែរឬទេ នៅពេលមានអង្គហេតុចោទប្រកាន់ ដែលឋិតក្រោមការ

---

[1] ដោយសារតែបញ្ហាផ្សេងៗ អង្គបុរេជំនុំជម្រះក្តី ត្រូវបានបង្ហាញព័ត៌មានដោយមេធាវីការពារក្តី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដែលមិនមែនជាភាគីនៃរឿងក្តី នៅក្នុងសំណុំរឿង០០១។ មេធាវីការពារក្តីបានផ្តល់នូវឧបសម្ព័ន្ធ ក ដែលលើកឡើងអំពីទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលត្រូវបានលើកឡើងពីមុនពាក់ព័ន្ធនឹងការអនុវត្តJCEនៅអ.វ.ត.ក។ ឧបសម្ព័ន្ធ ខ ចែងអំពីគោលបំណងពិស្តារអំពីសេចក្តីសង្ខេបច្បាប់ស្តីពីJCE ដោយសារតែJCE កើតមាននៅតុលាការ*ពិសេស*។

[2] *រឿងក្តី អៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចស្តីពីការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជា សហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩, D97/13, ERN: 00411047-00411056។

[3] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២២។

[4] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ១៣-១៧។

ស៊ើបអង្កេត។ ការពិចារណាសំខាន់ចំនួនពីរគឺថា ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវតែអាចមើលឃើញជាមុន និងថាច្បាប់ដែលចែងអំពីការទទួលខុសត្រូវនេះ ត្រូវតែអាចរកបាន។ ការវាយតម្លៃអំពីភាពដែលអាចមើលឃើញជាមុន និងភាពដែលអាចរកបាន អាចធ្វើទៅបាន នៅពេលដែលអំពើដែលចោទប្រកាន់នោះ ត្រូវបានផ្តន្ទាទោស នៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៃពេលវេលាជាក់លាក់ណាមួយ[5]។

គ. ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅអ.វ.ត.ក គឺជាការសន្និដ្ឋានដែលទាញចេញអំពីហេតុដែលថា អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ ដែលអនុវត្តច្បាប់អន្តរជាតិ។ ដោយយោងទៅលើចរិតលក្ខណៈអន្តរជាតិរបស់ អ.វ.ត.ក និងដោយបានពិចារណាឃើញថា យុត្តិសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃអំពីការទទួលខុសត្រូវ JCE ត្រូវបានតាក់តែងឡើង មុនពេលនៃអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបសួរនៅអ.វ.ត.ក ដូច្នេះ វាមានមូលដ្ឋាននៅក្នុងច្បាប់អន្តរជាតិ សម្រាប់អនុវត្តទម្រង់នៃការទទួលខុសត្រូវនេះ[6]។

ឃ. វាមិនអាចអះអាងបានទេថា ទម្រង់នៃការទទួលខុសត្រូវអន្តរជាតិដូចជា JCE អាចអនុវត្តហួសពីក្របខណ្ឌនៃបទល្មើសអន្តរជាតិនោះទេ។ ដោយក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ យកគំរូតាមច្បាប់បារាំង បទល្មើសអន្តរជាតិដូចជាបទល្មើសដែលឋិតក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក គឺជាបទល្មើសដែលជាប្រភេទពិសេសឋិតនៅក្នុង "របបគតិយុត្ត" ពិសេសដាច់ដោយឡែកមួយ ផ្សេងពីច្បាប់ព្រហ្មទណ្ឌជាតិ។ អនុលោមតាមគោលការណ៍នៃការបកស្រាយលើ"របបគតិយុត្តិ"ពិសេស ទម្រង់នៃការទទួលខុសត្រូវ នៃបទល្មើសអន្តរជាតិអាចត្រូវបានអនុវត្តចំពោះតែបទល្មើសអន្តរជាតិតែប៉ុណ្ណោះ[7]។

ង. ធាតុផ្សំនៃការទទួលខុសត្រូវ JCE មានលក្ខណៈអាចព្យាករណ៍ជាមុន និងអាចរកបាននៅក្រោមច្បាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ នៅក្នុងប្រទេសកម្ពុជា។ គោលការណ៍នីត្យានុកូលភាពមិនត្រូវបានរំលោភបំពានដោយការអនុវត្តការទទួលខុសត្រូវJCE ចំពោះមុខអ.វ.ត.កទេ។ ចំណុចនៃការទទួលខុសត្រូវJCE ត្រូវបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ការទទួលខុសត្រូវJCE អាចអនុវត្តចំពោះទម្រង់ទាំងបី ទោះបីជាJCE មិន

---

5 *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ១៨-២០។

6 *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២១។

7 *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២២។

00438482



អាចអនុវត្តបានចំពោះបទល្មើសជាតិក៏ដោយ។ *ចេតនាប្រព្រឹត្តបទល្មើស ឬធាតុផ្សំអត្តនោម័ត* (*mens rea*) នៃJCE III គឺកម្រិតត្រឹមតែការទទួលយកជាអត្តនោម័តនៃផលវិបាកជាលក្ខណៈធម្មជាតិ និងអាចព្យាករណ៍បាននៃការអនុវត្តផែនការរួមតែប៉ុណ្ណោះ[8]។

## II. ការសង្ខេបទឡ្ហីករណ៍

២. បណ្តឹងឧទ្ធរណ៍នេះ នឹងបង្ហាញថា ក.ស.ច.សបានភ័ន្តច្រឡំដូចខាងក្រោម នៅពេលក.ស.ច.ស សម្រេចថា ការទទួលខុសត្រូវJCE អាចអនុវត្តបានចំពោះមុខអ.វ.ត.ក៖

ក. ក.ស.ច.ស បានភ័ន្តច្រឡំដែលយល់ឃើញថា អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ។ អ.វ.ត.ក ជាតុលាការកម្ពុជាថ្នាក់ជាតិ។

ខ. ក.ស.ច.ស បានភ័ន្តច្រឡំនៅពេលបានសន្និដ្ឋានថា អ.វ.ត.ក អាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ អ.វ.ត.ក ក្នុងឋានៈជាតុលាការជាតិកម្ពុជា មិនអាចអនុវត្តដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ វាគ្មានការលើកលែងនៅក្នុងប្រទេសកម្ពុជា ដោយផ្អែកលើទ្រឹស្តីនៃបទល្មើសអន្តរជាតិ ដែលត្រូវគោរពទៅតាម"របបគតិយុត្តិ"ពិសេសឡើយ។

គ. ក.ស.ច.ស ខកខានមិនបានធ្វើការវិភាគដោយឯករាជ្យថាតើការទទួលខុសត្រូវJCE ពិតជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥-៧៩នោះទេ។ ទោះបីជាអ.វ.ត.ក អាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏ការទទួលខុសត្រូវJCE មិនមែនជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥-៧៩ទេ។

ឃ. ក.ស.ច.ស បានភ័ន្តច្រឡំក្នុងការព្រមទទួលថា ការទទួលខុសត្រូវJCE ដែលបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូល*Tadić* អាចស្ថិតនៅក្រោមបទប្បញ្ញត្តិ "ការប្រព្រឹត្តិបទល្មើស" ដែលមានចែងនៅក្នុងមាត្រា២៩ នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។ និង

ង. ក.ស.ច.ស បានភ័ន្តច្រឡំនៅក្នុងការសម្រេចថា ការអនុវត្តការទទួលខុសត្រូវJCE មិនបានរំលោភបំពានគោលការណ៍នីត្យានុកូលភាពនោះទេ។ ទោះបីជាអ.វ.ត.ក អាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ *និងទោះបីជា* ការទទួលខុសត្រូវJCE ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥-៧៩ក៏ដោយ ក៏គោលការណ៍នីត្យានុកូលភាពនៅតែមិនអនុញ្ញាតឲ្យ

---

[8] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២៣។

អនុវត្តទម្រង់នៃការទទួលខុសត្រូវនេះនៅចំពោះមុខអ.វ.ត.ក ទេ។

## III. បញ្ហាបឋម

### ក. ការទទួលយកបានបណ្តឹងឧទ្ធរណ៍

៣. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានក្រោមវិធាន៧៤(៣)(ក) ឬវិធាន៥៥(១០) និងវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។ វិធាន ៧៤(៣)(ក) ចែងថា ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដោយបញ្ជាក់ឡើងវិញអំពីយុត្តាធិការរបស់ អ.វ.ត.ក។ នៅក្នុងដីកាសម្រេចJCE ក.ស.ច.សបានប្រកាសថា អ.វ.ត.កមានយុត្តាធិការអនុវត្ត JCE ជាទម្រង់នៃការទទួលខុសត្រូវចំពោះបទល្មើសអន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវJCE មិនអាចរកឃើញនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះទេ[9] ដែលអនុលោមតាមកិច្ចព្រមព្រៀង ច្បាប់នេះចែងអំពីយុត្តាធិការរបស់អ.វ.ត.ក[10]។

៤. វិធាន៥៥ (១០) និងវិធាន៧៤(៣)(ខ) ចែងថា ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធពាក្យសុំឱ្យបំពេញកិច្ចស៊ើបសួរ។ ដីកាសម្រេចJCEចែងថា ពាក្យសុំរបស់លោក **អៀង សារី** ប្រឆាំងនឹងការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានស្គាល់ថាជាសហកម្មឧក្រិដ្ឋកម្មរួម[11] ត្រូវបានពិចារណាយ៉ាងត្រឹមត្រូវថាជា សំណើសុំបំពេញកិច្ចស៊ើបសួរក្រោមវិធាន៥៥(១០)[12]។

៥. ទោះបីជាបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ក្រោមវិធានដែលបានលើកឡើងខាងលើ ក៏

---

[9] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២១-២២ និងសេចក្តីសន្និដ្ឋាន។

[10] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[11] *រឿងក្តី អៀង សារី,* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅអ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថាសហកម្មឧក្រិដ្ឋកម្មរួម, ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨, D97។

[12] ដីកាសម្រេចJCE កថាខណ្ឌ៨ "សំណើសុំរបស់ អៀង សារី ត្រូវបានធ្វើឡើងដោយមានការភាន់ច្រឡំក្រោមវិធាន៥៣(១)នៃវិធានផ្ទៃក្នុង ...។ ទោះបីជាយ៉ាងក៏ដោយ សហចៅក្រមស៊ើបអង្កេត សម្រេចដោយ*តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់* ធ្វើការពិចារណាសំណើសុំនេះ ដោយយោងទៅលើវិធានផ្ទៃក្នុងដែលត្រឹមត្រូវ គឺវិធាន ៥៥(១០)"។

បណ្តឹងឧទ្ធរណ៍នេះនៅតែអាចទទួលយកបានអនុលោមតាមវិធាន២១ ដែលវិធាននេះតម្រូវថា ការជំនុំជម្រះត្រូវតែមានយុត្តិធម៌ និងចែងថា គ្រប់បុគ្គលទាំងអស់មានសិទ្ធិទទួលដំណឹងអំពីបទល្មើស ដែលចោទប្រកាន់ចំពោះខ្លួន។ ក.ស.ច.ស បានទទួលស្គាល់ថា ជនត្រូវចោទមានសិទ្ធិទទួលដំណឹង អំពីទម្រង់នៃការទទួលខុសត្រូវដែលអាចចោទប្រកាន់ចំពោះខ្លួន។ ក.ស.ច.ស លើកឡើងថា "បញ្ហានេះ ... លើកឡើងពីបញ្ហានៃការជូនដំណឹងឲ្យបានត្រឹមត្រូវដល់ជនត្រូវចោទ លើទម្រង់នៃ ការទទួលខុសត្រូវដែលអាចយកមកប្រើ។ ... ពាក្យ "សហកម្មឧក្រិដ្ឋកម្មរួម" មិនមានចែងច្បាស់ នៅក្នុងច្បាប់ និងក្នុងកិច្ចព្រមព្រៀងទេ។ ... នៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតចាំបាច់ ត្រូវតែឆ្លើយតបទៅនឹងសំណើនេះ ដើម្បីផ្តល់នូវព័ត៌មានគ្រប់គ្រាន់ស្តីអំពីទម្រង់នៃការទទួលខុសត្រូវ ដែលមិនមានចែងច្បាស់នៅក្នុងច្បាប់អ.វ.ត.ក និងកិច្ចព្រមព្រៀង"[13]។

**ខ. សំណើសុំលើកទឡ្ហីករណ៍ផ្ទាល់មាត់**

៦. សិទ្ធិរបស់ **អៀង សារី** អាចនឹងត្រូវបានរំលោភបំពាន។ សេចក្តីសម្រេចរបស់ ក.ស.ច.ស រំលោភបំពានគោលការណ៍នីត្យានុកូលភាព ដូចនេះសេចក្តីសម្រេចនេះរំលោភលើសិទ្ធិជាមូលដ្ឋានក្នុងការ ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលផ្តល់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។ សវនាការសួរដេញដោលផ្ទាល់មាត់ជាសាធារណៈ មាន សារសំខាន់ដើម្បីលើកឡើងនូវបញ្ហានានាឲ្យបានពេញលេញ និងមានតម្លាភាព ដែលបញ្ហាទាំងនោះ បានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។ សេចក្តីសម្រេចរបស់ ក.ស.ច.ស មិនត្រឹមតែប៉ះពាល់ ទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តចំពោះមុខអ.វ.ត.កប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ដល់ឋានៈ នៃ អ.វ.ត.ក ទាក់ទងនឹងច្បាប់អន្តរជាតិ។ ការពិនិត្យមើលជាសាធារណៈនៃការអនុវត្តការទទួលខុស ត្រូវJCE នៅអ.វ.ត.ក ត្រូវទទួលបានការអនុញ្ញាត។

IV. **ទឡ្ហីករណ៍**

ក. **ក.ស.ច.ស ភ័ន្តច្រឡំក្នុងការយល់ឃើញថា អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការ អន្តរជាតិ។ អ.វ.ត.ក ជាតុលាការជាតិកម្ពុជា។**

---

[13] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ១០ (គូសបញ្ជាក់បន្ថែម)។

## ១. សេចក្តីថ្លែងការណ៍របស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០១

៧. ដោយសំអាងលើ អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០១ ក.ស.ច.ស បានភ័ន្តច្រឡំនៅពេលលើកឡើងថា “ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះមុខអ.វ.ត.ក គឺជាការសន្និដ្ឋានដែលទាញចេញអំពីហេតុដែលថា អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ ដែលអនុវត្តច្បាប់អន្តរជាតិ”[14]។ អង្គបុរេជំនុំជម្រះលើកឡើងថា “ក្នុងការអនុវត្តជាក់ស្តែងនិងតាមផ្លូវច្បាប់ អ.វ.ត.ក គឺជាស្ថាប័នឯករាជ្យ ហើយដំណើរប្រតិបត្តិការរបស់ខ្លួនក៏ឯករាជ្យផងដែរ នៅក្នុងរចនាសម្ព័ន្ធតុលាការជាតិកម្ពុជា ... ”[15]។ ទោះបីជាមានការកត់សម្គាល់ឃើញថាការិយាល័យរបស់សហព្រះរាជអាជ្ញា (“ក.ស.ព”) បានលើកឡើងថា អ.វ.ត.កគឺជា “តុលាការលក្ខណៈអន្តរជាតិពិសេសក៏ដោយ”[16] ក៏អង្គបុរេជំនុំជម្រះមិនបានប្រកាន់នូវជំហរយល់ឃើញនេះទេ។

៨. នៅពេលពិភាក្សាអំពីការដាច់ចេញពីគ្នារបស់អ.វ.ត.ក ចេញពីតុលាការយោធា អង្គបុរេជំនុំជម្រះបានយោងលើ “សេចក្តីសម្រេចអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការពិសេសនៃប្រទេសសេរ៉ាឡេអូននៅក្នុងរឿងក្តី *Taylor* ដែលអង្គបុរេជំនុំជម្រះបានធ្វើការពិចារណាថាតុលាការនេះជាតុលាការអន្តរជាតិ ដោយហេតុថា តុលាការនេះបានបង្កើតឡើងដោយសន្ធិសញ្ញា។ ការបង្កើតតុលាការនេះគឺជា “ការសំដែងឆន្ទៈរបស់សហគមន៍អន្តរជាតិ” ដែលជា “ផ្នែកមួយនៃយន្តការស្វែងរកយុត្តិធម៌អន្តរជាតិ ហើយមានយុត្តាធិការក្នុងការកាត់សេចក្តីបទល្មើសអន្តរជាតិធ្ងន់ធ្ងរ”[17]។ តាមការដកស្រង់សេចក្តីថ្លែងការណ៍នេះ ក.ស.ច.ស បានសន្និដ្ឋានថា “អ.វ.ត.ក មាន “លក្ខណៈអន្តរជាតិ” ដែលបង្កើតជា “មូលដ្ឋានក្រោមច្បាប់អន្តរជាតិសម្រាប់អនុវត្តJCE...”[18]។

៩. តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (“តុលាការ SCSL”) ខុសគ្នាយ៉ាងច្រើនពី អ.វ.ត.ក។ ធាតុផ្សំអន្តរជាតិ ត្រូវបានដាក់បញ្ចូលយ៉ាងមានប្រសិទ្ធភាពថា ជា “ផ្នែកមួយ” ក្នុង

---

[14] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២១។

[15] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ “ឌុច”*, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០១), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”, ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌ១៩ (គូសបញ្ជាក់បន្ថែម)។

[16] “សហព្រះរាជអាជ្ញាបានជូនសំអាងថា កត្តាមួយចំនួនដែលបានសង្ខេបនៅក្នុងរបាយការណ៍បង្ហាញពីឯករាជ្យភាពនេះ ដែលធ្វើឲ្យ អ.វ.ត.ក ក្លាយជា ‘សាលាក្តីពិសេស និងមានចរិតលក្ខណៈអន្តរជាតិ’ ។ *ដូចជើងទំព័រខាងលើ* (គូសបញ្ជាក់បន្ថែម)។

[17] *ដូចជើងទំព័រខាងលើដែរ* កថាខណ្ឌ២០។

[18] ដីកាសម្រេច JCE, កថាខណ្ឌ ២១។

ប្រព័ន្ធច្បាប់ជាតិ នៅក្នុងប្រទេសកម្ពុជា ដែលវាខុសគ្នាពីប្រទេសសេរ៉ាឡេអូន ដែលជា "តុលាការកូនកាត់មានឯករាជ្យពីប្រព័ន្ធជាតិ"[19]។ ហេតុដូចនេះ "គេត្រូវប្រយ័ត្នប្រយែងក្នុងការរួមបញ្ចូលតុលាការកូនកាត់ផ្សេងៗទៅក្នុងប្រភេទតែមួយ"។ [តុលាការSCSL], "គណៈវិនិច្ឆ័យតាមបទបញ្ញា-៦៤ (Regulation-64 Panels") របស់ប្រទេសកូសូវ៉ូ, គណៈវិនិច្ឆ័យពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅក្នុងប្រទេសទីម័រខាងកើត និងអង្គជំនុំជម្រះវិសាមញ្ញរបស់ប្រទេសកម្ពុជា គឺមានលក្ខណៈខុសៗគ្នា ទៅតាមមូលដ្ឋានច្បាប់របស់ខ្លួន និងការរួមបញ្ចូលជាពិសេសនៃបុគ្គលិកនិងច្បាប់ ទាំងជាតិនិងអន្តរជាតិ"[20]។

១០. នៅឆ្នាំ២០០០ ប្រធានាធិបតីសេរ៉ាឡេអូនKabbah ស្នើសុំអង្គការសហប្រជាជាតិ ("UN") ជួយបង្កើតតុលាការមួយស្រដៀងនឹងតុលាការICTY និងតុលាការICTR ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ[21]។ ជាការពិត លោកប្រធានាធិបតីបានស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលអាចចែករំលែកជាមួយនឹងតុលាការICTY/ICTR ហើយចៅក្រមអាចជាចៅក្រមអន្តរជាតិ ទោះបីជាលោកប្រធានាធិបតីពិតជាធ្លាប់បានស្នើសុំប្រព័ន្ធសហរដ្ឋអាជ្ញាមួយ ដែលមានសហរដ្ឋអាជ្ញាជាតិ និងសហរដ្ឋអាជ្ញាអន្តរជាតិក៏ដោយ[22]។

១១. ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ បានស្នើសុំអគ្គលេខាធិការធ្វើការចរចារឲ្យមានការព្រមព្រៀងជាមួយរដ្ឋាភិបាលសេរ៉ាឡេអូន "ដើម្បីបង្កើតតុលាការពិសេសឯករាជ្យមួយ..."[23]។

---

[19] អត្ថបទរបស់ Parinaz Kermani Mendez, មានចំណងជើងថា *The New Wave of Hybrid Tribunals: A Sophisticated Approach to Enforcing International Humanitarian Law or an Idealistic Solution with Empty Promises?*, 20 CRIM. L. F. ទំព័រ៥៣, ៦២ (២០០៩) ។

[20] *ដូចជើងទំព័រខាងលើដែរ*, ទំព័រ៦៣។ *សូមមើល រឿងក្តី អៀង សារី*, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ០៣), សារណារបស់លោក អៀង សារី អនុលោមតាមសេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវី សុំការពន្យារពេលសមស្រប ក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨, ឯកសារ C/22/I/26, ERN: 00177265-00177280, ឧបសម្ព័ន្ធ ក, ដែលប្រៀបធៀប អ.វ.ត.ក ទៅនឹងតុលាការ "កូនកាត់" ជាច្រើនទៀត។

[21] លិខិតចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០០០ ចេញពីតំណាងអចិន្ត្រៃយ៍នៃប្រទេសសេរ៉ាឡេអូន ផ្ញើជូនអង្គការសហប្រជាជាតិ ថ្លែងទៅកាន់ប្រធានក្រុមប្រឹក្សាសន្តិសុខ, ឯកសារ អ.ស.ប លេខ S/2000/786, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០០, ទំព័រ៤។

[22] *ដូចជើងទំព័រខាងលើដែរ* ទំព័រ៥។

[23] សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៣១៥, ឯកសារ អ.ស.ប លេខ S/RES/1315 (២០០០), ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០០, ទំព័រ២។

ដោយសារតែបញ្ហាចំណាយ សហគមន៍អន្តរជាតិស្ទាក់ស្ទើរក្នុងការបង្កើតតុលាការ*ពិសេស*មួយទៀត[24]។ ផ្ទុយមកវិញ កិច្ចព្រមព្រៀងដែលសម្រេចបាន ចែងអំពី "តុលាការពិសេសអន្តរជាតិ" ដែលបង្កើតឡើងដោយសន្ធិសញ្ញា "ដើម្បីកាត់សេចក្តីបុគ្គលទាំងឡាយដែលទទួលខុសត្រូវច្រើនបំផុតចំពោះការប្រព្រឹត្តិអំពើរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ និងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលឋិតក្រោមច្បាប់សេរ៉ាឡេអូន"[25]។ អគ្គលេខាធិការបានរៀបរាប់ថា[26]៖

> ការធានានៃការវិវឌ្ឍស្ថាប័នច្បាប់ជាប់ទាក់ទងមួយ ... អាចសម្រេចបានតាមរយៈការភ្ជាប់យុត្តិសាស្ត្រតុលាការពិសេសទៅនឹងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ...។អាស្រ័យហេតុនេះ មាត្រា២០ កថាខណ្ឌ៣ នៃលក្ខន្តិកៈចែងថា ចៅក្រមរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេស ត្រូវទទួលការណែនាំដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការយូហ្គោស្លាវី និងតុលាការរ៉្វាន់ដា។ មាត្រា១៤ កថាខណ្ឌ១ នៃលក្ខន្តិកៈចែងថា វិធាននីតិវិធីនិងភស្តុតាងរបស់តុលាការរ៉្វាន់ដា ត្រូវតែអនុវត្តជាចាំបាច់នូវនីតិវិធីចំពោះមុខតុលាការពិសេស។

១២. ជនទាំងឡាយណាដែលបានផ្តន្ទាទោសដោយSCSL អាចត្រូវបានដាក់ពន្ធនាគារនៅក្នុងរដ្ឋណាមួយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងជាមួយតុលាការICTY ឬតុលាការICTR ស្តីពីការអនុវត្តការដាក់ទណ្ឌកម្ម[27]។ នៅក្នុងការកំណត់រយៈពេលនៃការជាប់ពន្ធនាគារ លក្ខន្តិកៈរបស់តុលាការSCSL ចែងថា តាមករណីសមស្រប អង្គជំនុំជម្រះសាលាដំបូងត្រូវដំណើរការអនុវត្តការផ្តន្ទាទោសដាក់ពន្ធនាគារនៅតុលាការICTR និងនៅក្នុងតុលាការជាតិសេរ៉ាឡេអូន[28]។

១៣. អង្គជំនុំជម្រះសាលាដំបូងនីមួយៗនៅSCSL មានចៅក្រមចំនួនបីរូប៖ ចៅក្រមពីររូបតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដោយផ្តោតអារម្មណ៍ពិសេសលើប្រទេសជាសមាជិក

---

[24] អត្ថបទរបស់ Suzannah Linton, មានចំណងជើងថា *Cambodia, East Timor and Sierra Leone: Experiments in International Justice*, 12 CRIM. L. F. ទំព័រ ១៨៥, ២៣២ (២០០១)។

[25] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសេរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ("កិច្ចព្រមព្រៀង SCSL"), បុព្វកថា (គូសបញ្ជាក់បន្ថែម)។

[26] របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអូន, ឯកសារ អ.ស.ប លេខ S/2000/915, ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០០០, កថាខណ្ឌ ៤១។

[27] កិច្ចព្រមព្រៀង SCSL, មាត្រា ២២(១)។

[28] លក្ខន្តិកៈនៃតុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអូន ("លក្ខន្តិកៈ SCSL"), មាត្រា ១៩(១)។

របស់សហគមន៍សេដ្ឋកិច្ចនៃរដ្ឋអាហ្វ្រិកខាងលិច និងប្រទេសCommonwealth និងចៅក្រមមួយរូបតែងតាំងដោយរដ្ឋាភិបាលសេរ៉ាឡេអូន ទោះបីជាចៅក្រមរូបនោះមិនចាំបាច់ជាជនជាតិសេរ៉ាឡេអូននោះទេ[29]។ អង្គជំនុំជម្រះតុលាការកំពូល មានចៅក្រមចំនួនប្រាំរូប ដែលបីរូបតែងតាំងដោយអង្គការសហប្រជាជាតិ និងពីររូបតែងតាំងដោយសេរ៉ាឡេអូន[30]។ អគ្គលេខាធិការតែងតាំងរដ្ឋអាជ្ញាអន្តរជាតិមួយរូបដើម្បីដឹកនាំការស៊ើបអង្កេត ដោយមានជនជាតិសេរ៉ាឡេអូនមួយរូបជារដ្ឋអាជ្ញារង[31]។ អសនៈរបស់SCSL អាចនឹងផ្លាស់ទៅខាងក្រៅប្រទេសសេរ៉ាឡេអូន[32] ដូចដែលបានធ្វើរួចហើយនៅក្នុងរឿងក្តីCharles Taylor[33]។ កិច្ចព្រមព្រៀងSCSL "ត្រូវបានបញ្ចប់តាមរយៈការព្រមព្រៀងនៃភាគីនានា ក្រោយពីបញ្ចប់នូវសកម្មភាពតុលាការរបស់តុលាការពិសេសនេះ"[34]។ ដូចនេះ គោលសំខាន់នោះគឺថា SCSL ត្រូវបានគ្រប់គ្រងដោយអង្គការសហប្រជាជាតិ។

១៤. ផ្ទុយមកវិញ ការចរចារសម្រាប់បង្កើតអ.វ.ត.ក កើតចេញពីការបង្កើតនូវអង្គជំនុំជម្រះជាតិនៅក្នុងក្របខណ្ឌប្រព័ន្ធតុលាការកម្ពុជា ដែលជួយដោយមូលនិធិ និងធនធានអន្តរជាតិ។ ទាំងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិមិនមានបំណងបង្កើតអ.វ.ត.កជាតុលាការអន្តរជាតិមួយនោះទេ។ គ្មានឯកសារមូលដ្ឋានគ្រឹះរបស់អ.វ.ត.ក បង្ហាញយ៉ាងច្បាស់ឬបង្កប់ន័យយ៉ាងដូច្នេះនោះទេ។

១៥. នៅក្នុងអំឡុងពេលចរចាររវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិស្នើសុំឲ្យបង្កើតនូវតុលាការអន្តរជាតិមួយ។ ទោះបីជាយ៉ាងណាក៏ដោយ មតិយោបល់នេះត្រូវបានបដិសេធយ៉ាងច្បាស់ដោយរដ្ឋាភិបាលកម្ពុជា[35]។ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ទទូចសុំថា វិសាលភាពនៃការចូលរួមរបស់អង្គការសហប្រជាជាតិត្រូវបានកម្រិតត្រឹម "ការផ្តល់អ្នកជំនាញដើម្បីជួយប្រទេសកម្ពុជាក្នុងការធ្វើសេចក្តីព្រាងច្បាប់ ដែលអាចផ្តល់ឲ្យតុលាការជាតិ

---

[29] *ដូចជើងទំព័រខាងលើដែរ* មាត្រា ១២។ កិច្ចព្រមព្រៀង SCSL, មាត្រា២។

[30] លក្ខន្តិកៈ SCSL, មាត្រា១២។ កិច្ចព្រមព្រៀង SCSL, មាត្រា ២។

[31] របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការបង្កើតតុលាការពិសេសសម្រាប់ប្រទេស សេរ៉ាឡេអូន, ឯកសារ អ.ស.ប លេខ S/2000/915, ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០០០, កថាខណ្ឌ៤៧។

[32] កិច្ចព្រមព្រៀង SCSL, មាត្រា ១០។

[33] *សូមមើល* សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ១៦៨៨, ឯកសារ អ.ស.ប លេខ S/RES/1688 (២០០៦), ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦។

[34] កិច្ចព្រមព្រៀង SCSL, មាត្រា ២៣។

[35] របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការជំនុំជម្រះក្តីខ្មែរក្រហម, ឯកសារ អ.ស.ប លេខ A/57/769, ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣, កថាខណ្ឌ ៦។

កម្ពុជាពិសេសមួយធ្វើការជំនុំជម្រះមេដឹកនាំខ្មែរក្រហម និងអាចផ្តល់ឱ្យចៅក្រមនិងព្រះរាជអាជ្ញាបរទេសចូលរួមនៅក្នុងដំណើរការនីតិវិធី"[36]។ ដូចនេះ ដោយគ្មានចម្ងល់អ្វីទាំងអស់ រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានចរចា និងបានសម្រេចកិច្ចព្រមព្រៀងបង្កើតអ.វ.ត.កជាតុលាការជាតិមួយនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានរួចហើយ[37]។

១៦. តាមរយៈការឆ្លុះបញ្ចាំងអំពីចេតនា និងលទ្ធផលនៃការចរចា កិច្ចព្រមព្រៀងចែងថា៖

> **ដោយហេតុថា** នៅមុនពេលចរចាលើកិច្ចព្រមព្រៀងនេះ មានការរីកចម្រើនជាច្រើនធ្វើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ... និងរដ្ឋាភិបាលកម្ពុជា ឈានទៅរកការបង្កើតនូវអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ...
>
> **ដោយហេតុថា** តាមសេចក្តីសម្រេចចិត្តលេខ ៥៧/២២៨ មហាសន្និបាត ... បានស្នើសុំលោកអគ្គលេខាធិការឱ្យបន្តការចរចា ដោយពុំមានការពន្យារពេលដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាល ដោយឈរលើការចរចាពីពេលមុន...[38]។

ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក បានបញ្ជាក់ថា "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់..."[39]។

---

[36] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ៧ (គូសបញ្ជាក់បន្ថែម)។

[37] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ១០។ អគ្គលេខាធិការបានថ្លែងថា "ក្នុងកថាខណ្ឌ១ នៃសេចក្តីសម្រេចចិត្តលេខ៥៧/២២៨ មហាសន្និបាតចាត់តាំងខ្ញុំយ៉ាងច្បាស់ ឱ្យចចារដើម្បីសម្រេចឱ្យបានកិច្ចព្រមព្រៀង ដែលស្របគ្នានឹងបទប្បញ្ញត្តិរបស់សេចក្តីសម្រេចចិត្តនេះ។ ខ្ញុំយល់ឃើញថា ដើម្បីឱ្យស្របទៅនឹងលក្ខខណ្ឌនៃសេចក្តីសម្រេចចិត្ត កិច្ចព្រមព្រៀងណារវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែបំពេញលក្ខខណ្ឌខាងក្រោមនេះ៖ (ក) កិច្ចព្រមព្រៀងនេះត្រូវគោរពតាម និងផ្តល់ប្រសិទ្ធភាពច្បាស់លាស់ចំពោះគោលការណ៍ ដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវតែជាតុលាការជាតិ ឋិតនៅក្រោមរចនាសម្ព័ន្ធតុលាការដែលមានស្រាប់របស់កម្ពុជា ដែលត្រូវបានបង្កើតឡើង និងប្រតិបត្តិដោយជំនួយអន្តរជាតិ ..." *សូមមើលផងដែរ ដូចជើងទំព័រខាងលើ*, កថាខណ្ឌ៣១, ដែលរូបគាត់ពិភាក្សាអំពីប្រភេទនៃ អ.វ.ត.ក ក្រោមសេចក្តីព្រៀងកិច្ចព្រមព្រៀងថា៖ "ដូចគ្នាទៅនឹងស្ថាប័នច្បាប់ផ្សេងទៀតដែរ ប្រភេទច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ ត្រូវកំណត់ដោយលិខិតុបករណ៍ដែលបានបង្កើតច្បាប់ទាំងនោះ។ ស្របតាមសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ អង្គជំនុំជម្រះវិសាមញ្ញត្រូវបង្កើតឡើងដោយច្បាប់ជាតិរបស់កម្ពុជា។ ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញត្រូវជាតុលាការជាតិកម្ពុជា ដែលត្រូវបានបង្កើតឡើងក្រោមរចនាសម្ព័ន្ធតុលាការរបស់ប្រទេសនេះ"។ (គូសបញ្ជាក់បន្ថែម)។

[38] កិច្ចព្រមព្រៀង, បុព្វកថា។

[39] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះ"), មាត្រា២ថ្មី (គូសបញ្ជាក់បន្ថែម)។

00438490



១៧. នៅក្នុងការសម្រេចថាតើច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ បានអនុលោមតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ឬមិនបាននោះ ការព្រួយបារម្ភរបស់ក្រុមប្រឹក្សាធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាទៅនឹងឋានៈរបស់អ.វ.ត.ក មានលក្ខណៈច្បាស់លាស់។ យើងបានកត់សម្គាល់ថា "ដើម្បីបម្រើការអង្គជំនុំជម្រះវិសាមញ្ញនេះ ទាំងភាគីខ្មែរ ទាំងភាគីមកពីអង្គការសហប្រជាជាតិ សុទ្ធតែ<u>ត្រូវបាន</u>តែងតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែល<u>ជាស្ថាប័នកំពូលជាតិខ្មែរសុទ្ធសាធ</u> សូម្បីតែប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាល ក៏ត្រូវបានតែងតាំងដោយអាជ្ញាធរ<u>កម្ពុជា</u>ដែរ។ <u>អង្គការសហប្រជាជាតិ មានភារកិច្ចត្រឹមស្នើបញ្ជីបេក្ខជនតែប៉ុណ្ណោះ ហើយគ្មានសិទ្ធិសម្រេចទេ</u>"[40]។ ក្រុមប្រឹក្សាធម្មនុញ្ញ បានលើកឡើងបន្ថែមថា "<u>ការយកប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់</u> និងការរើសយករាជធានីភ្នំពេញជាទីតាំងដំណើរការ <u>ជាការគាំពារថ្មីមួយទៀតដល់អធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា</u>"[41]។

១៨. គេហទំព័ររបស់ អ.វ.ត.ក និងអង្គការសហប្រជាជាតិផ្នែកជំនួយដល់ការកាត់សេចក្តីខ្មែរក្រហម ("UNAKRT") ក៏បានពន្យល់ទៅសាធារណជនថា អ.វ.ត.កគឺជាតុលាការជាតិកម្ពុជា ។ គេហទំព័ររបស់អ.វ.ត.ក សរសេរថា "រដ្ឋាភិបាលកម្ពុជាបានទទូចសុំថា ដើម្បីជាផលប្រយោជន៍ដល់ប្រជាជនកម្ពុជាទាំងអស់ តុលាការជម្រះក្តីត្រូវប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជាដោយប្រើប្រាស់មន្ត្រី និងចៅក្រមកម្ពុជាគួបផ្សំជាមួយមន្ត្រី និងចៅក្រមអន្តរជាតិ។ កម្ពុជាបានអញ្ជើញសហគមន៍អន្តរជាតិឱ្យចូលរួមសហការក្នុងការកាត់សេចក្តីនេះ ដោយសារកម្ពុជា នៅទន់ខ្សោយផ្នែកតុលាការ និងដោយសារលក្ខណៈអន្តរជាតិនៃបទល្មើស និងដើម្បីជួយធានាឱ្យមានយុត្តិធម៌ជាលក្ខណៈស្តង់ដារអន្តរជាតិ"[42]។ គេហទំព័រUNAKRT បានសរសេរថា "<u>UNAKRT ផ្តល់ជំនួយបច្ចេកទេស</u>ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ អ.វ.ត.ក គឺជាតុលាការជាតិមួយដែលគាំទ្រដោយបុគ្គលិកអន្តរជាតិ បង្កើតឡើងដោយអនុលោមតាមច្បាប់កម្ពុជា"[43]។

១៩. ភាពខុសគ្នាពិសេសផ្សេងទៀត ដែលតុលាការSCSL មាន"លក្ខណៈជាតុលាការអន្តរជាតិ" ខុសគ្នាពីអ.វ.ត.ក ដែលមានលក្ខណៈជាតុលាការជាតិមួយ រួមមាន៖

---

[40] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០/០០២/២០០១ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ ទំព័រ៣ (បកប្រែក្រៅផ្លូវការ និងគូសបញ្ជាក់បន្ថែម)។

[41] *ដូចជើងទំព័រខាងលើដែរ* ទំព័រ៤ (បកប្រែក្រៅផ្លូវការ គូសបញ្ជាក់បន្ថែម)។

[42] អាចរកបាននៅគេហទំព័រ http://www.eccc.gov.kh/english/about_eccc.aspx.

[43] អាចរកបាននៅគេហទំព័រ <u>http://www.unakrt-online.org/01_home.htm</u> (គូសបញ្ជាក់បន្ថែម)។

- សមាសភាពរបស់ចៅក្រម និងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ មានលក្ខណៈខុសគ្នា៖ កម្ពុជា គឺជាអ្នកទទួលខុសត្រូវចំពោះការតែងតាំងសមាសភាពអន្តរជាតិ មិនមែនអង្គការសហប្រជាជាតិទេ។

- នៅអ.វ.ត.ក សហមេធាវីការពារក្តី ត្រូវតែ "អនុវត្តតាម ... ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី ..."[44]។ មិនមានលក្ខខណ្ឌតម្រូវបែបនេះនៅតុលាការSCSLទេ។

- ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះ មិនបានលើកឡើងថា ចៅក្រមត្រូវទទួលការណែនាំដោយសេចក្តីសម្រេចតុលាការកំពូលរបស់តុលាការICTY/ICTR *ឬ*វិធាននីតិវិធីរបស់តុលាការនេះ *ឬ*ការអនុវត្តការផ្តន្ទាទោស។

- ជនទាំងឡាយដែលត្រូវបានផ្តន្ទាទោសដោយអ.វ.ត.ក មិនមានលទ្ធភាពទទួលការជាប់ពន្ធនាគារ ក្នុងរដ្ឋដែលរៀបចំកិច្ចព្រមព្រៀង ដូចក្នុងតុលាការICTY ឬ ICTRនោះទេ។

- គ្មានបទប្បញ្ញត្តិណាមួយដែលអនុញ្ញាតឱ្យអ.វ.ត.ក ផ្លាស់ទីតាំងរបស់ខ្លួនទៅខាងក្រៅប្រទេសកម្ពុជាទេ។

- ការបញ្ចប់ដំណើរការរបស់អ.វ.ត.ក មានលក្ខណៈខុសគ្នាផងដែរ។ មាត្រា២៨ នៃកិច្ចព្រមព្រៀងចែងថា "ប្រសិនបើរាជរដ្ឋាភិបាលផ្លាស់ប្តូររចនាសម្ព័ន្ធ ឬការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ឬក៏ធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះដំណើរការតាមរបៀបណាមួយដែលមិនសមស្របជាមួយខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អង្គការសហប្រជាជាតិរក្សាសិទ្ធិផ្អាកជំនួយឧបត្ថម្ភជាហិរញ្ញវត្ថុ ឬជាអ្វីផ្សេងទៀតដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ"[45]។ អ.វ.ត.ក នឹងមិនចាំបាច់បញ្ឈប់ដំណើរការនោះទេ ប្រសិនបើកិច្ចព្រមព្រៀងត្រូវបានបញ្ចប់។

## ២. សេចក្តីថ្លែងការណ៍របស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១

២០. ផ្ទុយទៅនឹងសេចក្តីប្រកាសរបស់អង្គបុរេជំនុំជម្រះដែលលើកសំអាងដោយក.ស.ច.ស អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០១ បានលើកឡើងថា អ.វ.ត.ក "ត្រូវបានបង្កើតឡើង

---

[44] កិច្ចព្រមព្រៀង មាត្រា ២១(៣)។

[45] គូសបញ្ជាក់បន្ថែម។

ដាច់ដោយឡែក ឯករាជ្យ និងមានលក្ខណៈអន្តរជាតិ”[46]។ សេចក្តីប្រកាសនេះធ្វើឡើងក្នុងគោលបំណងបង្ហាញតួនាទីរបស់អ.វ.ត.ក *នៅក្នុង* រចនាសម្ព័ន្ធតុលាការជាតិ និងទំនាក់ទំនងរបស់វាទៅនឹងតុលាការជាតិផ្សេងទៀត[47]។ អង្គជំនុំជម្រះសាលាដំបូងមិនបានរៀបរាប់ច្រើន អំពីលក្ខណៈ “អន្តរជាតិ” ក្រៅតែពីការបង្ហាញថា ដំណើរការនីតិវិធីចំពោះមុខអ.វ.ត.ក មិនអាចចាត់ទុកថាជាការបន្តនូវសំណុំរឿងខុច ពីតុលាការយោធានោះទេ។ អង្គជំនុំជម្រះសាលាដំបូងប្រាកដជាមិនបានប្រកាស ឬពីព្រោះមិនអាចប្រកាសថា អ.វ.ត.កមានសមត្ថកិច្ចនិងអំណាចក្នុងការអនុវត្តដោយផ្ទាល់នូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិដោយផ្អែកលើលក្ខណៈ “អន្តរជាតិ”នេះ ដូចដែលក.ស.ច.សលើកឡើងនោះទេ[48]។

២១. អង្គជំនុំជម្រះសាលាដំបូង <u>គ្រាន់តែ</u>បានពន្យល់ថា <u>រចនាសម្ព័ន្ធ</u>របស់អ.វ.ត.ក ខុសគ្នាពីរចនាសម្ព័ន្ធរបស់តុលាការកម្ពុជាផ្សេងទៀត។ <u>នីតិវិធី</u>របស់តុលាការ ត្រូវតែស្របជាមួយនឹងច្បាប់កម្ពុជា ព្រមទាំងឲ្យស្របជាមួយនឹងបទដ្ឋានអន្តរជាតិ[49]។ លក្ខខណ្ឌវិនិច្ឆ័យ ត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញកម្ពុជា[50]។ កិច្ចព្រមព្រៀងចែងថា៖

> នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា ពុំអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ[51]។

នីតិវិធីនៅអ.វ.ត.ក ប្រហែលអាចខុសគ្នាពីនីតិវិធីដែលប្រើប្រាស់នៅក្នុងតុលាការកម្ពុជាផ្សេងៗ

---

[46] *សំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ “ឌុច”*, 00១/១៨-0៧-២00៧-អ.វ.ត.ក/អ.ជ.ស.ដ, សេចក្តីសម្រេចលើសំណើសុំដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២00៩, E39/5, ERN: 00338832-00338846 (“សេចក្តីសម្រេចលើសំណើសុំដោះលែង*ឌុច*របស់អង្គជំនុំជម្រះសាលាដំបូង” កថាខណ្ឌ១0។

[47] នេះក៏ជាមូលហេតុដែលអង្គបុរេជំនុំជម្រះបានពិភាក្សាបញ្ហានេះ ដែលសេចក្តីសម្រេចនេះត្រូវបានដកស្រង់ដោយក.ស.ច.ស។

[48] ដីកាសម្រេចJCE កថាខណ្ឌ២១។

[49] សេចក្តីសម្រេចលើសំណើសុំដោះលែង*ឌុច*របស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ១១។ (“<u>រចនាសម្ព័ន្ធ</u>របស់អ.វ.ត.ក មានលក្ខណៈខុសគ្នាពីរចនាសម្ព័ន្ធរបស់តុលាការកម្ពុជាផ្សេងទៀត។ ពីព្រោះ<u>នីតិវិធីរបស់អ.វ.ត.ក ស្របជាមួយច្បាប់កម្ពុជា</u> អ.វ.ត.ក មានសិទ្ធិអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួនឲ្យស្របជាមួយនឹងបទដ្ឋានអន្តរជាតិ...” (គូសបញ្ជាក់បន្ថែម)។

[50] *សូមមើល* រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលបានធ្វើវិសោធនកម្មឆ្នាំ១៩៩៩ មាត្រា៣១។

[51] កិច្ចព្រមព្រៀង មាត្រា១២(១)។ *សូមមើលផងដែរ* ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ មាត្រា២0ថ្មី មាត្រា២៣ថ្មី។

ត្រង់ថា កិច្ចព្រមព្រៀង<u>មិន</u>អនុញ្ញាតឱ្យផ្លាស់ប្តូរច្បាប់សារធាតុជាធរមានទេ។ កិច្ចព្រមព្រៀង <u>មិនអាច</u> ចាត់ទុកថាជាលិខិតអនុញ្ញាត*ពេញលេញ* ដើម្បីណែនាំទស្សនទានច្បាប់បរទេសដែលមិនមានមូលដ្ឋាននៅក្នុងច្បាប់កម្ពុជា និង/ឬ ផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជានោះទេ។

២២. អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ភាពខុសគ្នាមួយរវាងអ.វ.ត.ក និងតុលាការកម្ពុជាផ្សេងទៀតគឺថា អ.វ.ត.ក "មានបុគ្គលិក និងមន្ត្រីតុលាការកម្ពុជា និងអន្តរជាតិ ដែលមិនមានសមត្ថកិច្ចចូលរួមចំពោះមុខ ឬសម្រេចលើសេចក្តីសម្រេចមួយ ដោយតុលាការកម្ពុជាក្នុងស្រុកទេ។ លើសពីនេះ ចៅក្រមកម្ពុជានៅអ.វ.ត.ក មានបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ បន្ថែមពីលើសិទ្ធិទាំងឡាយដែលមានដោយចៅក្រមកម្ពុជាផ្សេងទៀត"[52]។ ថ្វីបើមានភាពខុសគ្នាទាំងនេះក្តី <u>រាជរដ្ឋាភិបាលកម្ពុជាមានអំណាចនិងឆន្ទានុសិទ្ធិចុងក្រោយ</u> ដើម្បីឱ្យបុគ្គលណាក្លាយជាចៅក្រម សហចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញានៅអ.វ.ត.ក។ ការតែងតាំងត្រូវធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយផ្អែកលើការជ្រើសតាំងរបស់អង្គការសហប្រជាជាតិ[53]។

២៣. ប្រសិនបើអ.វ.ត.ក គឺពិតជាតុលាការអន្តរជាតិមួយ (ឬមានលក្ខណៈអន្តរជាតិ ដូចដែល ក.ស.ព បានហៅនោះ) ត្រឹមវិសាលភាពណាមួយ ដែលអាចប្រើប្រាស់ច្បាប់និងទម្រង់នៃការទទួលខុសត្រូវដែលខុសគ្នាពីនិងផ្ទុយគ្នាពីរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌដូចនេះហេតុដូចម្តេចបានជា ចៅក្រមតុលាការនេះមិនមានសមត្ថកិច្ចដោះស្រាយបញ្ហាពុករលួយនៅអ.វ.ត.ក? សេចក្តីសម្រេចរបស់ចៅក្រមអ.វ.ត.កក្នុងការគោរពតាមរដ្ឋាភិបាលកម្ពុជាដោយបដិសេធមិនឆ្លើយតាមនឹងបញ្ហានេះ[54] មានន័យថា ចៅក្រមបានចាត់ទុកអ.វ.ត.ក ថាជាតុលាការកម្ពុជា។ ជាការពិតណាស់ តុលាការអន្តរជាតិ *ពិសេស* ឬ តុលាការ"លក្ខណៈអន្តរជាតិ" មិនមានចេតនាមិនអើពើ បើមិនទទួលស្គាល់ (ជាការយល់ឃើញ ដោយខ្វះចំណាត់ការ)លើករណីនៃ

---

[52] សេចក្តីសម្រេចលើសំណើសុំដោះលែង*ឌុច*របស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ១១។

[53] កិច្ចព្រមព្រៀង មាត្រា៣(១), ៥(៥), ៦(៥)។

[54] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ២០), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ នួន ជា, ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ឯកសារ D158/5/3/15, ERN: 00366747-00366761, កថាខណ្ឌ ២៩៖ "អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញបន្ថែមទៀតថា ករណីនេះកំពុងស្ថិតនៅចំពោះមុខស្ថាប័នសមស្របគឺរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ"។

ការប្រព្រឹត្តិអំពើពុករលួយ ដែលត្រូវបានអះអាងថាមាននៅអ.វ.ត.កនោះទេ[55]។

២៤. ពាក្យ "លក្ខណៈអន្តរជាតិ" មិនមានអត្ថន័យដោយខ្លួនឯង ថាតើអ.វ.ត.កអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ កុំថាឡើយដល់ទៅយុត្តិសាស្ត្រតុលាការICTY និងICTR ដែលអះអាងថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទៀតនោះ។ នៅពេលពិនិត្យមើលនៅក្នុងបរិបទនេះ អង្គបុរេជំនុំជម្រះនិងអង្គជំនុំជម្រះសាលាដំបូង គ្រាន់តែមានន័យចង់ពន្យល់ថា ដោយសារតែជំនួយរបស់UN អ.វ.ត.កមានចរិតលក្ខណៈច្បាស់លាស់ដែលតុលាការកម្ពុជាជាតិផ្សេងទៀតមិនមានចរិតលក្ខណៈនេះ និងដោយសារអាណត្តិរបស់ខ្លួន វាមិនមានព្រំដែនអំណាចដែលភ្ជាប់អ.វ.ត.កទៅនឹងតុលាការផ្សេង

---

[55] *សូមមើល រឿងក្តី នួន ជា សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស , សំណើលើកទីដប់មួយសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ឯកសារ D158, ERN: 002294816-00294830។ *សូមមើល រឿងក្តី នួន ជា សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩, ឯកសារ D158/5, ERN: 00294885-00294888។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ញត្តិរបស់លោក អៀង សារី សុំចូលរួមនឹងទទួលយកតាមសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទី១១ របស់ នួន ជា, ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩, ឯកសារ D258/2, ERN: 00294872-00294873។ *រឿងក្តី នួន ជា សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ២១), បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើលើកទី១១ ស្នើសុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ឯកសារ D158/5/1/1, ERN: 00323238-00323255។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ២០), បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរអំពីការចោទប្រកាន់ជាហូរហែរអំពីអំពើពុករលួយ និងសំណើសុំចាត់ការសវនាការដេញដោលផ្ទាល់មាត់ឱ្យឆាប់រហ័ស, ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩, ឯកសារ D158/5/3/1, ERN: 00323171-00323193។ *រឿងក្តី នួន ជា សំណុំរឿងលេខ* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ២១), សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើលើកទីដប់មួយរបស់ជនត្រូវចោទ សុំបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩, ឯកសារ D158/5/1/15, ERN: 00364033-00364046។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, (អ.ប.ជ២០), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីដប់មួយរបស់ នួន ជា, ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩, ឯកសារ D158/5/3/15, ERN: 00366747-00366761។ *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ, ក្រុម១--ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះសាលាដំបូង ជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS, ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩, ឯកសារ E65, ERN: 00327910-00327919។ *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច",* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ, សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី-ក្រុម១ ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ជួយសម្រួលឱ្យមានការផ្សព្វផ្សាយដល់ភាគីនូវរបាយការណ៍របស់ UN-OIOS, ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩, ឯកសារ E65/9, ERN: 00378404-00378411។

ទៀតនៃប្រព័ន្ធតុលាការកម្ពុជា។ មិនមានអ្វីនៅក្នុងសេចក្ដីប្រកាសដែលធ្វើឡើងដោយអង្គបុរេជំនុំជម្រះ ឬអង្គជំនុំជម្រះសាលាដំបូង ស្នើសុំថា អ.វ.ត.ក អាចអនុវត្តស្រដៀងគ្នានឹងតុលាការ ICTY, ICTR ឬSCSL ដោយគ្មានការពិចារណាដល់ប្រព័ន្ធច្បាប់កម្ពុជានោះទេ។ ចៅក្រមអ.វ.ត.ក មិនអាចដណ្ដើមអំណាចនយោបាយនិងអំណាចរដ្ឋធម្មនុញ្ញរបស់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិដែលត្រូវបានបោះឆ្នោតត្រឹមត្រូវរបស់ព្រះរាជាណាចក្រកម្ពុជាទេ។

## ខ. ក.ស.ច.ស មានវិការៈក្នុងការអះអាងថា ដោយសារ អ.វ.ត.ក មានចរិតលក្ខណៈជាតុលាការអន្តរជាតិ តុលាការនេះអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន។

### ១. អ.វ.ត.ក ដែលជាតុលាការក្នុងស្រុក មិនអាចអនុវត្តការទទួលខុសត្រូវ JCE ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានឡើយ។

២៥. ក.ស.ច.ស យល់ឃើញថា ការទទួលខុសត្រូវ JCE មិនមាននៅក្នុងច្បាប់ប្រទេសកម្ពុជាឡើយ នៅពេលដែលខ្លួនបានធ្វើការសន្និដ្ឋានថា "ធាតុផ្សំនៃ JCE ដែលសហចៅក្រមស៊ើបអង្កេតយល់ថាជាច្បាប់ដែលត្រូវអនុវត្តបាននៅ អ.វ.ត.ក អាចអនុវត្តចំពោះតែបទល្មើសអន្តរជាតិប៉ុណ្ណោះ មិនមែនអាចអនុវត្តចំពោះបទល្មើសក្នុងច្បាប់ជាតិនោះទេ"[56]។ នេះគឺជាសំអាងហេតុតាមផ្លូវច្បាប់ដ៏ត្រឹមត្រូវ[57]។

២៦. ទោះបីជាយ៉ាងណាក៏ដោយ ក.ស.ច.ស មានវិការៈ នៅពេលដែលខ្លួនយល់ថា ក.ស.ច.ស អាចអនុវត្តការទទួលខុសត្រូវ JCE ជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចំពោះបទល្មើសអន្តរជាតិ[58]។ ដូចដែលបានលើកទឡ្ហីករណ៍ខាងក្រោមនេះ ការទទួលខុសត្រូវ JCE គឺមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ទោះបីជា JCE ត្រូវបានគេពិចារណាថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏ អ.វ.ត.ក មិនអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបានដែរ។ នេះដោយសារតែ : ១. ប្រទេសកម្ពុជាមិនបានទទួលស្គាល់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិគឺជាការចងភ្ជាប់កាតព្វកិច្ច និងអាចអនុវត្តបានក្នុងស្រុក និង ២. ច្បាប់កម្ពុជាមិនអនុញ្ញាតឲ្យមានការអនុវត្តបទប្បញ្ញត្តិច្បាប់

---

56 ដីកាសម្រេច JCE កថាខណ្ឌ ២២។

57 សម្រាប់ការវិភាគលំអិតទៅលើបញ្ហានេះ សូមមើល ឧបសម្ពន្ធ ក ផ្នែក II គ។

58 ដូចជើងទំព័រខាងលើ កថាខណ្ឌ ២១។

ព្រហ្មទណ្ឌឥតសរសេរចែងទុកជាមុនឡើយ។

២៧. "ជាធម្មតា តុលាការជាតិមិនអនុវត្តដំណើរការនីតិវិធីចំពោះបទល្មើសអន្តរជាតិ ដោយផ្អែកតែទៅលើច្បាប់*ទំនៀមទម្លាប់*អន្តរជាតិនោះឡើយ ប្រសិនបើបទល្មើសមួយត្រូវបានគេចែងសម្រាប់តែនៅក្នុងច្បាប់នោះប៉ុណ្ណោះ"[59]។ យោងតាមការសិក្សាប្រៀបធៀបរបស់វិទ្យាស្ថាន Max-Planck ទាក់ទិនទៅនឹងការផ្តន្ទាទោសតាមច្បាប់ជាតិសម្រាប់បទល្មើសអន្តជាតិ[60] មានបុរេលក្ខខណ្ឌពីរ ក្នុងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងតុលាការជាតិ :

> ទីមួយ ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវតែអាចអនុវត្តបានដោយតុលាការជាតិនៃរដ្ឋនីមួយៗ។ រដ្ឋដែលចង់ដាក់ទោសទណ្ឌដល់នរណាម្នាក់ ... ដោយការអនុវត្តដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាទូទៅ ត្រូវតែទទួលស្គាល់ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាការចងភ្ជាប់កាតព្វកិច្ច និងអាចអនុវត្តបាននៅក្នុងរដ្ឋនោះ[61]។
>
> ...
>
> ទីពីរ ច្បាប់ជាតិ ត្រូវតែអនុញ្ញាតឱ្យមានការអនុវត្តបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលឥតសរសេរទុកជាមុន។ នៅក្នុងបណ្តាប្រទេសជាច្រើន គោលការណ៍ដ៏តឹងរ៉ឹងនៃនីត្យានុកូលភាព ហាមឃាត់មិនឱ្យមានការផ្តន្ទាទោសឧក្រិដ្ឋជន ដោយអនុវត្តបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌដែលឥតសរសេរទុកជាមុន[62]។

---

59 ANTONIO CASSESE, INTERNATIONAL CRIMINAL LAW 303 (Oxford University Press 2003).

60 សម្រាប់ការពណ៌នាអំពីការសិក្សាស្រាវជ្រាវ ដែលមានចំណងជើងថា ការផ្តន្ទាទោសតាមច្បាប់ជាតិ សម្រាប់បទឧក្រិដ្ឋអន្តរជាតិ ដែលបានធ្វើឡើងដោយ Max-Planck Institut für ausländisches und internationales Strafrecht, Freiburg, Germany សូមមើល http://www.mpicc.de/ww/en/pub/forschung/forschungsarbeit/strafrecht/nationale_strafverfolgung.htm។

61 បណ្ឌិត Kreicker ផ្តល់នូវឧទាហរណ៍អំពីប្រទេសអាល្លឺម៉ង់ : "រដ្ឋធម្មនុញ្ញអាល្លឺម៉ង់ ចែងនៅក្នុងមាត្រា ២៥ ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាផ្នែកនៃ ច្បាប់សហព័ន្ធអាល្លឺម៉ង់ ហើយដូច្នេះ វាចងកាតព្វកិច្ចមនុស្សគ្រប់រូប"។ កត់សំគាល់ថា រដ្ឋធម្មនុញ្ញកម្ពុជាមិនមានបទប្បញ្ញត្តិបែបនេះឡើយ។

62 ពិភាក្សាដោយបណ្ឌិត Helmut Kreicker ប្រធានផ្នែក "ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ" នៅវិទ្យាស្ថាន Max-Planck (MPI) សម្រាប់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងបរទេស, Freiburg ប្រទេសអាល្លឺម៉ង់, ក្នុងកិច្ចការរបស់គាត់ : *National Prosecution of Genocide from a Comparative Perspective*, 5 INT'L CRIM. L. REV. 313, 319-20 (2005) ("Kreicker")។ បណ្ឌិត Kreicker បានបន្តពន្យល់ទៀតថា "សូម្បីនៅក្នុងរដ្ឋទាំងនោះដែលមិនតម្រូវឱ្យមានបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាលាយលក្ខណ៍អក្សរ ប៉ុន្តែព្រមទទួលសុពលភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅថ្នាក់ជាតិ ... <u>តំរូវនៃការអនុវត្តដោយផ្ទាល់ នូវច្បាប់ព្រហ្ម</u>

២៨. ប្រទេសកម្ពុជាប្រកាន់យកប្រព័ន្ធទ្វិកនិយម (dualist) ជាជាងប្រព័ន្ធឯកនិយម (monist) ដូច្នេះ នឹងមិនអនុវត្តដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ ដោយមិនមានសេចក្តីណែនាំជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញ នីតិកម្ម ឬយុត្តិសាស្ត្រជាតិរបស់ខ្លួន ដែលច្របាច់បញ្ចូលវានៅក្នុងច្បាប់ក្នុងស្រុក[63]។ ទាំងរដ្ឋធម្មនុញ្ញ ដែលមានជាធរមាននៅពេលដែលបទល្មើសដែលត្រូវបានចោទប្រកាន់ត្រូវបានគេប្រព្រឹត្ត និងរដ្ឋធម្មនុញ្ញនាពេលបច្ចុប្បន្នរបស់កម្ពុជា មិនបានចែងនូវនីតិវិធីសម្រាប់ការច្របាច់បញ្ចូលច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅក្នុងច្បាប់ក្នុងស្រុកឡើយ។ រដ្ឋសភាជាតិរបស់ប្រទេសកម្ពុជា មិនបានអនុម័តនីតិកម្មណាមួយ ដែលច្របាច់បញ្ចូលការទទួលខុសត្រូវ JCE ទៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុកឡើយ។

២៩. ច្បាប់កម្ពុជា <u>មិនបាន</u>អនុញ្ញាតឲ្យមានការអនុវត្តបទប្បញ្ញត្តិច្បាប់ដែលមិនមានសរសេរទុកជាមុនឡើយ[64]។ ស្រដៀងគ្នានេះដែរ តុលាការប្រទេសបារាំង ដែលប្រព័ន្ធច្បាប់របស់តុលាការប្រទេសនេះ ត្រូវបានប្រព័ន្ធច្បាប់កម្ពុជាយកគំរូតាមនោះ[65] បានបញ្ជាក់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ <u>មិនអាច</u>ត្រូវបានយកមកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការប្រទេសបារាំងឡើយ ដោយសារតែមិនមានបទប្បញ្ញត្តិចែងនៅក្នុងយុត្តាធិការប្រទេសបារាំង ដែលចាត់ទុកអំពើដែលពាក់ព័ន្ធថាជា

---

<u>ទណ្ឌទំនៀមទម្លាប់អន្តរជាតិ មិនត្រូវបានគេយកជាជម្រើសឡើយ។ ក្រោមការត្រួតពិនិត្យនៅក្នុងគម្រោង MPI មិនមាននៅក្នុងប្រទេសណាមួយឡើយ ដែលវាជាជម្រើសមួយក្នុងការផ្តន្ទាទោសចារី</u> នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ <u>ដោយគ្រាន់តែអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ</u>។ តាមវិធីមួយ ឬវិធីម៉្យាងវិញទៀត បទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌជាតិត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសក្រោមច្បាប់ជាតិ"។ ដូចជើងទំព័រខាងលើ ត្រង់ចំណុច ៣២០ (សេចក្តីបញ្ជាក់បន្ថែម)។

[63] ការប្រកាន់យកប្រព័ន្ធទ្វិកនិយម (dualist) ឬប្រព័ន្ធឯកនិយម (monist) គឺកំណត់នូវយន្តការដែលរដ្ឋប្រើប្រាស់ ដើម្បីផ្តល់ប្រសិទ្ធភាពដល់កាតព្វកិច្ចអន្តរជាតិរបស់ខ្លួន។ រដ្ឋដែលប្រកាន់ប្រព័ន្ធទ្វិកនិយម ចាត់ទុកច្បាប់អន្តរជាតិថាមានលក្ខណៈដោយឡែកពីច្បាប់ជាតិ។ សូមមើល ឧបសម្ព័ន្ធ II ថ (១)(ក) សម្រាប់ការពិភាក្សាអំពីភាពខុសគ្នារវាង ប្រព័ន្ធទ្វិកនិយម និងឯកនិយម។ ផងដែរសូមមើលរឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើរបស់ អៀង សារី ប្រឆាំងនឹងលទ្ធភាពនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩, D240 ERN: 00401925-00401940 កថាខណ្ឌ ១៧-២០។

[64] នេះដោយសារតែមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលចែងថា "មិនមានបទឧក្រិដ្ឋណាមួយ អាចត្រូវបានយកមកផ្តន្ទាទោស ដោយការដាក់ទោសបញ្ញត្តិ ដែលមិនត្រូវបានប្រកាសដោយច្បាប់ មុនបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្តឡើងឡើយ"។ (បកប្រែក្រៅផ្លូវការ)។

[65] សូមអាន ឧទាហរណ៍ ដីកាសម្រេច JCE កថាខណ្ឌ ២២។ ក.ស.ច.ស កត់សំគាល់ថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ យកគំរូតាមច្បាប់បារាំង។

បទឧក្រិដ្ឋឡើយ[66]។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Aussaresses*[67] តុលាការកំពូលប្រទេសបារាំង (*Cour de Cassation*) បានតម្កល់សាលដីការបស់តុលាការឧទ្ធរណ៍ទីក្រុងប៉ារីស ដែលថាការផ្តន្ទាទោសឧត្តមសេនីយ៍ Aussaresses ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុង សង្គ្រាមអាល់ហ្សេរី ត្រូវបានហាមឃាត់។ តុលាការនោះចេញសាលដីកាដូច្នេះ ដោយសារក្រមព្រហ្មទណ្ឌដែលមានជាធរមាននៅពេលនោះ មិនមានបទប្បញ្ញត្តិចាត់ទុកឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិថាជាបទល្មើសឡើយ ទោះបីជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានចាត់ទុកថាជាបទល្មើស ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលនោះយ៉ាងណាក៏ដោយ[68]។ "វិធានទំនៀមទម្លាប់អន្តរជាតិមិនអាចជំនួសការដែលមិនមានបទប្បញ្ញត្តិ ដែលចាត់ទុកអំពើថាជាបទល្មើស ដែលត្រូវបានចោទប្រកាន់ដោយដើមបណ្តឹងរដ្ឋប្បវេណី (*partie civile*) ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានឡើយ"[69]។

៣០. វិធីសាស្ត្រស្រដៀងគ្នាមួយ ដែលបដិសេធការអនុវត្តដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានអនុវត្តតាមដោយតុលាការកំពូលហូឡង់ នៅក្នុងរឿងក្តី *Bouterse*[70] ដែលបានចេញសេចក្តីសម្រេចប្រឆាំងនឹងការអនុវត្ត ដោយផ្ទាល់នូវទំនៀមទម្លាប់ជាមូលដ្ឋានសម្រាប់ការផ្តន្ទាទោសព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងតុលាការជាតិរបស់ខ្លួន។ នៅក្នុងសាលដីកានេះ បញ្ជាក់ថា ភាពអាចអនុវត្តទៅបានដោយផ្ទាល់ នឹងមានការប៉ះពាល់ដល់គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (*nullum crimen sine lege*)[71]។ នៅក្នុងការផ្តល់យោបល់ប្រឹក្សាជូនចំពោះតុលាការឧទ្ធរណ៍

---

[66] នេះគឺជាករណីទូទៅនៅក្នុងយុត្តាធិការជាច្រើន។ "ប្រព័ន្ធច្បាប់ជាតិជាច្រើនមិនទទួលយកទំនៀមទម្លាប់ជាប្រភពនៃច្បាប់ព្រហ្មទណ្ឌឡើយ ដោយយល់ឃើញថា ទំនៀមទម្លាប់មិនបានបំពេញនូវលក្ខខណ្ឌនៃភាពជាក់លាក់ និងភាពអាចដឹងជាមុនបាន ដែលមានសារៈសំខាន់ដល់គោលការណ៍នីត្យានុកូលភាព និងប្រសិទ្ធភាពនៃតួនាទីបង្ការនៃច្បាប់ព្រហ្មទណ្ឌ"។ Héctor Olásolo, កំណត់សំគាល់ស្តីពីការវិវត្តន៍នៃគោលការណ៍នីត្យានុកូលភាព នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, 18 CRIM. L. F. 301, 316-17 (2007) ("Olásolo, *Principle of Legality*")។

[67] Cour de Cassation, Chambre Criminelle, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣, *Bull. crim.* 2003 n° 122, ទំព័រ ៤៦៥។

[68] សូមមើល Juliette Lelieur-Fischer, ការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមអាល់ហ្សេរី : ការខិតខំប្រឹងប្រែងដែលមិនអាចទៅរួច? 2 J. INT'L CRIM. JUST. 231 (2004)។

[69] ដូចដើងទំព័រខាងលើ ត្រង់ចំណុច ២៣៦ ដកស្រង់ចេញពីសេចក្តីសម្រេចរបស់តុលាការកំពូលប្រទេសបារាំង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៣។

[70] *In re Bouterse*, HR, Sept. 18, 2001, NJ 559។

[71] Ward N. Ferdinandusse, Direct Application of International Criminal Law in National Courts 69 (T.M.C. Asser Press 2006) ("Ferdinandusse") ។

ទីក្រុង Amsterdam អ្នកជំនាញដែលតែងតាំងដោយតុលាការគឺសាស្ត្រាចារ្យ John Dugard ក៏បានបញ្ជាក់ផងដែរថា ច្បាប់ហូឡង់ “ទំនងជាតម្រូវឱ្យមានលក្ខន្តិកៈជាតិ ដែលប្រែក្លាយកាតព្វកិច្ចតាមច្បាប់អន្តរជាតិ ទៅជាច្បាប់ជាតិ នៅពេលដែលមានការទាក់ទងដល់ការចាត់ទុកអំពើរបស់មនុស្សថាជាបទល្មើស”[72]។ ផ្នែកសំអាងហេតុស្រដៀងគ្នានេះ ត្រូវបានយល់ស្របដោយតុលាការប្រទេសអាឡឺម៉ង់[73] ស្វីស[74] និងបណ្តារដ្ឋផ្សេងៗទៀត[75]។

៣១. វាមិនទំនងឡើយ ដែលថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ អាចត្រូវបានអនុវត្តដោយផ្ទាល់ចំពោះច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ដោយមិនមានបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ប្រកាសអោយប្រើនោះ ពីព្រោះវានឹងរំលោភទៅលើគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង[76]។ Susan Lamb ដែលជាអតីតរដ្ឋអាជ្ញានៅតុលាការ ICTY និងបច្ចុប្បន្ននេះជាអ្នកសម្របសម្រួលផ្នែកតុលាការជាន់ខ្ពស់នៅ អ.វ.ត.ក ធ្វើការពន្យល់ថា “គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង ដែលផ្អែកទៅលើការហាមឃាត់ដែលត្រូវបានសំដែងចេញ និងផ្អែកយ៉ាងច្បាស់ទៅលើតម្លៃនៃភាពជាក់លាក់ផ្លូវច្បាប់ មិនសមស្របជាមួយនឹងលក្ខណៈពិតប្រាកដនៃច្បាប់ទំនៀម

---

[72] សូមមើល *In re Bouterse,* សាលាឧទ្ធរណ៍ទីក្រុង Amsterdam LJN: AA8427, 7 កក្កដា ២000 *កថាខណ្ឌ ៨.២.២ ដកស្រង់ពី* B SWART & A KLIP (EDS), INTERNATIONAL CRIMINAL LAW IN THE NETHERLANDS 27-38 (1997) ។

[73] គោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់អាឡឺម៉ង់ ទំនងជាបដិសេធនូវការអនុវត្តដោយផ្ទាល់ជាទូទៅ នៃបទល្មើសអន្តរជាតិទាំងអស់ មិនថាបទល្មើសទាំងនេះមាននៅក្នុងទំនៀមទម្លាប់ ឬអនុសញ្ញាឡើយ។ FERDINANDUSSE, ត្រង់ចំណុច ៤0។

[74] តុលាការឧទ្ធរណ៍យោធាប្រទេសស្វីស បានសម្រេចក្នុងឆ្នាំ២000 ថា ការប្រែក្លាយទៅជាបទល្មើសព្រហ្មទណ្ឌចំពោះអំពើប្រល័យពូជសាសន៍ ដែលជាច្បាប់ទំនៀមទម្លាប់ មិនអាចត្រូវបានយកមកអនុវត្ត ដោយគ្មានវិធានយោងជាក់លាក់ដែលអនុញ្ញាតឱ្យយកវាមកអនុវត្តនៅពេលដែលអំពើដែលចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងឡើយ។ ដូចជើងទំព័រខាងលើ ត្រង់ចំណុច ៤0-៤១។

[75] សូមមើល Kreicker ត្រង់ចំណុច 320។

[76] “នៅក្នុងបរិបទនៃប្រព័ន្ធច្បាប់ជាតិ ទិដ្ឋភាពសំខាន់នៃគោលការណ៍នីត្យានុកូលភាពក្នុងច្បាប់ព្រហ្មទណ្ឌ និងជាពិសេសការសំដែងចេញយ៉ាងច្បាស់របស់វា បានបញ្ចូលនៅក្នុងគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (*maxims nullum crimen sine lege)* និង គោលការណ៍គ្មានការផ្តន្ទាទោសណាមួយដែលគ្មានច្បាប់ចែងនោះឡើយ (*nulla poena sine lege)* រួមទាំងការការពារជាផ្លូវការបន្ថែមទៀត ដែលអំពើដែលត្រូវបានហាមឃាត់ និងទោសបញ្ញត្តិរបស់វា ត្រូវបានបង្កើតជាមុនដោយបទដ្ឋាន ដែលអាចត្រូវបានគេចាត់ទុកថាជា “ច្បាប់” ជាពាក្យផ្លូវការ ហើយថាអាចត្រូវបានប្រកាសដោយអំណាចនីតិបញ្ញត្តិតែប៉ុណ្ណោះ។ <u>ដូច្នេះ លទ្ធភាពនៃការចាត់ទុកអំពើមួយចំនួនថាជាបទល្មើស ឬការដាក់ទោសបញ្ញត្តិ ដោយផ្អែកលើប្រភពច្បាប់ដែលឥតមានសរសេរទុកជាមុន ដូចជាទំនៀមទម្លាប់ ឬគោលការណ៍ច្បាប់ទូទៅ ដែលផ្តល់នូវការការពារកាន់តែតិចតួច ក្នុងទស្សនៃភាពជាក់លាក់ និងភាពអាចដឹងជាមុនបាន ត្រូវបានបដិសេធចោល</u>”។ Olásolo, *Principle of Legality,* ទំព័រ ៣0២ (សេចក្តីបញ្ជាក់ បន្ថែម)។

ទម្លាប់អន្តរជាតិឡើយ ដែលច្បាប់មិនត្រូវបានចែងទុកជាមុន ហើយជារឿយៗមានការពិបាកក្នុងការកំណត់អត្ថន័យឱ្យបានច្បាស់[77]"។ លោកស្រីក៏បញ្ជាក់ផងដែរថា "គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង សន្មតជាកម្មវត្ថុផ្អែកច្បាប់ឯករាជ្យសមហេតុផល និងជាច្បាប់ដែលគេស្គាល់ ឬត្រូវបានទទួលស្គាល់ : ជាលទ្ធផល ជារឿយៗវាត្រូវបានគេសន្មតថា គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង គឺត្រូវគ្នាតែជាមួយច្បាប់ដែលចែងប៉ុណ្ណោះ[78]"។ ដូចដែលសាស្ត្រាចារ្យ Fletcher និង Ohlin ធ្វើការកត់សំគាល់

> ក្នុងការប្រើទម្លាប់ក្នុងការលើកកំពស់លទ្ធភាពនៃការផ្តន្ទាទោស គឺរំលោភលើការសន្មតជាមុនជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌទំនើប។ "ច្បាប់ទំនៀមទម្លាប់" គឺជាអ្វីមួយដែលគេស្អប់ណាស់ នៅក្នុងតុលាការព្រហ្មទណ្ឌនៃគ្រប់សង្គមទំនើបទាំងអស់។ ហេតុផលសម្រាប់នីតិកម្ម គឺដើម្បីដកទម្លាប់ចេញពីប្រព័ន្ធ និងដើម្បីបង្កើតនូវរបបមួយដែលផ្អែកលើវិធាន និងបទដ្ឋានដែលត្រូវបានប្រកាសជាសាធារណៈជាមុនដោយអាជ្ញាធរដែលមានសមត្ថកិច្ច[79]។

## ២. មិនមានអញ្ញត្រកម្ម ដែលអនុញ្ញាតឱ្យមានការអនុវត្តដោយផ្ទាល់នូវច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះ "ប្រព័ន្ធ"យុត្តាធិការស្វយ័ត ឡើយ

៣២. ក.ស.ច.ស កត់សំគាល់ថា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ យកគំរូតាមច្បាប់បារាំង ហើយនៅក្នុងច្បាប់បារាំងនេះ បទល្មើសអន្តរជាតិ ដូចយ៉ាងបទល្មើសអន្តរជាតិដែលស្ថិតក្នុងសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក គឺជាបទល្មើសដែលមានលក្ខណៈពិសេសស្ថិតនៅក្នុងប្រព័ន្ធយុត្តាធិការស្វយ័ត ដែលផ្សេង

---

[77] Susan Lamb, គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen) គោលការណ៍គ្មានការផ្តន្ទាទោសណាមួយដែលគ្មានច្បាប់ចែងនោះឡើយ (Nulla Poena Sine Lege) នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ, នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ : A COMMENTARY VOL. 1 743 (Oxford University Press, 2002) ("Lamb")។

[78] ដូចដើងទំព័រខាងលើ ត្រង់ចំណុច ៧៤៩ (សេចក្តីបញ្ជាក់បន្ថែម)។

[79] George P. Fletcher & Jens David Ohlin, *Reclaiming Fundamental Principles of Criminal Law in the Darfur Case*, 3 J. INT'L CRIM. JUST. 539, 559 (2005) ("Fletcher & Ohlin, *Reclaiming Fundamental Principles*")។ សូមមើលផងដែរទំព័រ ៥៥៥-៥៦ ត្រង់ចំណុចដែលត្រូវបានលើកឡើងករណីថា ការប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាវិធីមួយក្នុងការបង្កើតការប្រឈមទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌ គឺមិនស្របច្បាប់ឡើយ នៅក្រោមគោលការណ៍នីត្យានុកូលភាព។

ពីច្បាប់ព្រហ្មទណ្ឌជាតិ និងត្រូវបានសំគាល់លក្ខណៈពិសេសដោយវិធានទីតិវិធី និងខ្លឹមសារ[80]"។ ក្នុងខណៈដែលមេធាវីការពារក្តីយល់ស្របជាមួយ ផ្នែកសំអាងហេតុរបស់ ក.ស.ច.ស ដែលថា JCE មិនអាចត្រូវបានយកមកអនុវត្តចំពោះបទល្មើសក្នុងច្បាប់ជាតិកម្ពុជានោះ[81] ទស្សនទាននៃប្រព័ន្ធយុត្តាធិការស្វ័យយ័តនេះ ក្នុងវិធីណាក៏ដោយ មិនអាចត្រូវបានគេប្រើប្រាស់ដើម្បីធ្វើយុត្តិកម្មអំពីការអនុវត្ត JCE ចំពោះបទល្មើសអន្តរជាតិបានឡើយ។

៣៣. ទស្សនាទាននៃប្រព័ន្ធយុត្តាធិការស្វយ័ត គឺគ្រាន់តែជាទស្សនាទាន ទាក់ទិននឹងទ្រឹស្តី ដែលសំដៅទៅលើប្រភេទនៃបទល្មើសនៅក្នុងច្បាប់បារាំង ដែលអាចមានលក្ខណៈពិសេស ដូចជា ១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ២) អំពើភេរវកម្ម ៣) បទល្មើសផ្លូវភេទ និង ៤) បទល្មើសលើពន្ធដារ និងអាករ[82]។ ទស្សនាទាននេះ គឺមិនផ្អែកទៅលើរដ្ឋធម្មនុញ្ញបារាំង ឬបរិបទច្បាប់ណាមួយឡើយ។ លើសពីនេះទៀត ដូចដែលបានពន្យល់ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីខ្លះ ក្នុងចំណោមភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ពួកគេប្រឆាំងនឹងដីកាសម្រេច JCE "នៅក្នុងច្បាប់កម្ពុជា មិនមានប្រព័ន្ធយុត្តាធិការស្វយ័តជាក់លាក់ចំពោះបទឧក្រិដ្ឋទាំងនេះទេ ដូច្នេះ មិនចាំបាច់បង្កើតគោលការណ៍នៃការបកស្រាយច្បាប់ពាក់ព័ន្ធនឹងប្រភេទជាក់លាក់ ផ្អែកតាមកំណត់តាមរយៈប្រពៃណីច្បាប់របស់បារាំងឡើយ"[83]។

៣៤. ទស្សនាទាននៃប្រព័ន្ធយុត្តាធិការស្វយ័ត តាមវិធីណាក៏ដោយ មិនបានផ្តល់ជាយោបល់ថា ការទទួលខុសត្រូវ JCE អាចត្រូវបានអនុវត្តនៅពេលដែលទម្រង់នៃការទទួលខុសត្រូវនោះ មិនមាននៅក្នុងប្រទេសបារាំង ឬប្រទេសកម្ពុជាឡើយ។ ការយោងទៅលើប្រព័ន្ធយុត្តាធិការស្វយ័តគឺជាការធ្វើឱ្យភ័ន្តច្រឡំ។ ប្រភពតែមួយគត់ដែល ក.ស.ច.ស បានយោងទៅលើ នៅពេលដែលខ្លួនបានធ្វើការពិភាក្សាអំពីទស្សនាទាននៃប្រព័ន្ធយុត្តាធិការស្វយ័ត[84] មិនបានបញ្ជាក់ថា លទ្ធផលផ្អែកច្បាប់ណាមួយ អាចត្រូវបានទាញចេញពីអង្គហេតុដែលថា បទឧក្រិដ្ឋជាក់លាក់ ត្រូវបានចាត់ទុកជាផ្នែក

---

[80] ដីកាសម្រេច JCE កថាខណ្ឌ ២២។

[81] ដូចជើងទំព័រខាងលើ។

[82] FREDERIC DESPORTES & FRANCIS LE GUNEHEC, DROIT PENAL GENERAL 117, កថាខណ្ឌ ១៧៤ (2002).

[83] រឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៧) សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចអនុវត្តបាននៃទម្រង់នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១០ D97/17/1, ERN: 00428308-00428315 ("បណ្តឹងឧទ្ធរណ៍ JCE របស់ដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ១១។

[84] FREDERIC DESPORTES & FRANCIS LE GUNEHEC, DROIT PENAL GENERAL (2002).

នៃប្រព័ន្ធយុត្តាធិការស្វយ័តឡើយ។ តាមពិត អត្ថបទដែល ក.ស.ច.ស បានយោងទៅលើនោះ គាំទ្រសេចក្តីសន្និដ្ឋានថា JCE មិនអាចត្រូវបានអនុវត្តនៅ អ.វ.ត.ក ឡើយ។ អត្ថបទនោះពិភាក្សាអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងកត់សំគាល់ថា វាមានលក្ខណៈមិនច្បាស់ឡើយ ថាតើអញ្ញត្រកម្មចំពោះគោលការណ៍មិនប្រតិសកម្ម ដែលមាននៅក្នុងអនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរុប នឹងត្រូវបានអនុវត្តដោយតុលាការបារាំង ឬយ៉ាងណា ដោយយល់ឃើញថា ពួកគេចាត់ទុករដ្ឋធម្មនុញ្ញរបស់របស់ពួកគេមានអធិកភាពទៅលើច្បាប់អន្តរជាតិ[85]។ រឿងក្តី *Aussaresses* ដែលបានពិភាក្សាខាងលើ ដែលត្រូវបានសម្រេចបន្ទាប់ពីសៀវភៅនេះត្រូវបានបោះពុម្ពផ្សាយ បញ្ជាក់យ៉ាងច្បាស់ថា ទោះបីជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចត្រូវបានពិចារណាថាស្ថិតនៅក្រោមប្រព័ន្ធយុត្តាធិការស្វយ័តក៏ដោយ ក៏បុគ្គលនោះមិនអាចត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានឡើយ ដោយគ្មានការយោងទៅលើនីតិកម្មជាតិនោះ។

៣៥. លើសពីនេះទៀត ការយោងទៅលើច្បាប់បារាំង គាំទ្រសេចក្តីសន្និដ្ឋានថា JCE មិនអាចត្រូវបានយកមកអនុវត្តនៅ អ.វ.ត.ក ឡើយតាមវិធីណាក៏ដោយ។ ដូចដែលបានកត់សំគាល់ដោយសាកលវិទ្យាល័យ McGill នៅក្នុងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី បារាំងបានអនុម័តច្បាប់មួយក្នុងឆ្នាំ១៩៤៨ ដែលបានដោះស្រាយនូវបញ្ហានៃការទទួលខុសត្រូវជាលក្ខណៈបុគ្គល នៅក្នុងគម្រោងការ ឬផែនការរួម ប៉ុន្តែបាននិរាករណ៍ច្បាប់នេះក្នុងឆ្នាំ១៩៥៣។ "នៅក្នុងរយៈដ៏ខ្លី ដែលច្បាប់ពិសេសនេះនៅជាធរមាន ច្បាប់នេះគឺជាគោលដៅនៃការរិះគន់យ៉ាងខ្លាំងចំពោះការនាំឱ្យមានការរំលោភគោលការណ៍សិទ្ធិមនុស្សជាសកល ដូចជាគោលការណ៍សច្ចធារណ៍និរទោស នីតិវិធីស្របច្បាប់ និងគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង"[86]។ ប្រសិនបើបារាំង បានបដិសេធការទទួលខុសត្រូវ JCE ក្នុងអំឡុងរយៈពេលដែលត្រូវបានបញ្ជាក់នេះ តើទស្សនាទានច្បាប់បារាំងអាចត្រូវគេយកជាសំអាងបានយ៉ាងដូចម្តេច ក្នុងការគាំទ្រការអនុវត្តការទទួលខុសត្រូវ JCE នៅ អ.វ.ត.ក?

---

[85] ដូចជើងទំព័រខាងលើ ត្រង់ចំណុច១២១-២២។

[86] រឿងក្តី កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ០២) សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ដែលបានដាក់ជូនដោយ មជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់ នៃសកលវិទ្យាល័យ McGill University ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ D99/3/25, ERN: 00234856-00234883 ("សារណារបស់សកលវិទ្យាល័យ McGill Brief") កថាខណ្ឌ ២៧។

## គ. ក.ស.ច.ស មានវិការៈក្នុងការទទួលស្គាល់ថា ទម្រង់ទាំងបីនៃការទទួលខុសត្រូវ JCE ដូចដែលត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* អាចត្រូវបានចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥-៧៩

### ១. អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* បានកំណត់ដោយមិនត្រឹមត្រូវថាការទទួលខុសត្រូវ JCE មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

៣៦. ក.ស.ច.ស បានកត់សំគាល់យ៉ាងត្រឹមត្រូវថា មាត្រា២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មិនបានចែងអំពីការទទួលខុសត្រូវ JCE ឡើយ[87]។ បន្ទាប់មក ក.ស.ច.ស បានបញ្ជាក់ថា "JCE គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការប្រព្រឹត្ត នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍លើរឿងក្តី *Tadić* នៅតុលាការ ICTY..."[88]។ ការទទួលស្គាល់របស់ ក.ស.ច.ស ទៅលើការបង្កើតនូវការទទួលខុសត្រូវ JCE របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* និងការមិនផ្តល់នូវសេចក្តីពន្យល់ណាមួយ ថាហេតុអ្វីបានជាខ្លួនទទួលស្គាល់ការបង្កើតនេះ គឺជាវិការៈដ៏ច្បាស់ក្រឡែត។ វិវាទកម្ម[89] ជុំវិញឋានៈនៃការទទួលខុសត្រូវ JCE នៅក្នុងច្បាប់ទំនៀម

[87] ដីកាសម្រេច JCE កថាខណ្ឌ ១៣។

[88] ដូចជើងទំព័រខាងលើ។

[89] សូមមើល ឧទាហរណ៍ Ciara Damgaard, ទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម*: A "Monster Theory of Liability" or a Legitimate and Satisfactory Tool in the Prosecution of the Perpetrators of Core International Crimes?, in* INDIVIDUAL CRIMINAL RESPONSIBILITY FOR CORE INTERNATIONAL CRIMES 129 (Springer, 2008) ("Damgaard"). "ទ្រឹស្តីនេះ លើកនូវក្តីព្រួយបារម្ភយ៉ាងខ្លាំងមួយចំនួន។ ក្នុងចំណោមប្រការផ្សេងទៀត វាមានលក្ខណៈមិនច្បាស់លាស់ ធ្វើឱ្យចុះខ្សោយនូវបទដ្ឋានបង្ហាញភស្តុតាង ប៉ះពាល់ដល់គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដោយគាំទ្រការទទួលខុសត្រូវជារួម រំលោភទៅលើគោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង និងរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះទោសដោយយុត្តិធម៌" Mohamed Elewa Badar, *"Just Convict Everyone!" – Joint Perpetration: From* Tadić *to* Stakić *and Back Again*, 6 INT'L CRIM. L. REV. 293, 301 (2006): "ប្រភពសំខាន់នៃការព្រួយបារម្ភ ទាក់ទិនទៅនឹងភាពអាចអនុវត្តបាននៃ JCE ទម្រង់ទី III នៅក្នុងអំណាចនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺថា ស្ថិតនៅក្រោមទាំងបទដ្ឋានអត្តនោម័ត និងសត្យានុម័ត អ្នកចូលរួមត្រូវទទួលខុសត្រូវដោយមិនមានយុត្តិធម៌ ចំពោះអំពើឧក្រិដ្ឋដែលគាត់មិនមានចេតនា និងមិនបានចូលរួមក្នុងអំពើនោះ" ។ William A. Schabas, ចេតនាប្រព្រឹត្តបទល្មើស និងតុលាការព្រហ្មទណ្ឌអន្តជាតិសម្រាប់អតីតយូហ្គោស្លាវី, 37 NEW ENGLAND L. REV. 1015, 1033-34: "ផ្តល់នូវវិធីសាស្ត្រពីរនេះ [JCE និងការទទួលខុសត្រូវក្នុងការបញ្ជា] ជួយសម្រួលដល់ការកាត់ទោសជនល្មើសម្នាក់ដែល ទំនងជាបានចូលរួមនៅក្នុងការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ។ ប៉ុន្តែ វិធីសាស្ត្រទាំងនេះបានធ្វើឱ្យមានការបន្ធូរបន្ថយទោស ដែលកាត់បន្ថយដែលមិន

ទម្លាប់អន្តរជាតិ និងការពិតដែលថា ការទទួលខុសត្រូវ JCE មិនត្រូវបានចែងឱ្យបានច្បាស់នៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនោះ តម្រូវឱ្យមានការពិនិត្យឋានៈ របស់វានេះឡើងវិញ។ ដូច្នេះ វាគួរតែមិនមានការភ្ញាក់ផ្អើលឡើយ ដែលសហព្រះរាជអាជ្ញាអន្តរជាតិថ្មី Andrew Cayley នៅក្នុងរឿងក្តីពីរដែលគាត់បានចូលប្រឡូក ក្នុងនាមជាមេធាវីការពារក្តី (*Taylor* នៅចំពោះមុខតុលាការ SCSL និង *Gotovina et al.*[90] នៅចំពោះមុខតុលាការ ICTY), JCE ត្រូវបានជំទាស់តវ៉ាយ៉ាងខ្លាំងថាជាទម្រង់ស្របច្បាប់នៃការទទួលខុសត្រូវ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២ ក៏បានជំទាស់ផងដែរថា JCE មិនគួរអនុវត្តឡើយ[91]។

៣៧. អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី *Tadić* យល់ឃើញថា ការទទួលខុសត្រូវ JCE ត្រូវបានកំណត់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[92]។ សេចក្តីសន្និដ្ឋានមិនត្រឹមត្រូវនេះ បានធ្វើឱ្យមានការទទួល

---

អាចចៀសវាងបាននូវសារៈសំខាន់ជាឧបទេសនៃសេចក្តីសម្រេចរបស់តុលាការ និងដែលប៉ះពាល់ដល់កេរ្តិ៍ណែលប្រវត្តសាស្ត្ររបស់ខ្លួន"។

[90] សូមមើលរដ្ឋអាជ្ញា ទល់នឹង *Gotovina et al.*, IT-06-90-PT, ញត្តិបឋមរបស់ជនត្រូវចោទ Ante Gotovina ប្រឆាំងនិងយុត្តាធិការ អនុលោមតាមវិធាន ៧២ (ក)(ឈ) នៃវិធាននៃនីតិវិធី និងភស្តុតាង ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧។ រដ្ឋអាជ្ញា ទល់នឹង *Čermak & Markač*, IT-03-73-PT, ញត្តិបឋមរបស់ Mladen Markač ស្តីពីវិការៈនៅក្នុងទម្រង់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៤។ រដ្ឋអាជ្ញា ទល់នឹង Taylor, SCSL-03-1-T, សេចក្តីសម្រេចទៅលើញត្តិបន្ទាន់ ទាក់ទិនទៅនឹងវិការៈដ៏ធ្ងន់ធ្ងរ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានធ្វើវិសោធនកម្ម លើកទីពីររបស់រដ្ឋអាជ្ញា ទាក់ទងនឹងសារណាអំពី JCE ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩។ នៅក្នុងករណីទាំងពីរនេះ លោក Cayley បំពេញតួនាទីជាសហមេធាវីធ្វើកំណត់ហេតុ សម្រាប់លោក Čermak នៅតុលាការ ICTY និងសម្រាប់លោក Taylor នៅតុលាការ SCSL។

[91] សូមមើលរឿងក្តី អៀង សារី ០០២/១៩-០៩-២០០៧-អវតក/កសចស ចម្លើយតបរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ D97/3/4, ERN: 00268488-00268498។ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ០២) ចម្លើយតបរបស់សហមេធាវីបរទេសតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ D99/3/32, ERN: 00239077-00239087។ រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក/អជសជ ប្រតិចារិកនៃដំណើរការជំនុំជម្រះទោស - កាំង ហ្គេកអ៊ាវ "ឌុច" ជាសាធារណៈ - ត្រូវបានពិនិត្យឡើងវិញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ E1/78.1, ទំព័រ 5, l. 25 – ទំព័រ 6, l. 9។

[92] សម្រាប់ការពិភាក្សាមួយលើបញ្ហាយន្តការណ៍របស់តុលាការតុលាការកំពូលរឿងក្តី *Tadić* ក្នុងការវាយតម្លៃអត្ថិភាពនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ *សូមមើល* ឯកសាររបស់ Vladimir-Djuro Degan ស្តីពី *ប្រភពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* ចេញផ្សាយក្នុងលេខ ៤(១) ដោយព្រឹត្តិបត្តិចិនស្តីពីច្បាប់អន្តរជាតិ លេខ៤៥ ទំព័រ៧៧-៧៨ (ឆ្នាំ២០០៥) ("Degan") ក្នុងឯកសារនេះសាស្ត្រាចារ្យ Degan ពន្យល់ថា Antonio Cassese ដែលជាចៅក្រមប្រធាននៅអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី

ស្គាល់នៅតុលាការ ICTY និងតុលាការ ICTR (ដែល ដោយចៃដន្យ ប្រើប្រាស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ដូចគ្នា) ដោយគ្មានការវិភាគឯករាជ្យបន្ថែមណាមួយឡើយ[93] ទោះបីជាមានការរិះគន់យ៉ាងខ្លាំង និងទោះបីជាអង្គជំនុំជម្រះតុលាការកំពូលរឿងក្តី *Tadić* បានធ្វើការសម្រេចរបស់ខ្លួនទៅលើបញ្ហានៃឋានៈទំនៀមទម្លាប់នៃការទទួលខុសត្រូវ JCE ដោយគ្មានគុណប្រយោជន៍នៃទឡ្ហីករណ៍សំអាងហេតុពីរដ្ឋអាជ្ញា និងមេធាវីការពារក្តីឡើយ – មេធាវីការពារក្តី *Tadić* មិនបានជំទាស់តវ៉ាទៅលើការអនុវត្តការទទួលខុសត្រូវ JCE ឡើយ[94]។ អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី *Tadić*

---

*Tadić* គឺជា "ជើងឯកមួយរូបក្នុងចំណោមជើងឯកដទៃទៀតនៃ 'ច្បាប់បង្កើតដោយចៅក្រម'"។ សាស្ត្រាចារ្យ Degan រិះគន់ខ្លាំងណាស់ដែរចំពោះយុទ្ធសាស្ត្ររបស់ចៅក្រម Cassese ក្នុងការវាយតម្លៃអត្ថិភាពនៃច្បាប់ទំនៀមទំលាប់អន្តរជាតិ។ លោកសាស្ត្រាចារ្យពន្យល់ពីបញ្ហាមួយចំនួននៃយុទ្ធសាស្ត្ររបស់ចៅក្រម Cassese ហើយចុងបញ្ចប់គាត់ដាស់តឿនថា "ទីបំផុតយើងត្រូវតែបញ្ជាក់ឲ្យច្បាស់ថាសេចក្តីថ្លែងធម្មតានៅក្នុងដីកាសម្រេចរបស់តុលាការ គួរតែត្រូវបានចាត់ទុកគ្រាន់ជាច្បាប់ទំនៀមទម្លាប់ដែលកំពុងវិវត្តន៍ឡើងតែប៉ុណ្ណោះ ដែលមិនមែនជាវិធានច្បាប់អនុម័តនិងប្រកាសឲ្យប្រើប្រាស់នោះទេ"។ សេចក្តីថ្លែងទាំងនេះអាចក្លាយទៅជាច្បាប់ទំនៀមទម្លាប់ពិសេសក្រោយមកទៀត ប្រសិនបើរដ្ឋភាគច្រើនអនុវត្តសេចក្តីថ្លែងទាំងនោះជាក់ស្តែងជាមួយគ្នានឹងសច្ចាធារណ៍ធម្មានុរូបនៃអំពើ *opinio juris* ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ជាទូទៅដំណើរការបង្កើតច្បាប់នេះមិនសមប្រកបសម្រាប់តុលាការព្រហ្មទណ្ឌនោះទេ ពីព្រោះតែហានិភ័យក្នុងការដាក់ទោសដល់ជនជាប់ចោទចំពោះអំពើមួយចំនួន ដែលមិនមែនជាអំពើព្រហ្មទណ្ឌនៅពេលដែលអំពើទាំងនោះត្រូវបានប្រព្រឹត្ត"។

93 ដូចដែរសាស្ត្រាចារ្យ Olásolo បានគត់សម្គាល់ "បន្ទាប់ពីរឿងក្តី *Tadić* អង្គជំនុំជម្រះតុលាការកំពូលនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និង រ្វ៉ាន់ដា បានពិភាក្សាទៅលើតែខ្លឹមសារជាក់លាក់របស់ធាតុផ្សំមួយចំនួននៃទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋរួម និងកម្រិតនៃភាពជាក់លាក់ដែលតម្រូវឲ្យមាននៅក្នុងសារណារបស់ពួកគាត់ តែប៉ុណ្ណោះ។ ប៉ុន្តែ <u>អង្គជំនុំជម្រះតុលាការកំពូលទាំងនេះមិនដែលបានពិនិត្យឡើងវិញលើតម្លៃនៃការវិភាគនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍លើរឿងក្តី *Tadić* នោះទេ</u>។ ឯកសាររបស់ HÉCTOR OLÁSOLO ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មេដឹកនាំនយោបាយនិងយោធាជាន់ខ្ពស់ ជាគោលការណ៍សម្រាប់បទល្មើសអន្តរជាតិ ៤៩ (រោងពុម្ព HART ឆ្នាំ២០០៩) (គូសបញ្ជាក់បន្ថែម)។

94 "ជាការសោកស្តាយណាស់ដែលអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Ojdanić* បដិសេធមិនស៊ើរើសេចក្តីសម្រេចលើរឿងក្តី *Tadić* ។ នៅក្នុងរឿងក្តី *Tadić* ដែលមិនដូចរឿងក្តី *Ojdanić* មេធាវីការពារក្តីមិនបានជំទាស់អត្ថិភាពនៃទំនួលខុសត្រូវលើសហកម្មឧក្រិដ្ឋកម្មរួម ឬអត្ថិភាពរបស់ទំនួលខុសត្រូវនេះនៅក្នុងមាត្រា ៧(១) នៃលក្ខន្តិកៈ នោះទេ។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* មិនបានទទួលផលប្រយោជន៍ពីទឡ្ហីករណ៍ពីរដ្ឋអាជ្ញា និងមេធាវីការពារក្តី ទាក់ទិននឹងឋានៈនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ ការពិនិត្យឲ្យច្បាស់ជាងនេះទៅលើអត្ថបទយោងនិងការអនុវត្តដែលយោងនៅក្នុងរឿងក្តី *Tadić* ដែលបង្កើតឲ្យមានបទដ្ឋានទំនៀមទម្លាប់នៃច្បាប់អន្តរជាតិទាក់ទងទៅនឹងទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលជាទម្រង់ពង្រីកនោះ បង្ហាញឲ្យឃើញថាការទទួលយកទម្រង់ទទួលខុសត្រូវបែបនេះនៅមានកម្រិត"។ ឯកសារលោក Steven Powles ស្តីពី *សហកម្មឧក្រិដ្ឋកម្មរួម៖ ទំនួលខុសត្រូវព្រហ្មទណ្ឌដោយជំនាញកាត់សេចក្តីនិងគំនិតច្នៃប្រឌិតយុត្តិធម៌?* លេខ២ ព្រឹត្តិបត្តស្តីពីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ទំព័រ៦០៦ ទំព័រ៦១៥ (ឆ្នាំ២០០៤) ("Powles")។

បានចូលរួមនៅក្នុងការពិនិត្យដែលមិនគួរឱ្យជឿជាក់បាន អំពីថាតើការទទួលខុសត្រូវ JCE អាចត្រូវបានពិចារណាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬយ៉ាងណា នៅពេលដែលអង្គជំនុំជម្រះនេះបានផ្អែកលើ ១) រឿងក្តីមានចំនួនតិចតួចបំផុត[95] និង ២) សន្ធិសញ្ញា ដែលអង្គជំនុំជម្រះនេះបានផ្អែកទៅលើនោះ តាមពិតមិនបានផ្តល់នូវការគាំទ្រចំពោះការទទួលខុសត្រូវ JCE ដូចដែលបានអះអាងឡើយ។

### ក) អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី *Tadić* បានផ្អែកលើរឿងក្តីមានចំនួនតិចតួចបំផុត

៣៨. ទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានកំណត់ត្រឹមតែ ទាក់ទិនទៅនឹងការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូលំទូលាយស៊ីសង្វាក់គ្នា និង សច្ចាធារណ៍ធម្មានុរូបនៃអំពើ *opinio juris* ដើម្បីបង្កើតនូវទម្រង់ទី១ នៃ JCE យ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី *Tadić* បានផ្អែកលើរឿងក្តីតែប្រាំមួយប៉ុណ្ណោះ[96] រឿងក្តីអង់គ្លេសបួនករណី រឿងក្តីកាណាដាមួយករណី

---

[95] "អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានប្រកាន់យកទស្សនៈដែលថា "ទស្សនទាននៃផែនការរួមដែលជាទម្រង់មួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសមគំនិត ត្រូវបានបង្កើតឡើងយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ សេចក្តីសន្និដ្ឋាននេះហាក់ដូចជាមិនត្រឹមត្រូវសោះ។ អ្វីដែលអាចចោទសួរបាននោះគឺថា តើយើងអាចលើកឡើងថាគោលការណ៍ទូទៅមួយនេះនៃច្បាប់ព្រហ្មទណ្ឌគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានដែរឬទេដោយផ្អែកលើតែរឿងក្តីពីរឬបីករណីតែប៉ុណ្ណោះនោះ"។ ឯកសាររបស់ MACHTELD BOOT ស្តីពីគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ និងស្តីពីបញ្ហាយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម កថាខណ្ឌទី ២៧៤ (Intersentia ឆ្នាំ២០០២)។ *សូមមើលឯកសារដដែលនេះ* ទំព័រ ២៨២ ដែល Boot បានលើកឡើងថា "ការអង្កេតទាំងអស់នេះអាចឱ្យធ្វើការសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូលបានរំលោភលើគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង នៅក្នុងរឿងក្តីនេះ"។ *សូមអានឯកសាររបស់* Lamb នៅទំព័រ ៧៤៦ ដែលគាត់បានលើឡើងថា "ការអនុវត្តរបស់រដ្ឋដែលមានគ្រប់គ្រាន់ដើម្បីណែនាំតុលាការពិសេសៗ បានបញ្ជាក់ថានិយមន័យនៃបទល្មើសអន្តរជាតិផ្តល់ឱ្យដោយតុលាការពិសេសនោះ គឺធ្វើឡើងទៅតាមអារម្មណ៍ ដែលនេះគឺជាគុណតម្លៃមួយហៅថា ច្បាប់ដែលមិនទាន់ចូលជាធរមាន"។ សម្រាប់ការពិភាក្សាពេញលេញជាងនេះទៅលើរឿងក្តីដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ផ្អែកលើនោះ និងភាពមិនគ្រប់គ្រាន់ដើម្បីគាំទ្រទម្រង់សហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ សូមមើលឧបសម្ព័ន្ធ "ក" ផ្នែក II "ឃ" (១)(ខ)។

[96] រឿងក្តីពីរបីទៀតមិនត្រូវបានធ្វើការវិភាគទេ ប៉ុន្តែត្រូវបានលើកឡើងជាសង្ខេបនៅក្នុងជើងទំព័រដោយពិភាក្សាទៅលើ រឿងក្តីទាំង ៦ នេះ។

និងរឿងក្តីអាមេរិកមួយករណី[97]។ យោងទៅលើអ្នកស្រាវជ្រាវជំនាញខ្លះបានឲ្យដឹងថា នេះ "ប្រហែលជាលក្ខណៈពិសេសដ៏គួរឲ្យព្រួយបារម្ភបំផុតនៃការវិភាគ រឿងក្តី *Tadić*"[98]។ ដូចដែលសាស្ត្រាចារ្យ Ambos បានកត់សំគាល់ "<u>ដំណោះស្រាយនៃរឿងក្តី *Tadić* ចំពោះច្បាប់យុត្តិសាស្ត្រសង្គ្រាមលោកលើកទី II យ៉ាងហោចណាស់មាន 'តម្លៃដែល អនុវត្តពីមុនមកមិនច្បាស់'</u>[99]។

៣៩. ដើម្បីបង្កើតនូវទម្រង់ទី២ នៃ JCE អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *Tadić* បានផ្អែកលើតែរឿងក្តីអង់គ្លេសមួយករណី និងរឿងក្តីអាមេរិកមួយករណីប៉ុណ្ណោះ[100]។ នេះមិនមែនជាការចង្អុលបង្ហាញនូវឋានៈទំនៀមទម្លាប់នៃការទទួលខុសត្រូវ JCE ឡើយ – ចំនួននៃរឿងក្តី និងយុត្តាធិការដែលត្រូវបានពិនិត្យ ដោយមិនលើកឡើងអំពីការដកច្បាប់យុត្តិសាស្ត្រទាំងស្រុងចេញពីយុត្តាធិការប្រព័ន្ធច្បាប់ Civil Law គឺមានចំនួនតិចតួចណាស់ដើម្បីបង្កើតនូវការអនុវត្ត

---

[97] *សូមមើលរឿងក្តី Prosecutor តតល់ជាមួយ Tadić* ឯកសារលេខ IT-94-1-A ដែលជាសាលដីកា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ (ហៅថា "សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី*Tadić*") កថាខណ្ឌ ១៩០-២00។

[98] ឯកសាររបស់ GIDEON BOAS និងអ្នកដទៃទៀត បណ្ណាល័យអ្នកអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិ លេខ១៖ ទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ២១ (បោះពុម្ពផ្សាយដោយសកលវិទ្យាល័យ Cambridge ឆ្នាំ២00៧) ("BOAS")។ *សូមអានផងដែរ* ឯកសាររបស់ Attila Bogdan ស្តីពី *ទំនួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលក្នុងការអនុវត្ត "សហកម្មឧក្រិដ្ឋកម្មរួម" នៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី* លេខ៦ ផ្សាយក្នុងព្រឹត្តិបត្តិច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ៦៣ ទំព័រ ១០៩-១១២ (ឆ្នាំ២00៦) ("Bogdan")។

[99] រឿងក្តីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" លេខ 00១/១៨.0៧.២00៧.អវតក.កសចស (អបជ 0២) ឯកសារអ្នកមិនមែនជាភាគីក្នុងរឿងក្តីទាក់ទិននឹងសំណុំរឿងព្រហ្មទណ្ឌលេខ 00១/១៨.0៧.២00៧.អវតក.កសចស (អបជ 0២) ថ្ងៃទី២៧ ខែតុលា ឆ្នាំ២00៨ ឯកសារលេខ D99/3/27 ERN: 00234912-00234942 ("សារណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តី") ទំព័រ ២៣។

[100] សូមមើល សាលដីកាលើបណ្តឹឧទ្ធរណ៍របស់ *Tadić* កថាខណ្ឌទី ២0២។ រឿងក្តីមួយផ្សេងទៀតត្រូវបានលើឡើងនៅក្នុងជើងទំព័រ ប៉ុន្តែសូម្បីតែសារណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តីដែលបានដាក់ជូនមកដោយសកលវិទ្យាល័យ McGill ក៏កត់សម្គាល់ថា "រឿងក្តីចុងក្រោយនៅ ICTY ដែលត្រូវបានយោងដើម្បីគាំទ្រការអនុវត្ត JCE ទម្រង់២ ការពិតគឺគាំទ្រការអនុវត្តគោលការណ៍ជួយនិងជម្រុញច្រើនជាង។ ដូច្នេះ *Mulka* គួរតែត្រូវបានគេបែងចែងចេញឲ្យច្បាស់ដោយបណ្តាតុលាការនាពេលអនាគត ពីព្រោះ ដូចដែល ICTY ទទួលស្គាល់រួចហើយនោះ "ប្រសិនបើមិនអាចបង្ហាញថា ជនជាប់ចោទពិតជាមានគោលបំណងរួមជាមួយរបប ណាស៊ី (Nazi) ទេនោះ តុលាការនឹងត្រូវចាត់ទុករូបគាត់ថាជាអ្នកជួយនិងជម្រុញ ពីព្រោះគាត់មិនមានបំណងជាក់លាក់ដើម្បី "ចង់ឲ្យបទល្មើសនោះជាបទល្មើសរបស់គាត់" នោះទេ។ សារណារបស់ McGill កថាខណ្ឌទី ២២។

របស់រដ្ឋដែលមានលក្ខណៈទូទៅ និងស៊ីសង្វាក់គ្នានោះ[101]។ "សាលដីកានេះ ផងដែរក៏មិនបានធ្វើការពិនិត្យលើ សច្ចាធារណ៍ធម្មានុរូបនៃអំពើ *opinio juris* ដែល 'គោលនយោបាយ និងសេចក្តីប្រកាសជាសាធារណៈរបស់រដ្ឋនានា ជាការសំដែងចេញនៃការប្តេជ្ញាចិត្តនៃជាតិរបស់ពួកគេឡើយ"[102]។

៤០. ការវិភាគទាក់ទិននឹងទម្រង់ទី៣នៃ JCE គឺរឹងរឹតតែមានភាពគួរឲ្យមន្ទិលសង្ស័យ និងភ័ន្តច្រឡំថែមទៀត[103]។ អង្គជំនុំជម្រះតុលាការកំពូល *Tadić* បានសំអាងមួយផ្នែកធំទៅលើសេចក្តីសម្រេចដែលពុំត្រូវបានគេបោះពុម្ពផ្សាយមួយចំនួន ដែលមួយភាគធំមានប្រភពចេញមកពីប្រទេសអ៊ីតាលី[104]។ "ការពឹងផ្អែកទៅលើសេចក្តីសម្រេច "ដែលពុំត្រូវបានបោះពុម្ពផ្សាយ" និង "ដែលសរសេរដោយដៃ" នេះ បង្កឲ្យមានកង្វល់ជាពិសេសក្នុងពេលពិចារណាឃើញថា អង្គជំនុំជម្រះតុលាការកំពូលបានចូលរួមក្នុងការកំណត់ និងការតាក់តែងទស្សនទានមួយដែលខ្លួនបានសន្និដ្ឋានថា "មានមូលដ្ឋានរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[105]"។ ទោះបីជាក្នុងកាលៈទេសៈណាក្តី គេពុំ

---

[101] បញ្ហាមួយទៀតជាមួយនឹងការសំអាងរបស់អង្គជំនុំជម្រះតុលាការកំពូលរឿងក្តី Tadic ទៅលើករណីទាំងនេះ គឺថាករណីដែលត្រូវបានកាត់ក្តីអនុលោមតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ (CCL) លេខ.១០ "មិនអាចត្រូវបានចាត់ទុកជាផ្នែកនៃច្បាប់អន្តរជាតិឡើយ ដោយសារវាត្រូវបានអនុម័តដោយអង្គការនីតិបញ្ញត្តិនៅប្រទេសអាឡឺម៉ង់ (ក្រុមប្រឹក្សាត្រួតពិនិត្យសម្ព័ន្ធមិត្ត)។ ជាលទ្ធផល សេចក្តីសម្រេច ដែលត្រូវបានចេញ ដោយផ្អែកទៅលើ CCL លេខ.១០ <u>មិនបានបង្កើតជាច្បាប់យុត្តិសាស្ត្រអន្តរជាតិដែលមានសុពលភាពឡើយ</u> ហើយ "គោលការណ៍នៃការចូលរួមក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ" ដែលត្រូវបានប្រកាសនៅពេលសវនាការទាំងនេះ "មិនមានសុពលភាពទៀតឡើយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ"" Bogdan ត្រង់ចំណុច ១០០។

[102] ដូចដើងទំព័រខាងលើ ត្រង់ចំណុច ១១០។

[103] មើល ALEXANDER ZAHAR & GÖRAN SLUITER, INTERNATIONAL CRIMINAL LAW (Oxford University Press, 2008) ត្រង់ចំណុចដែលមន្ត្រីច្បាប់តុលាការ ICTY ឈ្មោះ Alexander Zahar និង សាស្ត្រាចារ្យ Göran Sluiter ពិភាក្សាអំពីភាពចាំបាច់ក្នុងការកំណត់អំពីទម្លាប់អនុវត្តន៍ជាទូទៅ និងប្រកបដោយសង្គតិភាពរបស់រដ្ឋ និងដើម្បីកំណត់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងកត់សម្គាល់ថា "ចៅក្រម Cassese បានជីកគាស់សំណុំរឿងក្តីតូចតាចនៅអ៊ីតាលី ដែលទាក់ទិននឹងសង្គ្រាម។ …ឧបសគ្គរាំងស្ទះខាងភាសា និងវប្បធម៌ និងការពុំអាចត្រួតពិនិត្យសម្ភារៈបានសេចក្តីថាការធ្វើអង្កេតស្តីពីទម្លាប់អនុវត្តន៍របស់រដ្ឋមានលក្ខណៈរើសអើង"។

[104] មើលសាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២១៤-២១៧។

[105] Bogdan ត្រង់ ១១០-១១ សូមមើលផងដែរ Shane Darcy, *Imputed Criminal Liability and the Goals of International Justice*, 20 LEIDEN J. INT'L L. 377, 384-85 (2007) ("Darcy") (មានបន្ថែមការសង្កត់ន័យ)៖ "មានការគាំទ្រ<u>មួយចំនួន</u> ក្នុងយុត្តិសាស្ត្រនានាក្រោយសម័យសង្គ្រាមចំពោះប្រភេទមូលដ្ឋាននៃការទទួលខុសត្រូវតាមទម្រង់សហកម្ម

អាចយកសេចក្ដីសម្រេចទាំងនេះមកប្រើប្រាស់ ដើម្បីគាំទ្រដល់អំណះអំណាងថាច្បាប់ទំនៀមទម្លាប់អន្តរជាតិបានគាំទ្រឲ្យមានការទទួលខុសត្រូវចំពោះ JCE បានឡើយ។ ប្រទេសអ៊ីតាលីបានប្រើប្រាស់ប្រព័ន្ធមួយ ដែលក្នុងនោះជនណាដែលជួយធ្វើអន្តរាគមន៍ក្នុងការប្រព្រឹត្តិបទល្មើស

---

ឧក្រិដ្ឋកម្មរួមដែលត្រូវ បានកំណត់ដោយតុលាការ ICTY។ ប៉ុន្តែសម្រាប់ JCE ប្រភេទទី៣ អង្គជំនុំជម្រះតុលាការកំពូល បានសំអាងលើសេចក្ដីសម្រេច របស់តុលាការអ៊ីតាលីមួយចំនួនតូច និងការជំនុំជម្រះក្ដីមួយចំនួនតូច នៅចំពោះមុខតុលាការ យោធាសម្ព័ន្ធមិត្ត ដែលភាគច្រើនទាក់ទិននឹងអំពើហិង្សាដោយហ្វូងមនុស្ស ដែលផ្អែកការសំអាងតាមគោលការណ៍នេះ។ គេពុំទាន់ប្រាកដនៅឡើយថាតើការប្រើប្រាស់ទម្រង់ពន្លាតនៃការទទួលខុសត្រូវចំពោះផែនការរួម ដោយរដ្ឋមួយចំនួនតូចនេះ វាបានផ្ដល់ឋានៈជាច្បាប់ទំនៀមទម្លាប់ ឲ្យទៅគោលការណ៍ការទទួលខុសត្រូវតាមទម្រង់ JCE III ដែរឬយ៉ាងណានោះទេ ជាពិសេសដោយគេយល់ឃើញថាគ្មានសន្និសញ្ញាណាមួយដែលគេបានប្រើប្រាស់កាលសម័យក្រោយសង្គ្រាមនោះ បានទទួលស្គាល់ទស្សនទាននៃការទទួលខុសត្រូវតាមទម្រង់ JCE III នេះឡើយ។ អង្គជំនុំជម្រះតុលាការកំពូលយល់ថាមានការគាំទ្រតិចតួចចំពោះ JCE ប្រភេទទី៣ ប៉ុន្តែ បានកត់សម្គាល់ឃើញថាប្រព័ន្ធគតិយុត្តិភាគច្រើន ពុំចាត់ទុកសញ្ញាណនេះ ដូចៗគ្នាឡើយ។ អ្នកតិទៀនបានលើកអំណះអំណាងថាយុត្តិសាស្ត្រមួយចំនួនធំពុំគាំទ្រដល់ការទទួលខុសត្រូវចំពោះបទល្មើស ដែលពុំស្ថិតនៅក្នុងវិសាលភាពនៃគោលបំណងរបស់ជនទាំងនោះដែលចូលរួមក្នុងផែនការឧក្រិដ្ឋរួមឡើយ"។ មើលផងដែរ Powles ត្រង់ ៦១៥-១៦។ "គេបានអះអាងថាបញ្ជីសំអាងផ្លូវច្បាប់ដែលបានលើកយកជាមកធ្វើជាសំអាងនៅក្នុងរឿងក្ដី*Tadić* ផ្ដល់ការគាំទ្រតិចតួចប៉ុណ្ណោះ ទៅដល់ការទទួលខុសត្រូវបទល្មើសអនុលោមតាមប្រភេទទី៣ ឬទម្រង់ពង្រីកនៃសហកម្មឧក្រិដ្ឋកម្មរួម។ អង្គជំនុំជម្រះតុលាការកំពូលបានសំអាងជាសំខាន់លើរឿងក្ដី២នៅក្រោយសម័យសង្គ្រាមលោកលើកទី២ *Essen Lynching* and *Borkum Island* ។ គេបានអះអាងថារឿងក្ដីទាំង២នោះ ពិតជាគាំទ្រដល់ការទទួលខុសត្រូវតាម ទម្រង់សហកម្មឧក្រិដ្ឋកម្មរួមឡើយ។ នៅក្នុងរឿងក្ដី *Essen Lynching* មនុស្សមួយហ្វូងបានរួមគ្នាវាយដំអាកាសយានិក៣រូប រហូតដល់ស្លាប់។ គេពុំអាចកំណត់ថាតើនរណាវាយសម្លាប់ពិតប្រាកដបានឡើយក្នុងករណីនីមួយៗ"។ Powles បានពន្យល់ថា តាមគំនិតរបស់គាត់ រឿងក្ដី *Essen Lynching* ពិតជាពុំអាចគាំទ្រសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្ដី *Tadić* ដែលថាជនជាប់ចោទនីមួយៗមានទោសពីបទមនុស្សឃាតដោយហេតុថាពួកគេម្នាក់ៗជាប់ពាក់ព័ន្ធក្នុងការសម្លាប់មនុស្ស។ "តាមការកត់សម្គាល់នៃអង្គជំនុំជម្រះតុលាការកំពូល ភាគីអយ្យការនៅក្នុងរឿងក្ដី *Essen Lynching* បានគូសបញ្ជាក់ថាប្រសិនបើជនជាប់ចោទមានចេតនាសម្លាប់មនុស្ស នោះពួកគេនឹងមានទោសពីបទឃាតកម្មគិតទុកជាមុន។ ប្រសិនបើពួកគេគ្មានចេតនានេះទេ ពួកគេនឹងត្រូវផ្ដន្ទាទោសពីបទមនុស្សឃាត។ ជនជាប់ចោទត្រូវបានតុលាការផ្ដន្ទាទោសពីបទឃាតកម្មគិតទុកជាមុន ដោយនេះមានន័យថាតុលាការបានសន្និដ្ឋានថាពួកគេទាំងនោះពិតជាមានចេតនាសម្លាប់អាកាសយានិកទាំង៣នាក់នោះមែន។ ដូច្នេះ ប្រហែលជាមានសញ្ញាសួរអំពីថាតើតុលាការនៅក្នុងរឿងក្ដី *Essen Lynching* ពិតជាសម្រេចឲ្យជនដែលពុំមានចេតនាក្នុងការសម្លាប់ពិតប្រាកដមានទោសពីបទមនុស្សឃាតគិតទុកជាមុនមែនឬយ៉ាងណា។ ប្រហាក់ប្រហែលគ្នានេះ រឿងក្ដី *Borkum Island* ដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើង ផ្ដល់ការគាំទ្រតិចតួចទៅឲ្យការទទួលខុសត្រូវតាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួមប្រភេទទី៣"។ ដូចជើងទំព័រខាងលើ។

ត្រូវមានភារៈទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងឋានៈជាចារី[106] ថ្វីបើប្រព័ន្ធច្បាប់បទល្មើសជាតិភាគច្រើនបានប្រើប្រាស់វិធីសាស្ត្រមួយដែលបែងចែកដាច់ពីគ្នារវាងចារី ឬជនដៃដល់នៃបទល្មើស និងជនសមគំនិតក្នុងបទល្មើស[107]។ លើសពីនេះ ក្នុងចំណោមសេចក្តីសម្រេចលើរឿងក្តីនៅអ៊ីតាលីទាំងអម្បាលម៉ាននោះ មានតែមួយករណីគត់ (D"Ottavio et al.) ដែលគេបានលើកឡើងដែលអាចគាំទ្រដល់ JCE III[108]។ ដូចដែលសាស្ត្រាចារ្យ Ambos ធ្វើការកត់សម្គាល់ខ្លីៗយ៉ាងដូច្នេះថា៖

> គេពុំអាចដកការទទួលស្គាល់ទម្រង់ JCE III នៅក្នុងច្បាប់ទំនៀមទម្លាប់ចេញពីបណ្តារឿងក្តីនៅអ៊ីតាលីដែលអង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងនោះទេ ... ដោយហេតុថាខុសស្រឡះពីការជំនុំជម្រះនានានៅចំពោះមុខតុលាការយោធាអាមេរិក និងអង់គ្លេស យើងឃើញថានៅក្នុងការជំនុំជម្រះនោះ គ្មានច្បាប់អន្តរជាតិណាមួយត្រូវបានតុលាការយកមកអនុវត្តឡើយ ក្រៅតែពីច្បាប់ជាតិ (មាត្រា ១១៦ [១] នៃក្រមព្រហ្មទណ្ឌអ៊ីតាលី)។ លើសពីនេះ ច្បាប់យុត្តិសាស្ត្រនេះទៀតសោតក៏គ្មានសង្គតិភាពដែរ ដោយហេតុថាតុលាការកំពូលអ៊ីតាលី (*Corte Suprema di Cassazione*) បានបង្កើតសេចក្តីសម្រេច២ ដែលខ្វែងយោបល់គ្នាមកប្រើប្រាស់[109]។

ទង្វើនេះពុំបានជួយគាំទ្រដល់អំណះអំណាងរបស់អង្គជំនុំជម្រះតុលាការកំពូល *Tadić* ដែលថា JCE III មានមូលដ្ឋានយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[110]។

---

[106] ក្រមព្រហ្មទណ្ឌអ៊ីតាលី មាត្រា ១១០ "Quando più persone concorrono nel medesimo reato, ciascuna di esse soggiace alla pena per questo stabilita, salve le disposizioni degli articoli seguenti" ។

[107] មើល ELIES VAN SLIEDREGT, THE CRIMINAL RESPONSIBILITY OF INDIVIDUALS FOR VIOLATIONS OF INTERNATIONAL HUMANITARIAN LAW 59 (The Hague, TMC Asser Press, 2003) ("VAN SLIEDREGT, THE CRIMINAL RESPONSIBILITY OF INDIVIDUALS")។

[108] មើលសាលដីកាបណ្តឹងឧទ្ធរណ៍ *Tadić* កថាខណ្ឌ ២១៥។

[109] Ambos Brief ទំព័រ២៩។

[110] មើល Powles, ត្រង់ 616-17. "ក្នុងរឿងក្តី *Tadić* អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា ក្នុងប្រទេសជាច្រើន ការទទួលខុសត្រូវស្រដៀងគ្នានឹងសហកម្មឧក្រិដ្ឋកម្មរួមប្រភេទទី៣ ពិតជាមានអត្ថិភាព។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលក៏បានយល់ឃើញថានៅក្នុងយុត្តាធិការមួយចំនួន ជនជាប់ចោទមានទោសតែចំពោះបទល្មើសដែលកើតចេញពីសហកម្មឧក្រិដ្ឋកម្មរួមតែប៉ុណ្ណោះ ប្រសិនបើជនជាប់ចោទបានរួមចំណែកក្នុងចេតនាដែលបានគិតនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះ។ ដូច្នេះប្រសិនបើសមាជិកនៃផែនការឧក្រិដ្ឋកម្មរួមណាម្នាក់បានប្រព្រឹត្តបទល្មើស ដែលពុំបានគិតទុកជាមុននៅក្នុងសហកម្មឧក្រិដ្ឋកម្មរួមនោះជននោះនឹងត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌតែម្នាក់ឯងចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ដូច្នេះទម្លាប់អនុវត្តន៍របស់

### ខ) សន្ធិសញ្ញាដែលជាប្រភពសំអាងរបស់អង្គជំនុំជម្រះតុលាការកំពូល *Tadić* ពុំគាំទ្រដល់អត្ថិភាពនៃការទទួលខុសត្រូវតាមទម្រង់ JCE ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ

៤១. បន្ថែមពីលើការសំអាងលើរឿងក្តីមួយចំនួនតូចដែលគេបានជ្រើសរើស អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ក៏បានសំអាងលើសន្ធិសញ្ញាអន្តរជាតិចំនួន២ ក្នុងការគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថាការទទួលខុសត្រូវតាមទម្រង់ JCE មានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ និងអនុសញ្ញាអន្តរជាតិសម្រាប់ការបង្ក្រាបការបំផ្ទុះគ្រាប់បែករបស់ពួកភេរវករ ("ICSTB")[111] ។ ភាសាដែលគេបានប្រទះឃើញនៅក្នុងមាត្រា ២៥(៣)(ឃ)[112] នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ផ្អែកមូលដ្ឋានតាមមាត្រា ២(៣)(គ)[113] នៃ ICSTB[114]។ ឯកសារការងារត្រៀមរៀបចំ *(travaux préparatoires)* នៃ ICSTB ពុំពន្យល់ថា

---

<u>វដ្តគឺពុំមានសង្គតិភាពជាមួយទម្រង់ពង្រីកនៃសហកម្មឧក្រិដ្ឋកម្មរួមឡើយ</u>។ ដូចដើងទំព័រខាងលើ ត្រង់៦១៥ (សេចក្តីបញ្ជាក់បន្ថែម)។

[111] *សូមមើល រឿងក្តី Tadić សាលដីកា កថាខណ្ឌ ២២០-២៣។*

[112] មាត្រា២៥(៣)(ឃ) បញ្ជាក់ថា៖ "អនុលោមតាមលក្ខន្តិកៈនេះ ជនទាំងឡាយត្រូវមានភារៈទទួលខុស ត្រូវផ្នែកព្រហ្មទណ្ឌ និងមានទោសចំពោះបទល្មើសស្ថិតនៅក្នុងយុត្តាធិការតុលាការប្រសិនបើជននោះ (ឃ) តាមមធ្យោបាយណាក៏ដោយ រួមចំណែកក្នុងការប្រព្រឹត្តិ ឬការប្រព្រឹត្តិគិតទុកជាមុន នូវបទល្មើស ដែលប្រព្រឹត្តតាមគោលបំណងរួមនៃមនុស្សមួយក្រុម។ ការរួមចំណែកនេះត្រូវមានលក្ខណៈចេតនា និងត្រូវ (i) ធ្វើឡើងក្នុងគោលបំណងជម្រុញអំពើល្មើស ឬចេតនាប្រព្រឹត្តបទល្មើសរបស់ក្រុមនោះ ដែលសកម្មភាព ឬគោលបំណងនេះពាក់ព័ន្ធនឹងការប្រព្រឹត្តិបទល្មើសក្នុងយុត្តាធិការរបស់តុលាការ ឬ (ii) ធ្វើឡើងដោយមានការដឹងឮអំពីចេតនាប្រព្រឹត្តបទល្មើសរបស់ក្រុមនោះ"។

[113] មាត្រា២(៣)(គ)គូសបញ្ជាក់ថា "ជនណាម្នាក់ត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើស ប្រសិនបើជននោះ (គ) តាមមធ្យោបាយណាក៏ដោយ ចូលរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើសមួយ ឬច្រើន របស់ក្រុមមនុស្សដែលមានគោលបំណងរួមគ្នា ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌ១ ឬ២ នៃមាត្រាបច្ចុប្បន្ន។ ការរួមចំណែកនេះត្រូវមានលក្ខណៈចេតនា និងធ្វើឡើងក្នុងគោលបំណងជម្រុញសកម្មភាពឧក្រិដ្ឋរួម ឬគោលបំណងនៃក្រុមនោះ ឬធ្វើឡើងដោយមានការដឹងឮអំពីចេតនាប្រព្រឹត្តបទល្មើស១ ឬច្រើនដែលពាក់ព័ន្ធរបស់ក្រុមនោះ"។

[114] Kai Ambos មាត្រា២៥ *Individual Criminal Responsibility, in* COMMENTARY ON THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT: OBSERVERS' NOTES, ARTICLE BY ARTICLE 475, 483 (Otto Triffterer ed., 1999). *See also* Powles, at 617 (មានបន្ថែមការសង្កត់ន័យ)។ "មាត្រា៣៥(៣)(ឃ) [នៃលក្ខន្តិកៈតុលាការ ICC] ត្រូវ បានទទួលស្គាល់ដោយពុំមានឧបសគ្គក្នុងអំឡុងកិច្ចពិភាក្សាក្នុងទីក្រុងរ៉ូម ដោយហេតុថាវាផ្អែកលើមូលដ្ឋាននៃ Terrorist Bombings Convention ដែលមតិភាគច្រើនបានអនុម័ត។ វាត្រូវបានគេចាត់ទុកថាជាមូលដ្ឋាននៃការទទួលខុសត្រូវ ដើម្បីជៀសផុតពីការពិភាក្សាដ៏ចម្រូងចម្រាស់ស្តីពីថាតើ "ការសមគំនិត" គួរត្រូវរាប់បញ្ចូលថាជាមូលដ្ឋាននៃការទទួលខុសត្រូវនៅក្នុងលក្ខន្តិកៈតុលា

ហេតុអ្វីបានជាពាក្យពេចន៍មួយចំនួនដែលគេបានប្រទះឃើញក្នុងមាត្រា២ ត្រូវបានគេប្រើប្រាស់នោះទេ[115]។ បើទោះបីជាយ៉ាងដូច្នេះក្តី ដូចដែលបានពន្យល់ខាងក្រោម គឺថាតុលាការព្រហ្មទណ្ឌអន្តរជាតិបានទាត់ចោលនូវយុត្តិសាស្ត្រទាក់ទិននឹងJCE របស់តុលាការពិសេសដូចដែលបានបញ្ជាក់ដោយសាលដីកាតុលាការ *Tadić* និងឯកសារក្រោយៗរបស់ខ្លួន ដោយខ្លួនពេញចិត្តនឹងវិធីសាស្ត្រនៃ "ការគ្រប់គ្រងបទល្មើស" ជាងការវែកញែកឱ្យដាច់ពីគ្នារវាងចារី និងអ្នកសមគំនិត[116]។ ដូច្នេះវាមានភាព "ចម្លែក" ដែលអង្គជំនុំជម្រះតុលាការកំពូល *Tadić* យកលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិមកសំអាង នេះបើតាមទស្សនៈរបស់សាស្ត្រាចារ្យ Schabas[117]។ សន្ធិសញ្ញាទាំង២នេះ ពុំគាំទ្រដល់អំណះអំណាងរបស់អង្គជំនុំជម្រះតុលាការកំពូល *Tadić* ឡើយ ហើយអំណះអំណាងនេះ

---

ការ ICC ដែរឬយ៉ាងណា។ ដើម្បីមានទោសចំពោះ "ការសមគំនិត" ជនជាប់ចោទត្រូវមាន ចេតនាប្រព្រឹត្តបទល្មើសដែលជាកម្មវត្ថុនៃការប្រព្រឹត្តិ។ <u>គេបានអះអាងថា ប្រសិនបើមាត្រា៣៥(៣)(ឃ) មានចេតនាជាមូលដ្ឋានមួយទៀតនៃការទទួលខុសត្រូវចំពោះការសមគំនិត វាអាចពុំមែនជាចេតនានៃអ្នកតាក់តែងសេចក្តីព្រាងក្នុងការរាប់បញ្ចូលមូលដ្ឋាននៃការទទួលខុសត្រូវ ដែលអាចដាក់ទោសជនជាប់ចោទ ប្រសិនបើជនជាប់ចោទពុំមានចេតនាចង់ឱ្យលទ្ធផលចុងក្រោយនៃអំពើរបស់ខ្លួនស្របទៅតាមផែនការរួម នោះ"។</u>

[115] សាលដីកាតុលាការឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ជើងទំព័រ ២៧៩។

[116] បន្ថែមពីលើការពិភាក្សាខាងក្រោម សូមមើលដែរ Damgaard, ត្រង់១៧៦ ជើងទំព័រ១៩១ ត្រង់ចំណុចដែល Damgaard គូសបញ្ជាក់ថា "តាមទស្សនៈរបស់អ្នកនិពន្ធ មាត្រា២៥(៣)(ឃ) ហាក់ដូចជាក្តោបក្រសោម JCE ប្រភេទទី៣"។ ត្រង់ជើងទំព័រមួយគាត់បានកត់សម្គាល់ថាសាស្ត្រាចារ្យ Van Sliedregt និង Ambos មានទស្សនៈដូចគ្នា។ សាស្ត្រាចារ្យ Ambos បានគូសបញ្ជាក់ថាតុលាការICC តាមរយៈសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាំង២ ដែលយើងលើកយកមកពិភាក្សាខាងក្រោម បានផ្តាច់ខ្លួនចេញពី JCE។ សាស្ត្រាចារ្យ Ambos កត់សម្គាល់ឃើញថា "អង្គជំនុំជម្រះតុលាការ ICC ភ្ជាប់គោលការណ៍ JCE ទៅនឹងវិធីសាស្ត្រអត្តានោម័ត នៅក្នុងច្បាប់ស្តីពីការប្រព្រឹត្តរួមគ្នា ដូចជា ការកំណត់អំពីការប្រព្រឹត្តរួមគ្នា តាមរយៈការពឹងផ្អែកលើចេតនា ឬឆន្ទៈរបស់ភាគី។ បន្ទាប់មក ខ្លួនបានបដិសេធជាដាច់ខាតនឹងវិធីសាស្ត្រនេះ និងគោលការណ៍ JCE"។ Ambos Brief ទំព័រ៧ ជើងទំព័រ១៧ សាស្ត្រាចារ្យ Olásolo ក៏បានយល់ដូចគ្នា នេះដែរ។ សូមមើល Héctor Olásolo, *Joint Criminal Enterprise and its Extended Form: A Theory of Co-Perpetration Giving Rise to Principal Liability, A Notion of Accessorial Liability, or a Form of Partnership in Crime?*, 20 CRIM. L. F. 263, 278 (2009) ("Olásolo, *Joint Criminal Enterprise and its Extended Form*")។ មើលផងដែរ ដូចជើងទំព័រខាងលើ ទំព័រ២៨៥ ត្រង់ចំណុចសាស្ត្រាចារ្យ Olasolo ពន្យល់ថាទ្ឡីករណ៍ជាគោលការណ៍ ដែលគាំទ្រ JCE III ពុំជម្រះកង្វល់ដែលផ្អែកលើមូលដ្ឋាននៃគោលការណ៍ នីត្យានុកូលភាព និងការទទួលខុសត្រូវឡើយ។ "ជាការពិត ភាពពាក់ព័ន្ធនៃកង្វល់អស់ទាំងនេះគឺថាអ្នកតាក់តែងសេចក្តីព្រាង លក្ខន្តិកៈតុលាការ ICC ពុំបានដកនូវទម្រង់ណាមួយនៃការទទួលខុសត្រូវបទល្មើស ដែលស្រដៀងគ្នាទៅនឹងទម្រង់ពន្លាតនៃសហកម្មឧក្រិដ្ឋកម្មរួម ចេញពីវង្វង់នៃមាត្រា២៥(៣)(ឃ)ឡើយ។

[117] WILLIAM SCHABAS, AN INTRODUCTION TO THE INTERNATIONAL CRIMINAL COURT 212 (Cambridge University Press, 2001) ("SCHABAS, AN INTRODUCTION TO THE ICC, 1st ed.")។

ត្រូវបានគាំទ្រជាហូរហែរដោយអង្គជំនុំ ជម្រះសាលាដំបូង ICTY/ICTR ដែលថាការទទួលខុសត្រូវតាមទម្រង់ JCE ត្រូវបានបញ្ជាក់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ លើសពីនេះទៅទៀត ក្នុងចំណោមសន្ធិសញ្ញាទាំងអស់នេះ គ្មានសន្ធិសញ្ញាណាមួយមានអត្ថិភាពក្នុងចន្លោះពីឆ្នាំ១៩៧៥-១៩៧៩ ទេ។ ដូច្នេះសន្ធិសញ្ញាទាំងអស់នេះពុំអាចគាំទ្រដល់ទឡ្ហីករណ៍ដែលថា ការទទួលខុសត្រូវតាមទម្រង់ JCE បានមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលមានឧក្រិដ្ឋកម្មពាក់ព័ន្ធដែលត្រូវបានចោទប្រកាន់ឡើយ[118]។

៤២. ដោយហេតុថាអង្គជំនុំជម្រះតុលាការកំពូល *Tadić* សំអាងលើប្រភពដ៏តិចតួចពីយុត្តិសាស្ត្រមួយចំនួនតូច និងដោយហេតុថាសន្ធិសញ្ញាទាំង២ដែលខ្លួនយកមកសំអាងនោះ ពុំគាំទ្រដល់អត្ថិភាពនៃការទទួលខុសត្រូវតាមទម្រង់ JCE ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូច្នេះ អ.វ.ត.ក ត្រូវវិភាគដោយឯករាជ្យដើម្បីកំណត់ថាតើការទទួលខុសត្រូវតាមទម្រង់ JCE ពិតជាមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិមែន ឬយ៉ាងណា ឧបមាថា អ.វ.ត.ក កំណត់ថាខ្លួនមានលទ្ធភាពយកច្បាប់នេះមកអនុវត្តដោយផ្ទាល់។

**២) ការទទួលខុសត្រូវតាមទម្រង់ JCE ពុំដែលធ្លាប់ជាទម្រង់មួយនៃការទទួលខុសត្រូវដែលអនុវត្តជាទូទៅ និងប្រកបដោយភាពស៊ីសង្វាក់គ្នានៃបណ្តារដ្ឋនានាឡើយ**

៤៣. គេអាចបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិបានត្រឹមតែតាមរយៈ (ក) ការអនុវត្តន៍ជាទូទៅ និងប្រកបដោយភាពស៊ីសង្វាក់របស់រដ្ឋ (general and consistent State practice) និង (ខ) សច្ចាធារណ៍ធម្មានុរូបនៃអំពើ (*opinio juris*)[119]។ នាពេលបច្ចុប្បន្ន ពុំទាន់មានការអនុវត្តន៍ការ

---

[118] មើល រដ្ឋអាជ្ញា ទល់នឹង *Orić* IT-03-68-A សាលដីកាតុលាការឧទ្ធរណ៍ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ គំនិតខ្វែងគ្នាដោយផ្នែក និងសេចក្តីប្រកាសរបស់ចៅក្រម Liu កថាខណ្ឌ២៦ សំអាងលើអត្ថបទនៃសេចក្តីព្រាងក្រមស្តីពី ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងសុវត្ថិភាពនៃមនុស្សជាតិ និងមាត្រា២៨នៃលក្ខន្តិកៈតុលាការICC ដែលត្រូវបានអនុម័ត បន្ទាប់ពីការអនុម័តលក្ខន្តិកៈតុលាការ ICTY និង ICTR "គេត្រូវវាយតម្លៃអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ គិតមកទល់ថ្ងៃ ប្រព្រឹត្តបទល្មើស, ការពិតដែលថា... [លក្ខន្តិកៈតុលាការ ICC] ត្រូវបានអនុម័តនៅមុនថ្ងៃទាំងនេះ វាកំណត់ព្រំដែននៃទម្ងន់និងសារប្រយោជន៍របស់វា ក្នុងឋានៈជាប្រភពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

[119] "ច្បាប់ទំនៀមទម្លាប់ចាប់ផ្តើមក្លាយជាទម្លាប់អនុវត្តន៍មួយ និងក្រោយមកក្លាយទៅជាវិធានផ្គោបជាប់មកជាមួយនូវកាតព្វកិច្ចក្នុងពេលអ្នកដែលគោរព តាមវិធីនេះ ចាប់ផ្តើមចាត់ទុកការអនុវត្តន៍ថាជាកាតព្វកិច្ចរបស់ពួកគេ។" Fletcher & Ohlin, *Reclaiming Fundamental Principles*, ត្រង់៥៥៦។ គេត្រូវកត់សម្គាល់ថា "វាមានការលំបាកខ្លាំងក្នុងការបង្កើតឲ្យមានការឯកភាពគ្នាដើម្បីនឹងផ្តល់សុពលភាពវិធានមួយថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ ដូចដើងទំព័រខាងលើ សូមមេត្តាមើលឧបសម្ពន្ធ ក ផ្នែក IIឃ សម្រាប់ការពិភាក្សាស៊ីជម្រៅអំពីការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ មើលផងដែរ Bogdan ត្រង់៦៩។

ទទួលខុសត្រូវតាមទម្រង់ JCE ដោយរដ្ឋជាទូទៅ និងប្រកបដោយភាពស៊ីសង្វាក់ឡើយ ហើយសច្ចាធារណ៍ធម្មានុរូបនៃអំពើ *opinio juris* ទាក់ទិននឹងការទទួលខុសត្រូវតាមទម្រង់ JCE ដែលជាអ្នកផ្តល់ឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទៅឲ្យ JCE នោះ ក៏ពុំដែលធ្លាប់បានធ្វើដែរ។

### ក) ច្បាប់យុត្តិសាស្ត្រ Nuremberg ពុំគាំទ្រដល់អត្ថិភាពនៃការទទួលខុសត្រូវតាមទម្រង់ JCE ឡើយ

៤៤. នៅឯតុលាការ Nuremburg ចុងចោទត្រូវបានចាត់ទុកថាជា "ចារី" ឬ "អ្នកសមគំនិត" ដូច្នេះនៅក្នុងសាលក្រមនោះ គ្មានការកំណត់និយមន័យនៃទំនាក់ទំនងរវាងចារីផ្ទាល់នៃអំពើមនុស្សឃាត និងជនជាប់ចោទឡើយ[120]។ សាលក្រមតុលាការមួយនេះខ្លី ហើយមានសំអាងហេតុអង្គច្បាប់តិចតួច។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ត្រូវទាញសេចក្តីសន្និដ្ឋានចេញពីទម្រង់នៃការទទួលខុសត្រូវដែលជនជាប់ចោទត្រូវបានចោទប្រកាន់ ផ្អែកតាមអំណះអំណាងរបស់រដ្ឋអាជ្ញា។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ពុំបានខិតខំបែងចែកឲ្យច្បាស់ថាតើជនជាប់ចោទនៅក្នុងរឿងក្តីទាំងនេះត្រូវបានចោទប្រកាន់ថាជាចារី ឬជនសមគំនិតឡើយ។ បញ្ហាដែលបានចោទឡើងនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* គឺវាកើតចេញមកពីវិធីសាស្ត្រនៃច្បាប់ខំម៉ិនឡូដែលចៅក្រមបានអនុវត្តតាម។ ចំពោះការខកខានពុំបានបែងចែកឲ្យដាច់ពីគ្នានូវទម្រង់នៃការចូលរួមផ្សេងពីគ្នាក្នុងកម្រិតនៃការចោទប្រកាន់ ពួកគាត់បានគាំទ្រនូវទម្រង់នៃការទទួលខុសត្រូវទាំងស្រុងមួយ (ដែលមានលក្ខណៈសាមញ្ញទូទៅក្នុងយុត្តិសាស្ត្រច្បាប់ខមិនឡូ) ដែលចាត់ទុកចារី និងជនសមគំនិតក្នុងកម្រិតស្មើៗគ្នា។

៤៥. សាស្ត្រាចារ្យ Ohlin ពន្យល់យ៉ាងដូច្នេះថា៖

> ជាឧទាហរណ៍ តុលាការក្នុងរឿងក្តី *Tadić* បានយករឿងក្តីនានាដូចជា *Kurt Goebell* និងរឿងក្តីមួយចំនួនទៀតដូចជា (រឿងក្តី The Borkum Island) សេចក្តីសម្រេចរបស់តុលាការយោធាសហរដ្ឋអាមេរិកឆ្នាំ១៩៤៥ មកធ្វើជាសំអាង។ មើល *Tadić* § ២១០-

[120] នៅឯតុលាការ Nurember ចៅក្រមបានជំទាស់ពុំព្រមបែងចែកឲ្យដាច់ពីគ្នារវាង ចារី និងជនសមគំនិត ឬមេខ្លោង និងអ្នកជួយ និងអ្នកចំនុកបម្រុង។ "ការទទួលខុសត្រូវជាលក្ខណៈបុគ្គលត្រូវបានគេដាក់នៅខាងក្រោមប្រភេទនៃការចូលរួមក្នុងបទល្មើស។ ... គ្មានការបែងចែកឲ្យដាច់ពីគ្នានូវភាគីក្នុងបទល្មើសឡើយ ឯភាពខុសពីគ្នានៃតួនាទី និងកម្រិតនៃការចូលរួម ត្រូវបានបញ្ចាក់នៅក្នុងការទោសនោះ"។ VAN SLIEDREGT, THE CRIMINAL RESPONSIBILITY OF INDIVIDUALS ត្រង់២៧,៣១។

២១២។ ក្នុងរឿងក្តីនោះ យន្តហោះរបស់បន្ទាយទ័ពអាកាសសហរដ្ឋអាមេរិកមួយគ្រឿងត្រូវបានបាញ់ទម្លាក់ក្នុងទឹកដីប្រទេសអាឡឺម៉ង់ ហើយអាកាសយានិកត្រូវបានគេបណ្តើររហូតដល់ស្លាប់។ ក្រុមអាកាសយានិកត្រូវបានកងទ័ពអាឡឺម៉ង់បណ្តើរមកឱ្យប្រជាជនស៊ីវិលវាយដំ ហើយចុងក្រោយពួកគេត្រូវបានបាញ់សម្លាប់ចោលតែម្តង។ ខាងភាគីរដ្ឋអាជ្ញាសហរដ្ឋអាមេរិកបានលើកអំណះអំណាងនានាសុំឱ្យមានសាលក្រមបញ្ជាក់ពិរុទ្ធភាពមួយដោយផ្អែកតាមទ្រឹស្តីទូលំទូលាយនៃគោលបំណងបទល្មើសរួម។ <u>បើទោះបីជាអង្គហេតុនៃរឿងក្តីនេះពាក់ព័ន្ធផ្ទាល់ទៅនឹងការពិភាក្សាអំពីសហកម្មឧក្រិដ្ឋកម្មរួមក្តី ក៏តុលាការយោធានេះបានចេញត្រឹមតែសាលក្រម បញ្ជាក់ពិរុទ្ធភាពសាមញ្ញធម្មតាមួយប៉ុណ្ណោះ ដោយពុំផ្តល់សំអាងហេតុតាមទិដ្ឋភាពច្បាប់ឱ្យបានទូលំទូលាយ ស្តីពីបញ្ហានៃផែនការឧក្រិដ្ឋកម្មរួម ឬការវាយដំពីសំណាក់ហ្វូងមនុស្សឡើយ</u>។ <u>ដូច្នេះទើបបានជាតុលាការក្នុងរឿងក្តី *Tadić* បានត្រឹមតែដកស្រង់ពាក្យពេចន៍ផ្ទាល់ពីរដ្ឋអាជ្ញាតុលាការយោធាអាមេរិច និង *ទាញសេចក្តីសន្និដ្ឋាន* ថាចៅក្រមបានប្រើប្រាស់សំអាងហេតុរបស់ភាគីរដ្ឋអាជ្ញា។រឿងក្តីប្រភេទនេះពុំមានតម្លៃនឹងយកមកពិចារណាឡើយ។</u> តាមពិតការពិភាក្សារបស់រដ្ឋអាជ្ញាស្តីពីបញ្ហានេះ គឺពិតជាពុំមានភាពស៊ីសង្វាក់នៅខាងក្នុងឡើយ[121]។

៤៦. ក៏នៅមានគំរូជាច្រើនទៀត ដែលនិយាយអំពីបណ្តារឿងក្តីផ្សេងៗនៅក្រោយសម័យសង្គ្រាមលោកលើកទី២ ដែលក្នុងនោះទម្រង់ពង្រាតនៃការទទួលខុសត្រូវតាមទម្រង់ JCE (JCE III) ពុំត្រូវបានគេយកមកប្រើប្រាស់ដែរ។ ការពិតដែលថាការទទួលខុសត្រូវតាមទម្រង់ JCE ពុំត្រូវបានគេអនុវត្តឱ្យមានភាពស៊ីសង្វាក់នៅក្នុងរឿងក្តីទាំងនេះ សបញ្ជាក់ថាការទទួលខុសត្រូវនេះពិតជាពុំត្រូវចាត់ទុកថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។ ជាក់ស្តែងក្នុងរឿងក្តី *Justice* ចុងចោទ Alstoetter ត្រូវបានតុលាការរកឃើញថាមានទោសដោយសារជននេះជាសមាជិកក្រុម SS ប៉ុន្តែពុំមានទោស

---

[121] Jens David Ohlin, *Three Conceptual Problems with the Doctrine of Joint Criminal Enterprise*, 5 J. INT'L CRIM. JUST. ៦៩,៧៥ ជើងទំព័រ១០ (2007) ("Ohlin, *Three Conceptual Problems*") (មានបន្ថែមការសង្កត់ន័យ)។ សូមមើលផងដែរ McGill Brief កថាខណ្ឌ២៤ ដែលនិយាយអំពីរឿងក្តី *Essen Lynching* និង *Borkum Island* "បញ្ហាជាសារវ័ន្ត២នៅក្នុងការប្រើប្រាស់រឿងក្តីទាំងនេះដើម្បីគាំទ្រគោលការណ៍ទូលំទូលាយស្តីពីJCE ទម្រង់ពង្រាត គឺថា កាលៈទេសៈនៃរឿងក្តីនេះពុំមានលក្ខណៈច្បាស់លាស់ អំពីតួនាទី ឬចេតនានៃអ្នកចូលរួមម្នាក់ៗ ហើយផ្នែកសំអាងហេតុ របស់តុលាការច្បាស់ជាទាញយកមកពីទង្ហីករណ៍របស់ភាគីរដ្ឋអាជ្ញា និងការរកពិរុទ្ធភាព"។

ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ។ ចុងចោទ Cuhorst ត្រូវបានតុលាការសម្រេចឱ្យរួចផុតពីបទចោទ ក្នុងពេលតុលាការមិនអាចរកឃើញថាគាត់បានរើសអើងប្រឆាំងនឹងជនជាតិ Poles ដែលត្រូវបានតុលាការរបស់គាត់យកមកជំនុំជម្រះ។ ប្រសិនបើតុលាការកាត់សេចក្តីចុងចោទទាំង២នាក់នេះតាមទ្រឹស្តី JCE ពន្លាតវិញនោះ ខណៈដែលគេបានរកឃើញថាពួកគេបានព្រមព្រៀងចំពោះគោលដៅឧក្រិដ្ឋទាំងមូលរបស់ Hitler និង SS ក្នុងការរើសអើងប្រឆាំងនឹងជនជាតិជ្វីហ្វ និង Poles ហើយបានចូលរួមនៅក្នុងក្រសួងយុត្តិធម៌ ឬតុលាការពិសេស ចុងចោទទាំង២នាក់ប្រាកដជាត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលគេអាចដឹងមុន ដែលត្រូវបានប្រព្រឹត្តដោយមនុស្សដើម្បីឈានទៅសម្រេចតាមគោលដៅទាំងអស់នោះជាក់ជាមិនខាន[122]។

### ខ) ប្រព័ន្ធច្បាប់ភាគច្រើនជ្រើសរើសយកការប្រព្រឹត្តរួមគ្នា (Co-perpetration) ជាជាង JCE

៤៧. រដ្ឋនានាជាច្រើនឯទៀតក៏ដូចជាកម្ពុជា ពុំយកការទទួលខុសត្រូវតាមទម្រង់ JCE មកអនុវត្តទេ ប៉ុន្តែផ្ទុយទៅវិញប្រើប្រាស់នូវទម្រង់នៃការប្រព្រឹត្តរួមគ្នា ដែលខុសផ្សេងពីទម្រង់ JCE[123]។ សម្រាប់កម្ពុជា អនុលោមតាមមាត្រា ៨២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ចែងថា "ជនណាចូលរួមប្រព្រឹត្តដោយដោយចេតនា នូវបទល្មើស ទោសកម្មណាមួយ ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ជននោះត្រូវមានទោសដូចជា អាទិចារី។ ការរួមប្រព្រឹត្តដោយផ្ទាល់ទុកជាសហចារី ឯការរួម

---

[122] សហរដ្ឋអាមេរិក ទល់នឹង *Alstoetter* ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuremberg តាមច្បាប់ក្រុមប្រឹក្សាគ្រប់គ្រង លេខ១០ វ៉ុល III ទំព័រ៩៥៦,១១៥៨,១១៧១ (១៩៥០)។ សម្រាប់ឧទាហរណ៍មួយទៀតនៃរឿងក្តីក្រោយសង្គ្រាមលោកលើកទី២ ដែលពុំបានជំនុំជម្រះតាមទ្រឹស្តី JCE សូមមើល រដ្ឋអាជ្ញា ទល់នឹង Brdanin IT-99-36-A, Amicus Brief of Association of Defence Counsel – ICTY, ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៥ ទំព័រ៩-១០។

[123] លើសពីនេះទៀត យោងទៅលើ ការសិក្សាស្រាវជ្រាវរបស់ Max-Plank ការចូលរួមក្នុងបទល្មើស៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់មេដឹកនាំក្រុម និងបណ្តាញរបស់ឧក្រិដ្ឋជន យោបល់អ្នកជំនាញ ដែលត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ តុលាការ ICTY ការិយាល័យនៃការសម្របសម្រួលគម្រោងរបស់រដ្ឋអាជ្ញា : សាស្ត្រាចារ្យ បណ្ឌិត Ulrich Sieber., Priv. Doz. បណ្ឌិត Hans Georg Koch, Jan Michael Simon, Max Planck Institut für ausländisches und internationales Strafrecht, Freiburg, Germany ("Max-Planck, Participation in Crime"), សេចក្តីផ្តើម ទំព័រ ៣ "ការប្រៀបធៀបមួយនៃវិធាន ដែលគ្រប់គ្រងលើការ ចូលរួមក្នុងបទឧក្រិដ្ឋ បង្ហាញនូវកម្រិតខ្ពស់នៃភាពខុសគ្នា ក្នុងចំណោមប្រព័ន្ធច្បាប់ដែលត្រូវបានគេសិក្សាទៅលើ..." (សេចក្តីបញ្ជាក់បន្ថែម)។

ប្រព្រឹត្តដោយប្រយោលទុកជាការសមគំនិត[124]"។

៤៨. ទម្រង់នៃការប្រព្រឹត្តរួមគ្នាបែងចែកដាច់ពីគ្នារវាងការទទួលខុសត្រូវក្នុងឋានៈជាចារី និងជនសមគំនិត។ ភាពខុសគ្នានេះមានសារសំខាន់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ ដូចជាកម្ពុជា "ដោយសារតែភាពខុសគ្នានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូខ្លះ នៅក្នុងការវិនិច្ឆ័យទោសអតិបរមាក្នុងកម្រិតទាបជាងធម្មតានូវអ្នកជួយជ្រោមជ្រែងចារី[125]"។ រដ្ឋជាច្រើនផ្សេងទៀតក៏បានប្រើប្រាស់ទម្រង់សហចារីនេះផងដែរ។ ជាការពិតមួយ យោងតាមការសិក្សាមួយរបស់ Max Planck Institute តាមសំណើបន្ទាន់របស់ការិយាល័យរដ្ឋអាជ្ញានៃតុលាការ ICTY បញ្ជាក់ថារដ្ឋភាគច្រើនប្រើប្រាស់ទម្រង់ការប្រព្រឹត្តរួមគ្នា ជាជាងទម្រង់នៃការទទួលខុសត្រូវតាម JCE[126]។

---

[124] បកប្រែក្រៅផ្លូវការ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីក៏បានកត់សំគាល់ថា "បទល្មើសទាំងនេះ ដែលមានចរិតលក្ខណៈ អន្តរជាតិ គឺជាបទល្មើសជាតិដ៏ចម្បងផងដែរ ហើយដូច្នេះត្រូវបានផ្តន្ទាទោសក្រោមច្បាប់ជាតិដែលពាក់ព័ន្ធ ដែលចែង សម្រាប់ពហុចារី (ការប្រព្រឹត្តរួមគ្នា) និងការជួយ និងការជំរុញ (ការសមគំនិត)" បណ្តឹងឧទ្ធរណ៍ JCE របស់ភាគីដើមបណ្តឹង រដ្ឋប្បវេណី កថាខណ្ឌ ១១ (សេចក្តីបញ្ជាក់បន្ថែម)។ សូមមើល ឧបសម្ព័ន្ធ ក ផ្នែក II គ សម្រាប់ការពិភាក្សាអំពីភាព ខុសគ្នារវាងការប្រព្រឹត្តរួមគ្នា និង JCE។

[125] យោងតាម Damgaard នេះគឺជាមូលហេតុដែលតុលាការ*ពិសេស* បានផ្តោតយកចិត្តទុកដាក់លើបញ្ហាថាតើ JCE គឺជាទម្រង់មួយនៃការទទួលខុសត្រូវរបស់អចិចារី ឬ ការទទួលខុសត្រូវរបស់អ្នកសមគំនិត។ Damgaard, ទំព័រ១៩៤។

[126] *សូមមើល* Max-Planck, Participation in Crime, ភាគីទី១៖ ការវិភាគប្រៀបធៀបនៃប្រព័ន្ធច្បាប់, ទំព័រ ១៦។ ដូច្នេះ វាមិនភ្ញាក់ផ្អើលទេដែលថា សាស្ត្រាចារ្យ Ambos កត់សម្គាល់ក្នុង *សារណាររបស់អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងរឿងក្តី ឌុច ថា៖

ផ្ទុយទៅនឹងប្រវត្តិនេះ និង ការទទួលស្គាល់ជាសកលនៃ ការប្រព្រឹត្តរួមគ្នា ថាជាទម្រង់មួយនៃការប្រព្រឹត្តឧក្រិដ្ឋ (សូមមើលតែមាត្រា ២៥(៣)(ក)ទី2 alt. លក្ខន្តិកៈតុលាការ ICC) វាលើសពីការភ្ញាក់ផ្អើលទៅទៀត នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី [*Stakić*] ថ្លែងថាមួយផ្នែក 'ទម្រង់នៃការទទួលខុសត្រូវ (...) មិនមានការគាំទ្រក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ (...)' ប៉ុន្តែមួយផ្នែកទៀត ការទទួលខុសត្រូវ JCE គឺ 'ត្រូវបានបង្កើតឡើងយ៉ាងប្រាកដ' (សាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Stakić*...)។ [...] ក្នុងករណីណាមួយ ការប្រព្រឹត្តរួមគ្នាបានទទួលស្គាល់យ៉ាងជាក់លាក់ក្នុងមាត្រា ២៥ (៣) (ក) នៃលក្ខន្តិកៈតុលាការ ICC ដូចដែលបានលើកឡើងដោយអង្គបុរេជំនុំជម្រះតុលាការ ICC ការបញ្ជាក់លើការចោទប្រកាន់ក្នុងរឿងក្តី *Lubanga* ...

Ambos Brief, ជើងទំព័រលេខ ៤១។

**គ) លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ពុំយកការទទួលខុសត្រូវតាមទម្រង់ JCE មកចងក្រងធ្វើជាច្បាប់ឡើយ។ ច្បាប់យុត្តិសាស្ត្ររបស់ខ្លួនបានបដិសេធពុំទទួលស្គាល់ការយកការទទួលខុសត្រូវតាមទម្រង់ JCE មកអនុវត្ត**

៤៩. ដូចយើងលើកយកពិភាក្សាខាងក្រោម អង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Lubanga* ដែលកាលនោះមានអតីតប្រធានតុលាការ ICTY ចៅក្រម Claude Jorda ធ្វើជាអធិបតីលើសវនាការគឺថា "តាំងពីគ្រាដំបូង អង្គបុរេជំនុំជម្រះមានចេតនាអនុវត្តឃ្លាតចាកពីវិធីសាស្ត្រតែមួយគត់របស់តុលាការ ICTY ក្នុងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវរួមដែលជាបញ្ហាដដែល" នៅពេលខ្លួន "បដិសេធនូវសំណើរបស់មេធាវីការពារជនរងគ្រោះមួយរូបដែលសុំឱ្យយកទស្សនាទាននៃ JCE ច្របាច់បញ្ចូលទៅក្នុងសញ្ញាណនៃ "ការប្រព្រឹត្តិបទល្មើសនេះ...រួមជាមួយមនុស្សម្នាក់ទៀត" របស់លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដោយសម្តែងការស្ទាក់ស្ទើរមិនចង់ទទួលស្គាល់ JCE ថាជាទម្រង់មួយនៃការទទួលខុសត្រូវ[127]។

៥០. មាត្រា ២៥ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មានចែងពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវចំពោះបទល្មើសជាលក្ខណៈបុគ្គល ដែលមានជាធរមាននៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រានេះត្រូវបានព្រាងឡើងនៅក្នុងការជជែកពិភាក្សាគ្នាយ៉ាងទូលំទូលាយ ស្តីពីលក្ខន្តិកៈតុលាការ

---

[127] សៀវភៅរបស់ Thomas Weigend, មានចំណងជើងថា *Intent, Mistake of Law and Co-perpetration in the* Lubanga *Decision on Conformation of Charges*, 6 J. Int'l Crim. Just. ទំព័រ ៤៧១, ៤៧៦-៧៨ (២០០៨)។ គួរឱ្យចាប់អារម្មណ៍ និងស្របជាមួយនឹងការជំទាស់មួយក្នុងចំណោមការជំទាស់ទាំងឡាយរបស់មេធាវីការពារក្តី នៃ JCE នៅចំពោះមុខ អ.វ.ត.ក សាស្ត្រាចារ្យ Weigend កត់សម្គាល់ថា "<u>វាប្រហែលជាមិនយុត្តិធម៌នោះទេ ដែលនិយាយថា JCE ដែលបានបង្កើតឡើងដោយតុលាការ ICTY មានបេសកកម្មនយោបាយមួយ</u> គឺថាត្រូវដាក់ឱ្យអនុវត្តនូវ 'គោលការណ៍' ដែលថា 'ជនទាំងឡាយណាដែលជាប់ពាក់ព័ន្ធក្នុងការរំលោភដ៏ធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ ទោះក្នុងលក្ខណៈណាក៏ដោយដែលពួកគេអាចបានប្រព្រឹត្ត ឬ បានចូលរួមក្នុងការរៀបចំការរំលោភបំពានទាំងនោះ ត្រូវតែនាំខ្លួនមកកាត់ទោស' ...<u>តាមពិតនោះ បញ្ហាគឺថាតើបំណង (ដែលអាចយល់បាន) ក្នុងការនាំខ្លួន 'ចារី' ទាំងអស់មកកាត់ទោស គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់កំណត់អ្នកដែលជា 'ចារី' ដែរឬអត់។ និយាយម្យ៉ាងទៀត ចំពោះ JCE ការបោះសំណាញ់របស់ខ្លួនទូលំទូលាយពេក អាចធ្វើឱ្យខ្លួនមានការលំបាកក្នុងការពន្យល់ពីមូលហេតុថាហេតុអ្វីបានជាត្រី [ចារី] និមួយៗដែលចាប់បាន គួរទទួលនូវការដាក់ទណ្ឌកម្មចំពោះកំហុសឆ្គងជាអន្តរជាតិ"។</u> *ដូចជើងទំព័រខាងលើ,* ទំព័រ ៤៧៧ (គូសបញ្ជាក់បន្ថែម ជើងទំព័រត្រូវបានលុប)។

ឧក្រិដ្ឋកម្មអន្តរជាតិអស់រយៈពេល៣ឆ្នាំ និងមានប្រទេសចំនួន១៦០ចូលរួម[128]។ គោលដៅចម្បងនៃសន្និសិទទីក្រុងរ៉ូម គឺត្រូវសម្រេចឱ្យមានការទទួលស្គាល់តុលាការព្រហ្មទណ្ឌអន្តរជាតិឱ្យបានទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបាន ជាសំខាន់គឺតាមរយៈការដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈនូវបទប្បញ្ញត្តិនានាដែលគេបានទទួលស្គាល់តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[129]។ តុលាការថ្មីនេះត្រូវស្របទៅតាមគោលការណ៍ និងវិធាននានា ដែលធានាឱ្យមានបទដ្ឋានយុត្តិធម៌កម្រិតខ្ពស់បំផុត ហើយ គេត្រូវយកវិធានទាំងអស់នេះទៅច្របាច់បញ្ចូលក្នុងលក្ខន្តិកៈនេះ ជាជាងទុកឱ្យមានភាពស្រពេចស្រពិលតាមរយៈឆន្ទានុសិទ្ធិតុលាការ[130]។ ជាការពិត ដោយគិតពីកម្រិតនៃការចូលរួមនិងថិរវេលានៃ ដំណើរការព្រាងមាត្រានេះ គេបានចាត់ទុកថាលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិពិតជាបានយកច្បាប់ទំនៀមទម្លាប់អន្តរជាតិ មកប្រមូលចងក្រងធ្វើជាច្បាប់ស្ដីពីឧក្រិដ្ឋកម្មអន្តរជាតិប្រាកដមែន[131]។ នេះបង្ហាញឱ្យយើងឃើញអំពីចរិតលក្ខណៈច្បាស់លាស់ នៃការរួមបញ្ចូលសច្ចាធារណ៍ធម្មានុរូបនៃអំពើ *(opinio juris)* របស់សហគមន៍អន្តរជាតិដែលកំពុងតែផុសចេញជារូបរាង[132]។ ដំណើរការមួយនេះក៏ត្រូវបានគេចាត់ទុកថាជាការបង្រួបបង្រួម*តាមព្រឹត្តិន័យ*

---

[128] សៀវភៅរបស់ John Washburn, មានចំណងជើងថាThe Negotiation of the Rome Statute for the International Criminal Court and International Lawmaking in the 21st Century, 11 PACE INT'L L. REV. ទំព័រ ៣៦១, ៣៦១ (ឆ្នាំ១៩៩៩)។

[129] សៀវភៅរបស់ GERHARD, PRINCIPLES OF INTERNATIONAL CRIMINAL LAW ទំព័រ ៤០២ ជើងទំព័រ ១០៨ (បោះពុម្ពដោយ TMC Asser Press, ប្រែសម្រួលលើកទី១ ឆ្នាំ២០០៥) ("WERLE")។

[130] សៀវភៅរបស់ WILLIAM A. SCHABAS, មានចំណងជើងថា AN INTRODUCTION TO THE INTERNATIONAL CRIMINAL COURT ទំព័រ១៦-១៧, (បោះពុម្ពដោយ Cambridge University Press ប្រែសម្រួលលើកទី៣ ឆ្នាំ២០០៧)។

[131] "សន្ធិសញ្ញាជាច្រើនក្នុងផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ចងក្រងច្បាប់ទំនៀមទម្លាប់អន្តរជាតិយ៉ាងប្រាកដ និង យ៉ាងថៃដន្យ។ ឧទាហរណ៍ បញ្ហានេះពិតប្រាកដទាក់ទងនឹង និយមន័យនៃបទល្មើសក្នុងលក្ខន្តិកៈតុលាការ ICC"។ WERLE ទំព័រ ៤៥, រឹមទំព័រលេខ ១២៧។ "ជម្រើសទីពីរនិងទីបី បទប្បញ្ញត្តិមាត្រា ២៥(៣)(ខ) នៃលក្ខន្តិកៈតុលាការ ICC ឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់"។ WERLE ទំព័រ ១២៥, រឹមទំព័រលេខ ៣៥៨។ *សូមមើលផងដែរ* សៀវភៅរបស់ SCHABAS, មានចំណងជើងថា AN INTRODUCTION TO THE ICC, ប្រែសម្រួលលើកទី១, ទំព័រ២០, ជើងទំព័រលេខ ៦២ ដែលមានឧទាហរណ៍មួយនៃលក្ខន្តិកៈរបស់តុលាការ ICC កំពុងត្រូវបានទាញហេតុសំអាងជាការណែនាំមួយចំពោះការវិវឌ្ឍន៍នៃច្បាប់ទំនៀមទំលាប់អន្តរជាតិ។

[132] "លក្ខន្តិកៈតុលាការ ICC 'ធ្វើឱ្យមានលក្ខណៈជាអន្តរជាតិ' នូវគោលការណ៍រួមទាំងឡាយនៃច្បាប់ព្រហ្មទណ្ឌ ដែលត្រូវបានទទួលស្គាល់ក្នុងប្រព័ន្ធច្បាប់ជាតិ ដោយផ្ដល់ឱ្យនូវអ្វីដែលកំពុងត្រូវបានមើលឃើញថាជាលក្ខខណ្ឌតាមជាក់ស្ដែង ឬ ជាការរួមបញ្ចូលនូវគោលការណ៍ទាំងនោះនៅលើកម្រិតអន្តរជាតិ។ លើសពីនេះទៀត ខ្លឹមសាររបស់លក្ខន្តិកៈតុលាការ ICC គឺជាការបញ្ចូលគ្នានៃច្បាប់ករណីខាងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ និង ច្បាប់មនុស្សធម៌អន្តរជាតិសំខាន់ៗ។ ការពិតដែលថា រដ្ឋចំនួន ១២០

នូវគោលការណ៍បទល្មើសជាតិក្នុងកម្រិតអន្តរជាតិ[133]។ ជាការពិត មានការឯកភាពជាទូទៅមួយ[134]ថាអ្នកតាក់តែងសេចក្តីព្រាងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ នឹងពុំសម្រេចបង្កើតច្បាប់ថ្មី ឬទម្រង់នៃការទទួលខុសត្រូវថ្មី ដែលផ្ទុយពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលត្រូវបានបង្កើតឡើងឡើយ។ ក្នុងឋានៈជាប្រធានសន្និសីទទីក្រុងរ៉ូម លោក Philippe Kirsch បានអះអាងថា "គេបានយល់ថាលក្ខន្តិកៈដែលបានតាក់តែងឡើងនេះ គឺពុំមានបំណងបង្កើតឱ្យមានច្បាប់សារធាតុថ្មីនោះទេ ពោលគឺគេតាក់តែងវាឡើងគ្រាន់តែដើម្បីដាក់បញ្ចូលបទល្មើសទាំងឡាយ ដែលច្បាប់អន្តរជាតិបានហាមឃាត់រួចហើយប៉ុណ្ណោះ[135]"។ អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY ក្នុងរឿងក្តី *Furundžija* បានកត់សម្គាល់ឃើញថា ពង្រាងក្រម(Draft Code) ដែលមានអត្ថិភាពមុនលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ "គឺជាលិខិតុបករណ៍អន្តរជាតិដែលមានអាជ្ញាព្រឹត្តិដែលអាច (i) ទុកជាភស្តុតាងបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់ ឬ (ii) បំភ្លឺអំពីវិធានទំនៀមទម្លាប់នានាដែលមានខ្លឹមសារពុំច្បាស់លាស់ ឬដែលកំពុងស្ថិតក្នុងដំណើរការរៀបចំបង្កើត ឬ (iii) ជាសញ្ញាបញ្ជាក់អំពីទស្សនៈផ្នែកច្បាប់នៃអ្នកផ្សព្វផ្សាយច្បាប់ដែលមានគុណវុឌ្ឍិខ្ពស់ តំណាងឱ្យប្រព័ន្ធច្បាប់សំខាន់ៗក្នុងលោក[136]"។ ចៅក្រម Schomburg នៃអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ក្នុងរឿងក្តី *Gacumbitsi* ដែលជាអ្នកធ្វើសេចក្តីអត្ថាធិប្បាយអំពីមាត្រា២៥ បានកត់សម្គាល់ឃើញថាដោយពិចារណាអំពីការដឹងឮយ៉ាងទូលំទូលាយអំពីសហចារី និងចារី

---

បានបោះឆ្នោតគាំទ្រលក្ខន្តិកៈនោះ នៅសន្និសីទក្រុងរ៉ូមឆ្នាំ១៩៩៨ អាចត្រូវបាននិយាយថា ដើម្បីផ្តល់ជូននូវភស្តុតាងច្បាស់លាស់នៃការលេចឡើងនូវគោលការណ៍ *opinio juris* ចំពោះលក្ខណៈ និងទំហំនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។ DOMINIC MCGOLDRICK និងអ្នកផ្សេងទៀត, THE PERMANENT INTERNATIONAL CRIMINAL COURT: LEGAL AND POLICY ISSUES ទំព័រ ៣៥០, (បោះពុម្ពដោយ Hart Publishing, ប្រែសម្រួលលើកទី១, ឆ្នាំ២០០៤)។

133 *ដូចជើងទំព័រខាងលើ*។

134 "ដោយសារកិច្ចព្រមព្រៀងរួមដែលការកំណត់និយមន័យបទល្មើសនៅក្នុងលក្ខន្តិកៈតុលាការ ICC ត្រូវឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានស្រាប់ និងមិនបង្កើតច្បាប់ថ្មីនោះ រដ្ឋទាំងឡាយពឹងផ្អែកជាច្រើនទៅលើច្បាប់ចាស់ដែលទទួលស្គាល់ពីមុនមក ក្នុងការបង្កើតនិយមន័យក្នុងមាត្រា ៦ ដល់ មាត្រា៨ នៃលក្ខន្តិកៈតុលាការ ICC"។ សៀវភៅរបស់ KNUT DORMANN និងអ្នកផ្សេងទៀត, មានចំណងជើងថា ELEMENTS OF WAR CRIMES UNDER THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT xiii (បោះពុម្ពដោយ Cambridge University Press, ២០០៣)។

135 **Philippe Kirsch**, John T. Holmes, *The Rome Conference on an International Criminal Court: the Negotiating Process*, 93 AM. J. INT'L L. 2, 7, ជើងទំព័រ១០ (១៩៩៩)។

136 *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Furundzija*, OI -95-17/1-T, សាលក្រម, 10 December 1998, para 227។

ដោយប្រយោល ឃើញថាលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិពុំបង្កើតឱ្យមានច្បាប់ថ្មីនៅត្រង់ប្រការនេះទេ ក៏ប៉ុន្តែវាឆ្លុះបញ្ចាំងអំពីច្បាប់ដែលមានស្រាប់[137]។

៥១. តាមរយៈការទទួលស្គាល់របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* លក្ខន្តិកៈនេះគឺជា "អត្ថបទមួយដែលទទួលបានការគាំទ្រពីសំណាក់រដ្ឋជាច្រើនសន្ធឹកសន្ធាប់ ដែលគេអាចយកមកប្រើប្រាស់ដើម្បីបញ្ជាក់អំពីស្ថានភាពផ្លូវច្បាប់ នោះគឺសច្ចាធារណ៍ធម្មានុរូបនៃអំពើ *(opinio juris)* របស់បណ្តារដ្ឋទាំងអស់នោះ[138]"។ ប៉ុន្តែ ដូចដែលបានបញ្ជាក់ដោយរឿងក្តី *Tadić* ទ្រឹស្តី JCE ពុំត្រូវបានដាក់បញ្ចូលនៅក្នុងពាក្យពេចន៍នៃមាត្រា ២៥ ឡើយ។ ចេតនា មិនដាក់បញ្ចូល JCE ទៅក្នុងពាក្យពេចន៍នៃមាត្រា ២៥ ថ្វីបើគេបានខិតខំតាក់តែងវាយ៉ាងហ្មត់ចត់អស់រយៈពេលដ៏យូរយ៉ាងណាក៏ដោយនោះ គឺជាសញ្ញាបញ្ជាក់ប្រាប់អំពីការពិតមួយដែលថាការទទួលខុសត្រូវតាមទម្រង់ JCE ពុំអាចត្រូវបានចាត់ទុកថាជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ។ ជាការពិត តុលាការបទល្មើសអន្តរជាតិបានបដិសេធពុំទទួលស្គាល់ការទទួលខុសត្រូវតាមទម្រង់ JCE។ តុលាការនេះបានពន្យល់ថាមានវិធីសាស្ត្រ ៣ ក្នុងការកំណត់ថាតើអំពើណាមួយជាការទទួលខុសត្រូវរបស់ចារី ឬជនសមគំនិត។ វិធីសាស្ត្រទាំង៣នេះគឺ វិធីសាស្ត្រសត្យានុម័ត (objective approach) វិធីសាស្ត្រអត្តនោម័ត (subjective approach) និងវិធីសាស្ត្រសំដៅលើ "ការគ្រប់គ្រងលើបទល្មើស (control over crime approach)"[139]។

៥២. វិធីសាស្ត្រសត្យានុម័តផ្តោតលើការសម្រេចបាននូវធាតុផ្សំសត្យានុម័តមួយ ឬច្រើននៃបទល្មើស។ តាមរយៈវិធីសាស្ត្រនេះ មានតែជនដែលដែលអនុវត្តផ្ទាល់នូវធាតុផ្សំសត្យានុម័តមួយ ឬច្រើននៃបទល្មើសប៉ុណ្ណោះ ដែលអាចត្រូវបានចាត់ទុកថាជាចារីនៃបទល្មើស[140]។

---

[137] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Gacumbitsi*, ICTR-2001-64-A, សាលដីកា, យោបល់ដាច់ដោយឡែករបស់ចៅក្រម Schomburg ស្តីពីការទទួលខុសត្រូវលើបទល្មើសរបស់ដើមបណ្តឹងឧទ្ធរណ៍ចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍, ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦, កថាខណ្ឌ២១។

[138] សាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić*, កថាខណ្ឌ ២២៣។

[139] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo*, ICC-01/04-01/06, សេចក្តីសម្រេចលើការបញ្ជាក់ពីការចោទប្រកាន់,ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ (*"Lubanga"*), កថាខណ្ឌ ៣២៧-៣០។

[140] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ ៣២៨។ អង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Lubanga* បានកត់សម្គាល់ថា ខ្លួនមិនអាច ធ្វើតាមវិធីសាស្ត្រនេះបានទេ ពីព្រោះទស្សនៈទាននៃការប្រព្រឹត្តបទល្មើសតាមរយៈមនុស្សម្នាក់ផ្សេងទៀត ក្នុងមាត្រា ២៥(៣)(ក) នៃលក្ខន្តិកៈតុលាការ ICC មិនអាចត្រូវបានសម្រុះសម្រួលជាមួយនឹងទស្សនៈទាននៃការកំណត់ចំណាត់ថ្នាក់នៃអាទិចារីត្រឹមជនទាំង

៥៣. យោងទៅតាមអង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Lubanga* វិធីសាស្ត្រអត្តនោម័ត "គឺជាវិធីសាស្ត្រមួយដែលត្រូវបានយុត្តិសាស្ត្រនៃតុលាការ ICTY យកមកប្រើប្រាស់ តាមរយៈទស្សនទាននៃសហកម្មឧក្រិដ្ឋកម្មរួម ឬទ្រឹស្តីនៃផែនការរួម[141]"។ វិធីសាស្ត្រនេះ "ប្តូរពីការផ្តោតការយកចិត្តទុកដាក់នូវកម្រិតនៃការរួមចំណែកប្រព្រឹត្តបទល្មើស ដែលជាលក្ខណៈវិនិច្ឆ័យសម្គាល់រវាងចារី និងជនសមគំនិត ទៅផ្តោតការយកចិត្តទុកដាក់ទៅលើស្ថានភាពខាងសតិបញ្ញាដែលរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើសវិញ។ ដូច្នេះមានតែជនដែលរួមចំណែកក្នុងចេតនារួមក្នុងការប្រព្រឹត្តិបទល្មើសប៉ុណ្ណោះ ដែលអាចត្រូវបានចាត់ទុកថាជាចារីនៃបទល្មើស ដោយពុំគិតអំពីកម្រិតនៃការរួមចំណែករបស់ពួកគេនៅក្នុងការប្រព្រឹត្តិបទល្មើសឡើយ[142]"។

៥៤. គោលការណ៍នៃការគ្រប់គ្រងលើបទល្មើសដែលអង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Lubanga* បានបង្កើតឡើង ត្រូវបានគេយកមកអនុវត្តក្នុងប្រព័ន្ធច្បាប់ជាច្រើន[143]។ "សញ្ញាណដែលគាំទ្រវិធីសាស្ត្រទី៣ នេះគឺថា ចារីនៃបទល្មើសពុំកម្រិតត្រឹមតែជាជនដែលដែលប្រព្រឹត្តនូវធាតុផ្សំសត្យានុម័តនៃបទល្មើសឡើយ ប៉ុន្តែគឺថារាប់បញ្ចូលផងដែរ ទោះបីជននោះមិនមានវត្តមាននៅកន្លែងកើតហេតុក៏ដោយ នូវជនទាំងឡាយដែលគ្រប់គ្រង ឬជាមេគំនិតចំពោះការប្រព្រឹត្តិបទល្មើសដោយហេតុថាជនទាំងនោះជាអ្នកសម្រេចលើការប្រព្រឹត្តិ និងវិធីនៃការប្រព្រឹត្តិបទល្មើស[144]"។ វិធីសាស្ត្រនេះពាក់ព័ន្ធនឹងធាតុផ្សំសត្យានុម័តមួយ ដែលរួមមានកាលៈទេសៈនៃអង្គហេតុសមស្របនានាសម្រាប់អនុវត្តការគ្រប់គ្រងលើបទល្មើស និងធាតុផ្សំអត្តនោម័តមួយ ដែលក្នុងនោះមានការយល់ដឹង អំពីកាលៈទេសៈអស់ទាំងនេះ[145]។ យោងទៅតាមវិធីសាស្ត្រនេះ មានតែជនដែលមានអំណាចគ្រប់គ្រងលើការប្រព្រឹត្តិបទល្មើស និងជនដែលបានដឹងថាមានការគ្រប់គ្រងបែបនេះប៉ុណ្ណោះ ដែលអាចចាត់ថាជាចារី[146]។

---

ឡាយណាដែលអនុវត្តដោយផ្ទាល់នូវធាតុផ្សំសត្យានុម័តមួយឬច្រើនរបស់បទល្មើសនោះទេ។ *ដូចដើងទំ ព័រខាងលើ,* កថាខណ្ឌ ៣៣៣។

[141] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ ៣២៨។

[142] *ដូចដើងទំព័រខាងលើ*។

[143] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ ៣៣០។

[144] *ដូចដើងទំព័រខាងលើ*។

[145] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ ៣៣១។

[146] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ ៣៣២។

៥៥. អង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Lubanga* បានពន្យល់ថាខ្លួនពុំអាចអនុវត្តតាមវិធីសាស្ត្រអត្តនោម័ត ដូចតុលាការ ICTY បានឡើយ ដោយហេតុថាមាត្រា២៥(៣)(ក) និង២៥(៣)(ឃ) មានភាពខុសគ្នា។ មាត្រា២៥(៣)(ឃ) បានដកចេញពីទស្សនទាននៃសហចារី ដែលមាននៅក្នុងមាត្រា២៥(៣)(ក) និងកំណត់ទស្សនទាននៃការរួមចំណែកក្នុងការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយជនមួយក្រុមធ្វើឡើងតាមផែនការរួមមួយ។ ទស្សនទាននេះនឹងជាមូលដ្ឋាននៃទស្សនទានរបស់ការប្រព្រឹត្តរួមគ្នា នៅក្នុងអត្ថន័យនៃមាត្រា២៥(៣)(ក) ប្រសិនបើអ្នកតាក់តែងសេចក្តីព្រាងបានជ្រើសរើសយកវិធីសាស្ត្រអត្តនោម័ត ក្នុងការបែងចែកឱ្យដាច់ពីគ្នារវាងចារី និងជនសមគំនិត[147]។ អង្គបុរេជំនុំជម្រះក្នុងរឿងក្តី *Lubanga* បានកត់សម្គាល់ឃើញទៀតថា ពាក្យពេចន៍នៃមាត្រា២៥(៣)(ឃ) អនុញ្ញាតឱ្យមានទម្រង់នៃការទទួលខុសត្រូវក្នុងឋានៈជាជនសមគំនិតដែលនៅសេសសល់ ដោយធ្វើឱ្យគេអាចចាត់ទុកថាជាអំពើល្មើស រាល់ការរួមចំណែកណាដែលគេពុំអាចចាត់ទុកបានថាជាការបញ្ជា ការបញ្ចុះបញ្ចូល ការអូសទាញ ការទំនុកបម្រុង ការជម្រុញ ឬការជួយ នៅក្នុងអត្ថន័យនៃមាត្រា២៥(៣)(ខ)ឬ(គ)[148]។

៥៦. ដូច្នេះអង្គបុរេជំនុំជម្រះនៅក្នុងរឿងក្តី *Lubanga* បានសម្រេចថាវិធីសាស្ត្រសំដៅលើ "ការគ្រប់គ្រងលើបទល្មើស" គឺជាវិធីសាស្ត្រដ៏ត្រឹមត្រូវដែលត្រូវអនុវត្តតាម និងបានបែងចែកដាច់ពីគ្នារវាងការទទួលខុសត្រូវជាសមូហភាពតាមមាត្រា២៥(៣)(ឃ) នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីការទទួលខុសត្រូវតាមទម្រង់ JCE ដូចដែលគេបានតាក់តែងឡើងនៅក្នុងយុត្តិសាស្ត្រនៃតុលាការពិសេស[149]។ ក្នុងគ្រាបន្តបន្ទាប់មកទៀត ការថែងអំពីធាតុផ្សំនៃការរួមចំណែកសំខាន់ៗ និងការគ្រប់គ្រងរួមទៅលើលទ្ធផលនៃបទល្មើស ជាក់ស្តែង អង្គបុរេជំនុំជម្រះ ក៏បានបែងចែកដាច់ពីគ្នានូវការប្រព្រឹត្តរួមគ្នា ក្នុងអត្ថន័យនៃមាត្រា២៥(៣)(ក) ពី ការប្រព្រឹត្តរួមគ្នា ផ្អែកតាមអត្ថិភាពនៃ JCE I។ នៅក្នុងរឿងក្តី Katanga អង្គបុរេជំនុំជម្រះបានពន្យល់ថា "តាមរយៈការប្រើប្រាស់វិធីសាស្ត្រចុងក្រោយដែលសំដៅលើការគ្រប់គ្រងបទល្មើស អង្គបុរេជំនុំជម្រះ បានគាំទ្រគោលការណ៍

---

[147] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ ៣៣៤-៣៣៥។

[148] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ ៣៣៦-៣៣៧។

[149] អង្គបុរេជំនុំជម្រះបានពន្យល់ថា "ដោយមិនបានទទួលយកវិធីសាស្ត្រសត្យានុម័ត និង អត្តនោម័ត សម្រាប់ការបែងចែកពីគ្នារវាងអចិចារីនិងអ្នកសមគំនិតក្នុងបទល្មើស ខុសពីយុត្តិសាស្ត្ររបស់តុលាការពិសេស អង្គជំនុំជម្រះក៏ដូចជាអយ្យការពិចារណាថាលក្ខន្តិកៈរួមបញ្ចូលវិធីសាស្ត្រទីបី ដែលពឹងផ្អែកទៅលើទស្សនៈទាននៃការគ្រប់គ្រងលើបទល្មើស"។ *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ៣៣៨។

ចម្បងមួយក្នុងការបែងចែកដាច់ពីគ្នារវាងចារី និងជនសមគំនិតក្នុងបទល្មើស...។ វិធីសាស្ត្រសំដៅលើការគ្រប់គ្រងបទល្មើសត្រូវបានគេយកមកអនុវត្តនៅក្នុងប្រព័ន្ធច្បាប់មួយចំនួន ហើយគេបានទទួលស្គាល់យ៉ាងទូលំទូលាយថែមទៀតផងនៅក្នុងគោលការណ៍ច្បាប់[150]"។

៥៧. ក្នុងន័យឯកភាព អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកឡើងអំពីអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Stakić* នៃតុលាការ ICTY សម្រាប់ធ្វើការពិភាក្សាអំពីទម្រង់នៃសហចារី[151]។ ថ្វីបើអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Stakić* នៃតុលាការ ICTY បានកត់សម្គាល់ឃើញថាការប្រព្រឹត្តរួមគ្នា "ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់និយមន័យ និងយកមកអនុវត្ត" ពុំមានសំអាងគាំទ្រក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬក៏ក្នុងយុត្តិសាស្ត្រជាធរមានរបស់តុលាការនេះ" ហើយផ្ទុយទៅវិញបានអះអាងថា ការទទួលខុសត្រូវ JCE គឺត្រូវបានបង្កើតឡើងយ៉ាងរឹងមាំនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[152] ក៏គេអាចឃើញច្បាស់អំពីការបដិសេធជំទាស់ទៅនឹងសេចក្តីសន្និដ្ឋាននេះ។ ជាក់ស្តែងសាស្ត្រាចារ្យ Ambos អះអាងថា ការបញ្ជាក់អះអាងរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Stakić* នេះ "បង្ហាញថាការពុំអើពើដោយចំហរអំពីគោលការណ៍មូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ ដែលសូម្បីតែអ្នកគាំទ្រតាមគោលការណ៍ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជា អ្នកសរសេរ ល្បួមគិតឡើងវិញអំពីការគាំទ្ររបស់ខ្លួនហើយ[153]"។ អ.វ.ត.ក អាចមិនទទួលស្គាល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Stakić* ដោយគ្មានពន្យល់ហេតុផលទៅលើការយល់ឃើញរបស់ខ្លួនដែលថាអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Stakić* និងតុលាការព្រហ្មទណ្ឌអន្តរជាតិមានកំហុសឆ្គងនោះឡើយ។

៥៨. ការខ្វែងគំនិតគ្នាផ្នែកផ្ទៃក្នុងតុលាការទៅលើការយកការទទួលខុសត្រូវតាមទម្រង់ JCE ទៅអនុវត្តនៅតុលាការ ICTY និង ICTR មានលក្ខណៈគួរឲ្យកត់សម្គាល់[154]។ ហេតុដូច្នេះ ក្នុងពេល

---

[150] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Katanga & Ngdujolo*, ICC-01/04-01/07, សេចក្តីសម្រេចលើការបញ្ជាក់លើការចោទប្រកាន់, ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ ("*Katanga*"), កថាខណ្ឌ ៤៨៤-៨៥។

[151] *សូមមើល* *Lubanga*, កថាខណ្ឌ ៣៤២-៤៣, ៣៤៦។ *Katanga*, កថាខណ្ឌ ៥០៩-១០។

[152] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Stakić*, IT-97-24-A, សាលដីកា, ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ("សាលក្រមក្នុងរឿងក្តី *Stakić*"), កថាខណ្ឌ ៦២។

[153] Ambos Brief, ជើងទំព័រ ៤១។

[154] *សូមមើល ឧទាហរណ៍* សាលក្រមក្នុងរឿងក្តី *Stakić*, កថាខណ្ឌ ៤៣៨-៤២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Simić*, IT-95-9-T, យោបល់ដាច់ដោយឡែក និង ខ្វែងគ្នាដោយផ្នែក របស់ចៅក្រម Per-Johan Lindholm, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣

ពិចារណាអំពីការថ្លែងគំនិតគ្នាទាំងអម្បាលម៉ានដែលមាននៅក្នុងអង្គជំនុំជម្រះតុលាការ ICTY និង ICTR និងកត្តាផ្សេងៗទៀតដូចជាការពិតដែលថា ក) អ្នកតាក់តែងសេចក្តីព្រាងលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិពុំសម្រេចជ្រើសរើសយកទម្រង់នៃការទទួលខុសត្រូវជាសមូហភាព ដូចដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានបង្កើតឡើង ខ) តុលាការព្រហ្មទណ្ឌអន្តរជាតិក្នុងរឿងក្តី Lubanga និង Katanga បានបដិសេធជំទាស់នឹងទ្រឹស្តី JCE ក្នុងរឿងក្តី *Tadić* និង គ) អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ក្នុងចំណោមប្រការផ្សេងៗ មានកំហុសឆ្គងក្នុងការយកលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិមកសំអាង នៅក្នុងការគាំទ្រអំណះអំណាងរបស់ខ្លួនដែលថាទ្រឹស្តី JCE ឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលផ្អែកមូលដ្ឋានលើសន្ធិសញ្ញានានារបស់អង្គការសហប្រជាជាតិ និងគាំទ្រដោយសន្ធិសញ្ញានានារបស់អង្គការសហប្រជាជាតិ គេពុំអាចប្រកែកបានឡើយថាការទទួលខុសត្រូវតាមទម្រង់ JCE ដូចដែលបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* និងដែលត្រូវបានសាបព្រួសបន្ថែមតាមរយៈរឿងក្តីមួយចំនួនផ្សេងទៀតនៅតុលាការ ICTR និង ICTY ដែលយករឿងក្តី *Tadić*ជាមូលដ្ឋានសំអាង[155] ពិតជាពុំបញ្ជាក់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។

## ៣) គ្រោះថ្នាក់ដែលមានជាប់ជាមួយនៃការទទួលខុសត្រូវតាមទម្រង់ JCE បង្កឧបសគ្គដល់ អ.វ.ត.ក ដែលពឹងផ្អែកតាមគោលការណ៍នេះ

៥៩. ក.ស.ច.ស បានប្រកាសថា JCE II "<u>គឺមានលក្ខណៈខុសប្លែកគ្នាបន្តិចពី JCE I</u> ហើយវាទាក់ទិនទៅនឹងប្រព័ន្ធរួមមួយនៃការបំពារបំពានជនរងគ្រោះ ដែលក្នុងនោះជនជាប់ចោទបានដឹងឮអំពីប្រភេទនៃប្រព័ន្ធនោះ ហើយមានចេតនាជម្រុញប្រព័ន្ធរួមនៃការបំពារបំពាននោះ[156]"។ ក.ស.ច.ស ប្រហែលជាប្រកាសសម្រេចដូច្នេះ ដោយហេតុថានេះគឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ

("យោបល់ដាច់ដោយឡែករបស់ចៅក្រម Lindholm ក្នុងរឿងក្តី *Simić*")។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Simić, IT-95-9-A, យោបល់ខ្វែងគ្នារបស់ចៅក្រម Schomburg, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Gacumbitsi*, ICTR-2001-64-A, សាលដីកា, យោបល់ដាច់ដោយឡែករបស់ចៅក្រម Schomburg ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ដើមបណ្តឹងឧទ្ធរណ៍ចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍, ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៦ ("យោបល់ដាច់ដោយឡែករបស់ចៅក្រម Schomburg ក្នុងរឿងក្តី *Gacumbitsi*")។

155 "It must be finally stated that the *opinio juris* <u>is definitely not equivalent to simple 'legal opinions' either by judges or by legal experts in their collective works</u>. In both cases, these 'opinions' do not amount to international custom in the meaning of Article 38(1)(b) of the ICJ Statute." Degan, at 79.

156 ដីកា JCE, កថាខណ្ឌ១៥ (គូសបញ្ជាក់បន្ថែម)។

00438526



តុលាការកំពូលក្នុងរឿងក្តី *Tadić*[157]។ នេះគឺជាឧទាហរណ៍មួយទៀតអំពីគ្រោះថ្នាក់ក្នុងការទទួលស្គាល់សាលដីកាតុលាការកំពូលក្នុងរឿងក្តី *Tadić* ដោយពុំមានធ្វើការវិភាគដោយឯករាជ្យ។ អ្នកស្រាវជ្រាវមួយចំនួនបានពន្យល់ថាការប្រកាសដូច្នេះគឺ មានលក្ខណៈគួរឱ្យភាន់ច្រឡំ និងពុំត្រឹមត្រូវដោយហេតុថា JCE II តែងតែដូច JCE III មិនមែនដូច JCE I នោះទេ[158]។ ដូច្នេះ JCE II រងគ្រោះពីបញ្ហាតែមួយដូចគ្នានឹង JCE III ដែរ ដូចដែលបានពិភាក្សាខាងក្រោម។ យើងសូមលើកយក JCE II មកពិភាក្សាដូចក្រោមនេះ។ សាស្ត្រាចារ្យ Van Der Wilt បានពន្យល់បន្ថែមទៀតថាបញ្ហាដែលពាក់ព័ន្ធជាមួយនឹង JCE II គឺស្ថិតនៅត្រង់ថា "ពាក្យដ៏ស្រពេចស្រពិលដែលថា 'ចេតនាជម្រុញសកម្មភាពបទល្មើស ឬគោលបំណងរបស់ក្រុមនោះ' វាពុំគ្រប់គ្រាន់តាមលក្ខខណ្ឌតម្រូវនៃគោលការណ៍នីត្យានុកូលភាព ដែលថាធាតុផ្សំនានានៃបទល្មើសគួរត្រូវបានព្រាងឱ្យបានច្បាស់លាស់ តាមដែលអាចធ្វើទៅបាននោះទេ[159]"។

៦០. ទាក់ទិននឹងJCE III ក.ស.ច.ស កត់សម្គាល់ឃើញថាចេតនាប្រព្រឹត្តបទល្មើស*mens rea* សម្រាប់ JCE III ដែលអាចយកមកអនុវត្តបាននៅ អ.វ.ត.ក គឺជា "ការទទួលស្គាល់ដោយអត្តនោម័តនូវផលវិបាកតាមធម្មជាតិដែលអាចដឹងមុនបាននៃការអនុវត្តន៍ផែនការរួម[160]"។ ក.ស.ច.ស ពុំពន្យល់អំពីវិធីនៃការកំណត់ដូច្នេះនោះទេ ប៉ុន្តែខ្លួនបានកត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូល

---

[157] *សូមមើល* សាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić*, កថាខណ្ឌ ២០៣។

[158] "ការបរិយាយយ៉ាងល្អិតល្អន់ទៅលើទំនាក់ទំនងរវាងក្រុមទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី [*Tadić*] បានកត់សម្គាល់ឃើញថា ប្រភេទទីពីរគឺពិតជាជម្រើសមួយនៃប្រភេទទីមួយ។ ដំបូងបញ្ហានេះមើលទៅឃើញថាមានលក្ខណៈមិនត្រឹមត្រូវបន្តិចបន្តួច ពីព្រោះប្រភេទទីមួយមានភាពស្រដៀងគ្នាទៅនឹងទស្សនៈទាន Nuremberg ទាក់ទងនឹងការសមគំនិតខណៈដែលប្រភេទទីពីរគឺជាការរំលឹកពីសមាជិកភាពរបស់អង្គការឧក្រិដ្ឋ។ ក្នុងទស្សនៈពិតដែលថា តុលាការ Nuremberg បានច្របាច់ទស្សនៈទានទាំងពីរបញ្ចូលគ្នា ការបង្កើតថ្មីដោយការដាក់បញ្ចូលគ្នាប្រភេទទាំងនេះ ទោះជាយ៉ាងណាប្រហែលជាមិនគួរឱ្យភ្ញាក់ផ្អើលទេ។ យ៉ាងណាក៏ដោយ ក្រុមទាំងនេះ យោងទៅលើបរិបទអង្គហេតុច្បាស់លាស់ ហើយបញ្ហានេះទាមទាឱ្យមានការវាយតម្លៃផ្នែកច្បាប់ផ្សេងគ្នាផងដែរ ពីព្រោះតុលាការ ICTY បានបង្កើតឡើងឆាប់ពេក"។ អត្ថបទរបស់ Harmen van der Wilt, មានចំណងជើងថា *Joint Criminal Enterprise: Possibilities and Limitations*, 5 J. INT'L CRIM. JUST. ទំព័រ៩១, ៩៧ (២០០៧) ("van der Wilt")។ "តាមពិត, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* បានចាត់ទុកទម្រង់នៃការទទួលខុសត្រូវនេះថាមាន 'ទស្សនៈទានស្រដៀងគ្នាជាច្រើន' និង 'រក្សាទុក' លទ្ធិ JCE នេះ ប៉ុន្តែទស្សនៈនេះ ទទួលរងនូវកង្វះខាតខាងការធ្វើឱ្យមានភាពផ្សេងគ្នារវាង ទម្រង់ទាំងឡាយរបស់ JCE ដែលបានបង្កើតឡើងដោយសេចក្តីសម្រេចនេះ"។ Ambos Brief, ទំព័រ១៤។ *សូមមើលផងដែរ* សៀវភៅរបស់ Powles, ទំព័រ ៦០៩-១០។

[159] van der Wilt, ទំព័រ ១០០-០១។

[160] ដីកាសម្រេច JCE, ទំព័រ១០។

ក្នុងរឿងក្តី *Kvočka* បានកម្រិតចេតនាប្រព្រឹត្តបទល្មើស ត្រឹមតែជាផលវិបាកជាអត្តនោម័ត "តាមធម្មជាតិដែលអាចដឹងមុនបាន" ប៉ុណ្ណោះ ថ្វីបើអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* ពុំធ្វើដូច្នេះក៏ដោយ[161]។ ប្រសិនបើចេតនាប្រព្រឹត្តបទល្មើសសម្រាប់ JCE III ពុំត្រូវបានគេទទួលស្គាល់ជាទូទៅនោះទេ គេប្រាកដជាពិបាកយល់អំពីវិធីរបស់ ក.ស.ច.ស ក្នុងការចាត់ទុកទម្រង់ JCEមួយនេះ ថាត្រូវបានគេបង្កើតឡើងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ[162]។

---

161 *ដូចជើងទំព័រខាងលើ,* ជើងទំព័រលេខ ៣៤។ កថាខណ្ឌនៃសាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ដែលត្រូវបានទាញហេតុសំអាងក្នុងជើងទំព័រនេះ សំដៅពិតប្រាកដទៅលើប្រភេទរឿងក្តី JCE II ជាជាង JCE III ប៉ុន្តែមិនបង្ហាញឱ្យឃើញថាពិត ដែលអង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Kvočka* ធ្វើឱ្យមានភាពខុសគ្នាជាសត្យានុម័ត/អត្តនោម័ត ខណៈដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* មិនធ្វើឱ្យមានភាពខុសគ្នាទេ។

162 សាស្ត្រាចារ្យ Olásolo ពន្យល់ពីភាពផ្សេងគ្នារវាងវិធីសាស្ត្រសអត្តនោម័ត និង វិធីសាស្ត្រសត្យានុម័ត ចំពោះតម្រូវការ*ធាតុផ្សំអត្តនោម័ត* របស់ JCE III ដូច្នេះ៖ "ពីទស្សនវិស័យអត្តនោម័ត ទម្រង់លាតសន្ធឹងនៃសហកម្មឧក្រិដ្ឋកម្មរួម តម្រូវឱ្យចុងចោទ (i) ដឹងថាការប្រព្រឹត្តបទល្មើសដែលអាចព្យាករទុកជាមុន គឺជាផលវិបាកនៃការអនុវត្តផែនការណ៍បទល្មើសរួម និង (ii) ត្រូវប្រថុយដោយស្មគ្រចិត្តដោយចូលរួម ឬ បន្តចូលរួមក្នុងសហគ្រាសនោះ។ ជាលទ្ធផល វាក្រសោបយកការធ្វេសប្រហែសដែលគ្មានពីព្រោះចុងចោទមិនត្រូវការដឹងថាមាន '*ភវនីយភាព*' ឬ '*ភវនីយភាពដ៏សំខាន់*' (ហានិភ័យកម្រិតខ្ពស់) ដែលបទល្មើសដែលអាចព្យាករទុកជាមុនបាន នឹងត្រូវបានប្រព្រឹត្ត ដោយផលវិបាននៃការអនុវត្តផែនការណ៍បទល្មើសរួម។ គាត់គ្រាន់តែចាំបាច់ត្រូវដឹងថា ការប្រព្រឹត្តិបទល្មើសដែលអាចព្យាករទុកជាមុននោះ គ្រាន់តែជា 'ផលវិបាកធម្មតា' (ហានិភ័យកម្រិតទាប) នៃការអនុវត្តផែនការណ៍បទល្មើសរួមតែប៉ុណ្ណោះ។ លើសនេះទៀត បើទោះបីជាការពិតដែលថា ចុងចោទគ្រាន់តែចាំបាច់ត្រូវដឹងពីអថិភាពនៃហានិភ័យកម្រិតទាបក៏ដោយ រូបគាត់មិនតម្រូវឱ្យទទួលយក 'យ៉ាងច្បាស់លាស់ ឬ យ៉ាងជាក់លាក់' នូវការប្រព្រឹត្តបទល្មើសដែលអាចព្យាករទុកជាមុននោះទេ។ ផ្ទុយទៅវិញ វាគ្រប់គ្រាន់ដែលថា គាត់ប្រថុយប្រថានដោយចូលរួម ឬ បន្តចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួម។ <u>ត្រង់នេះគូសបញ្ជាក់ពីភាពខុសគ្នាដ៏សំខាន់មួយ ជាមួយនឹងទស្សនៈទាននៃគោលការណ៍ *dolus eventualis* ដែលយោងតាម អង្គបុរេជំនុំជម្រះ I នៃតុលាការ ICC បង្កើតឱ្យមានចេតនាកម្រិតទាបបំផុត។</u> <u>ទោះជាយ៉ាងណាក៏ដោយសម្រាប់ចារីខ្លះ ទម្រង់លាតសន្ធឹងនៃសហកម្មឧក្រិដ្ឋកម្មរួម ក៏អាចត្រូវបានអនុវត្តក្នុងស្ថានភាពដែលចុងចោទមិនបានដឹងថា ការប្រព្រឹត្តបទល្មើសដែលអាចព្យាករទុកជាមុន គឺជាផលវិបាកដែលអាចកើតឡើង នៃការអនុវត្តផែនការឧក្រិដ្ឋកម្មរួម។</u> ជាសត្យានុម័ត ដរាបណាចុងចោទស្ថិតនៅក្នុងឋានៈដែលដឹងជាមុនពីលទ្ធភាពនោះ វាជាប់ទាក់ទងទោះជាគាត់ពិតជាដឹងវាជាមុនឬមិនដឹងក៏ដោយ"។ សៀវភៅរបស់ Olásolo, មានចំណងជើងថា *Joint Criminal Enterprise and its Extended Form,* ទំព័រ ២៧៩-៨១ (ឆ្នាំ២០០៩) (គូសបញ្ជាក់បន្ថែម)។ នៅក្នុងទស្សនៈរបស់ Olásolo "ការអនុវត្តវិធីសាស្ត្រនេះ និងបង្កើតឱ្យមានការណែនាំបទដ្ឋានធ្វេសប្រហែស ដែលចុងចោទនឹងត្រូវផ្តន្ទាទោសពីបទរំលោភកាតព្វកិច្ចរបស់ខ្លួន ដើម្បីប្រព្រឹត្តដោយដឹងខ្លួនឯងក្នុងពេលនោះ នូវការវិភាគពីផលវិបាកដែលអាចកើតមានពីការអនុវត្តផែនការណ៍បទល្មើសរួម មុនពេលចូលរួមក្នុងផែនការនោះ"។ *ដូចជើងទំព័រខាងលើ។ សូមមើលផងដែរ* អត្ថបទរបស់ Jenia Iontcheva Turner, មានចំណងជើងថា *Defense Perspectives on Law and Politics in International Criminal Trials,* 48 VA. J. INT'L L. ទំព័រ៥២៩, ៥៦១ (២០០៨) (គូសបញ្ជាក់បន្ថែម)៖ "ក្រោមទម្រង់ [JCE III] ប្រសិនបើអព្យាការបង្ហាញថា ចុងចោទមានចេតនាចូលរួមក្នុងផែនការណ៍រួម

៦១. ក្រៅពីបញ្ហានៃធាតុផ្សំផ្នែកស្មារតីដែលចាំបាច់ ក៏នៅមានបញ្ហាមួយចំនួនផ្សេងទៀតទាក់ទិននឹង JCE III។ ជាក់ស្តែងដូចជា៖

ចំពោះ JCE III យើងហាក់បីដូចជាឃើញច្បាស់ថា ការចោទអំពីអំពើដែលថាជា "ផលវិបាកដែលអាចដឹងមុន" ដែលពីដើមដំបូងពុំត្រូវបានគេឯកភាព ហើយពុំត្រូវបានគិតទុកជាមុនដោយអ្នកចូលរួមទាំងអស់នោះ ពិបាកនឹងអាចទុកថាជាទម្រង់មួយនៃការប្រព្រឹត្តរួមគ្នា ឬចារីណាស់ ប្រសិនបើគេតម្រូវ ដូចដែលពន្យល់ខាងលើ គឺថាជនជាប់ចោទ ជាអ្នកបំពេញនូវធាតុផ្សំទាំងអស់ទាំអត្តនោម័ត និងសត្យានុម័តនៃបទល្មើស។ នៅក្នុង JCEIII ធាតុផ្សំមួយ ឬច្រើនបានកំពុងបាត់បង់ និងត្រឹមតែការចោទប្រកាន់ថាជាសមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួមប៉ុណ្ណោះតាមរយៈ *ការទទួលខុសត្រូវជំនួស (vicarious liability)* ដូចជាតាមរយៈការជំនួសអំពើរបស់ជនដទៃ របស់ចារីពិតប្រាកដ ដោយផ្ទេរអំពើនេះទៅឱ្យ "ជនដែលពុំមានជាអ្នកប្រព្រឹត្ត" ឬជា "អំពើដែលពុំបានប្រព្រឹត្ត" របស់សមាជិកនោះ។ ប៉ុន្តែ អំពើដែលពុំបានប្រព្រឹត្ត អាចត្រូវបានចាត់ទុកថាជាទម្រង់នៃការជួយទំនុកបម្រុងបទល្មើសតែប៉ុណ្ណោះ។ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែមដោយគោលការណ៍ប្រពៃណីមួយរបស់ប្រទេសអង់គ្លេស ដែលបានកំណត់ជាយូរលង់មកហើយថា អ្នកចូលរួមក្នុងផែនការបទល្មើសរួម គឺជាចារី (ត្រឹមតែ) ក្នុងកម្រិតបន្ទាប់បន្សំប៉ុណ្ណោះ (ដូចជា អ្នកសមគំនិត)

---

ចុងចោទនឹងត្រូវទទួលខុសត្រូវចំពោះបទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តឡើងដោយអ្នកផ្សេងដែលរូបគាត់មិនមានចេតនាដរាបណាបទល្មើសទាំងនោះអាចព្យាករណ៍ទុកជាមុនបាន។ <u>តុលាការមួយចំនួនបានបកស្រាយពាក្យ អាចព្យាករណ៍ទុកជាមុនថាមានន័យថា 'ការព្យាករជាមុនជាសត្យានុម័ត' មានន័យថា ចុងចោទអាចត្រូវបានផ្តន្ទាទោសសូម្បីតែចំពោះបទល្មើសទាំងឡាយណា ដែលរូបគាត់មិនបានព្យាករណ៍ទុកជាមុនក៏ដោយ។</u> ដូចដែលអ្នកអត្ថាធិប្បាយច្បាប់ និង មេធាវីការពារក្តីបានកត់សម្គាល់ ការបកស្រាយទាំងនេះបន្ទាបចេតនាដែលចាំបាច់សម្រាប់ការទទួលខុសត្រូវចំពោះការធ្វេសប្រហែស ឬ ក្នុងករណីការសាកល្បង 'លទ្ធភាពព្យាករជាមុនជាសត្យានុម័ត' ចំពោះការធ្វេសប្រហែស។ សមាគមន៍មេធាវីការពារក្តីនៅតុលាការ ICTY បានរិះគន់លទ្ធិនេះថាទូលំទូលាយពេក និង 'ងាយនឹងមើលរំលង និង រំលោភ'។ ប្រព័ន្ធច្បាប់ជាតិជាច្រើន ក៏បានបដិសេធការអនុវត្តលាតសន្ធឹងនៃការទទួលខុសត្រូវបទល្មើស។ សូម្បីតែនៅក្នុងប្រទេសដែលទទួលយកការទទួលខុសត្រូវចំពោះបទល្មើសដែលមិននៅក្នុងទំហំនៃផែនការណ៍រួមក៏ដោយ ក៏ការទទួលខុសត្រូវនេះជារើយៗត្រូវបានរិះគន់ថាជាពិរុទ្ធភាពដោយការមានទំនាក់ទំនង"។ *សូមមើលផងដែរ* Ambos Brief, ទំព័រ ៩-១០, ដែលសាស្ត្រាចារ្យ Ambos ពន្យល់ថា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ខកខានមិនបានបញ្ជាក់ពីទម្រង់ត្រឹមត្រូវនៃការចូលរួមក្នុង JCE, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Kvočka* "បានជ្រើសរើសដំណោះស្រាយជាសត្យានុម័ត" និង បានចាត់ទុកភាពផ្សេងគ្នារវាងការជួយនិងការជម្រុញ និងការប្រព្រឹត្តរួមគ្នា ថាជាដំណោះស្រាយអត្តនោម័ត។

ទាក់ទិនទៅនឹងគ្រប់បទល្មើស ដែលត្រូវបានប្រព្រឹត្តដោយជនណាម្នាក់នៅក្នុងការអនុវត្តគោលបំណងនោះ[163]។

៦២. JCE III ក៏ពុំស្របជាមួយនឹងគោលការណ៍នៃពិរុទ្ធភាពផងដែរ "ដោយហេតុថាវាឱ្យអ្នកចូលរួមក្នុងសហកម្មឧក្រិដ្ឋកម្មរួមទទួលខុសត្រូវចំពោះបទល្មើសរបស់អ្នកចូលរួមដទៃទៀត ដែលគេពុំបានឯកភាព ពីខាងដើម ដោយហេតុថាបទល្មើសទាំងនោះអាចដឹងមុនបាន[164]"។ សញ្ញាណដែលថាអ្នកចូលរួមអាចមានទោសចំពោះបទល្មើសដែលគ្រាន់តែ "អាចដឹងមុនបាន" គឺមានបញ្ហាចោទ ដោយសារប្រសិនបើមានការកំណត់ជាសត្យានុម័តមួយ អំពីថាតើបទល្មើសទាំងនោះអាចឱ្យគេដឹងមុនបានគ្រប់គ្រាន់ឬយ៉ាងណានោះ នោះជនជាប់ចោទអាចមានទោសចំពោះបទល្មើសដែលគាត់ពុំអាចដឹងមុនបាន។ ប៉ុន្តែ ប្រសិនបើគេប្រើវិធីសាស្ត្រសត្យានុម័ត ភាគីអយ្យការត្រូវបង្ហាញថា "ជនជាប់ចោទបានដឹងគ្រប់គ្រាន់ ថាបទល្មើសបន្ថែមគឺជាផលវិបាកដែលអាចដឹងមុននិងអាចកើតឡើងតាមធម្មជាតិ[165]"។ ប៉ុន្តែ "ជនជាប់ចោទណាមួយដឹងថាលទ្ធផលជាក់លាក់មួយនឹងកើតឡើង ឬលទ្ធផលនេះជនជាប់ចោទអាចដឹងមុនបាន ទាំងពីនេះគឺមិនអាចទៅរួចសមហេតុសមផលនោះទេ។ ជាការពិត ការដឹងឮគឺជាបទដ្ឋានមួយសម្រាប់បទល្មើសដែលមានចេតនាប្រព្រឹត្ត (មើលមាត្រា ៣០ លក្ខន្តិកៈតុលាការ ICC) ខណៈដែលភាពអាចដឹងមុនបានគឺជាពាក់ព័ន្ធទៅនឹងទ្រឹស្តីនៃធ្វេសប្រហែស ឬពុំយកចិត្តទុកដាក់[166]"។

---

[163] Ambos Brief ទំព័រ ១៣។

[164] ដូចជើងទំព័រខាងលើ ត្រង់ ១ សូមមើល ដូចជើងទំព័រខាងលើ ត្រង់ ១៥-១៩ Fletcher & Ohlin *Reclaiming Fundamental Principles* ត្រង់ ៥៥០៖ "ការរិះគន់លើកទី២របស់យើង ... គឺអំពីខ្លឹមសារនៃគោលការណ៍ តែម្តង។ គោលការណ៍នេះចាត់ទុកយ៉ាងច្បាស់ថាភាគីទាំងអស់ក្នុងបទសមគំនិត ត្រូវមានភារៈទទួលខុសត្រូវស្មើៗគ្នាចំពោះអំពើបទល្មើសរបស់ក្រុមនោះ ដោយមិនគិតអំពីតួនាទី និងការបំពេញមុខងារ របស់សមាជិកម្នាក់ៗ នៅក្នុងការប្រព្រឹត្តិបទល្មើស។ ការបកស្រាយ គោលការណ៍នេះពិតជារំលោភគោលការណ៍មូលដ្ឋានដែលថា បុគ្គលម្នាក់ៗ គួរត្រូវបានផ្តន្ទាទោសចំពោះអ្វីដែលខ្លួនទទួលខុសត្រូវ។ តាមរយៈការពុំអើពើនូវភាពខុសគ្នាដែលពាក់ព័ន្ធរវាងសមាជិកនៃក្រុមសមគំនិតគ្នា គោលការណ៍នេះបានលុបចោលនូវភាពខុសគ្នារវាងអ្នកផ្តួចផ្តើមគំនិតបទល្មើសធ្ងន់ធ្ងរ និងជនដែលបាន ចូលរួមត្រឹមតែក្នុងលក្ខណៈបន្ទាប់បន្សំ។ ការពុំអើពើភាពខុសគ្នានេះគឺជាការជាន់ឈ្លីគោលការណ៍សីលធម៌ជាមូលដ្ឋាន ដែលផ្តល់មូលដ្ឋានគ្រឹះដល់ការទទួលខុសត្រូវចំពោះបទល្មើស និងការផ្តន្ទាទោស។ បុគ្គលម្នាក់ៗគួរត្រូវផ្តន្ទាទោស ទៅតាមការទទួលខុសត្រូវរបស់គេតែរៀងៗខ្លួន"។

[165] រដ្ឋអាជ្ញា ទល់នឹង *Kvočka* IT-98-30/1-A ,សាលដីកា ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ៨៦។

[166] Ambos Brief ទំព័រ១៧។ កត់សម្គាល់ឃើញថា អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* អាចជាអ្នកបង្កើតការភាន់ច្រឡំ ពីព្រោះចៅក្រម Cassese អ្នកសរសេរសាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី *Tadić* ប្រហែលជាពុំយល់ឱ្យបានត្រឹមត្រូវ នូវអត្ថន័យនៃពាក្យថា *dolus eventualis*។ "សាស្ត្រាចារ្យ Cassese សរសេរថា "ភាពធ្វេសប្រហែស" មានន័យដូចគ្នានឹងពាក្យថា

## ៥) ប្រសិនបើ JCE ត្រូវបានទទួលស្គាល់ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការយកវាមកអនុវត្តត្រូវកំណត់ត្រឹមតែ ជាការប្រព្រឹត្តរួមគ្នាប៉ុណ្ណោះ ពោលគឺដូចមានចែងក្នុងច្បាប់កម្ពុជា

៦៣. សាស្ត្រាចារ្យ Ambos ពន្យល់ថា JCE I អាច (និងគួរតែ) ប្រៀបប្រដូចទៅនឹងសញ្ញាណនៃ "ការប្រព្រឹត្តរួមគ្នា"[167] នៅក្នុងប្រព័ន្ធ Civil Law ដែរ។ តាមសាស្ត្រាចារ្យ Ambos "លក្ខខណ្ឌចាំបាច់របស់ការប្រព្រឹត្តរួមគ្នា <u>គ្រាន់តែបំពេញដោយ JCE I</u> និង <u>លុះត្រាតែ</u> វាត្រូវបានបកស្រាយថាជារចនាសម្ព័ន្ធមួយបែបសត្យានុម័តផងនិងអត្តនោម័តផង ដោយតម្រូវឱ្យមានលើសពីគោលបំណងរួម ឬ ឆន្ទៈរួម (ធាតុ*អត្តនោម័ត*) នៃការប្រព្រឹត្តពិតប្រាកដនៃសកម្មភាពមួយ (ឬច្រើន) ដោយសមាជិកម្នាក់(ច្រើននាក់) នៃក្រុមនោះ (*ធាតុសត្យានុម័ត*)"[168]។ សាស្ត្រាចារ្យ Ambos ជឿថាវាជាចេតនារបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ពេលដែលតុលាការនេះហៅ JCE I ថាជា "ការប្រព្រឹត្តរួមគ្នា" និងបានប្រើក្នុងរឿងក្តីពាក់ព័ន្ធនឹងរឿងនៅអាល្លឺម៉ង់ និង អ៊ីតាលី[169]។ អតីតចៅក្រមមួយរូបនៅ ICTY ឈ្មោះ Per-Johan Lindholm

---

*dolus eventualis* ប៉ុន្តែនេះពុំត្រឹមត្រូវទេ។ ពាក្យថា *dolus eventualis* ត្រូវគេប្រើប្រាស់នៅក្នុងអក្សរសាស្ត្រទ្វីប ដើម្បីរៀបរាប់អំពីព្រំដែននៃការសម្លាប់ដោយចេតនា។ ភាពធ្វេសប្រហែស ចង់ផ្តោតទៅលើហានិភ័យដែលចារីមានឆន្ទៈនឹងប្រឈម ប៉ុន្តែ *dolus eventualis* គឺនិយាយអំពីអាកប្បកិរិយារបស់អ្នក ប្រព្រឹត្តដោយពុំគិតពីហានិភ័យនៃមហន្តរាយ។ អំពើដែលអាចផ្តន្ទាទោសបានដូចដែលបានកំណត់នៅក្នុងអក្សរសាស្ត្រ អាល្លឺម៉ង់ និងច្បាប់យុត្តិសាស្ត្រ គឺជាការឯកភាព និងការកំណត់ជាមួយលទ្ធផលអាក្រក់។ ប្រសិនបើគោលបំណងនៃកង ប្រដាប់អាវុធគឺដើម្បីកម្ចាត់ទីតាំងកងទ័ពបដិបក្ខ ហើយពួកគេដឹងថាជាលទ្ធផលនឹងធ្វើឱ្យមនុស្សស្លាប់ នោះអាកប្បកិរិយា របស់ពួកគេបែបនេះពុំមែនជា *dolus eventualis*ឡើយ។ ការសម្លាប់របស់ពួកគេគឺ *dolus* ប្រសិនបើពួកគេដឹងថាមនុស្ស មួយចំនួននឹងត្រូវស្លាប់ ហើយឯកភាព និងចង់ឱ្យមានលទ្ធផលនេះនៅក្នុងចិត្ត និងសម្រេចបន្តធ្វើដូច្នោះទៀត។ ប្រសិនបើ អំពើនោះជាការសម្លាប់ដោយធ្វេសប្រហែស នោះគេនឹងសង្កត់ធ្ងន់ទៅលើទម្ងន់នៃហានិភ័យ និងផលប្រយោជន៍ខាងយោធា នៃប្រតិបត្តិការនោះ Fletcher & Ohlin, *Reclaiming Fundamental Principles* ត្រង់៥៥៤។

[167] ការដាក់សារណារបស់ Ambos ទំព័រ ៩-១៣ ។ ចំពោះបញ្ហាដែលកើតមាន ប្រសិនបើ JCE I មិនត្រូវបានប្រៀបប្រដូចនឹង "ការប្រព្រឹត្តរួមគ្នា"។ សូមមើល *ដូចដើងទំព័រខាងលើ* ទំព័រ ៩-១៣។

[168] *ដូចដើងទំព័រខាងលើ* ទំព័រ ១១។

[169] *ដូចដើងទំព័រខាងលើ* សូមមើលផងដែរ Kai Ambos, សហកម្មឧក្រិដ្ឋកម្មរួម និងការទទួលខុសក្នុងការបញ្ជា, 1 J. INT'L CRIM. JUST. 1, 12 (2007), ដែលគាត់គូសបញ្ជាក់ថា "តាមការពិតអង្គជំនុំជម្រះឧទ្ធរណ៍ *Tadić* បានទទួលស្គាល់អត្តសញ្ញាណរវាងការប្រព្រឹត្តរួមគ្នា និង JCE I យ៉ាងហោចណាស់ ជាវិជ្ជាយុត្តសព្ទ ដោយហៅ JCE I "ការប្រព្រឹត្តរួមគ្នា" ហើយប្រៀបធៀបជាមួយពាក្យ *ការប្រព្រឹត្តរួមគ្នា* ដូចបានយកមកប្រើក្នុងរឿងក្តីក្រោយសង្គ្រាមលោកលើកទី២ រវាងប្រទេសអាល្លឺម៉ង់

ក៏មានទស្សនៈថា JCE I អាចប្រៀបប្រដូចនឹងការប្រព្រឹត្តរួមគ្នាដែរ។ គាត់បានពន្យល់ថា "តាមទស្សនៈរបស់ខ្ញុំ ទម្រង់ដែលគេហៅថាទម្រង់ជាមូលដ្ឋាននៃសហកម្មឧក្រិដ្ឋកម្មរួមមិនមានធាតុផ្សំអ្វីទេ។ វាគ្មានអ្វីក្រៅតែពីការដាក់ស្លាកភ្ជាប់ទៅនឹងទស្សនៈ ឬ ទ្រឹស្តីដែលល្បីល្បាញតាំងពីយូរមកហើយ នៅក្នុងយុត្តាធិការភាគច្រើន រួមទាំងច្បាប់អន្តរជាតិផង ដែលគេហៅថា ការប្រព្រឹត្តរួមគ្នា"[170]។

៦៤. ដោយសារការប្រព្រឹត្តរួមគ្នាគឺជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលមានចែងក្នុងច្បាប់កម្ពុជាហើយនោះ មិនមែនមូលហេតុអ្វីដែលត្រូវអនុវត្ត JCE I ជាទម្រង់នៃការទទួលខុសត្រូវមួយដោយឡែក ផ្សេងទៀតនោះទេ[171]។ មុខងារចម្បងរបស់ អ.វ.ត.ក គឺដើរតួជា "គំរូ" មួយសម្រាប់តុលាការកម្ពុជា។ ហេតុនេះ វាជាការមានសារៈប្រយោជន៍ដល់តុលាការកម្ពុជា ដែលឃើញពីទម្រង់នៃការទទួលខុសត្រូវមួយ ដែលបានអនុវត្តនៅកម្ពុជារួចមកហើយ ត្រូវបានគេយកទៅបកស្រាយជាជាងនាំចូលទម្រង់នៃការទទួលខុសត្រូវមួយពីបរទេស ដែលមិនអាចអនុវត្តបាននៅក្នុងតុលាការកម្ពុជាផ្សេងៗទៀត ជាពិសេសវានាំមកនូវលក្ខណៈចម្រូងចម្រាសផង។

៦៥. ជាងនេះទៅទៀត រដ្ឋាភិបាលកម្ពុជាបានបដិសេធយ៉ាងច្បាស់លាស់នូវការទទួលខុសត្រូវ JCE។ កម្ពុជាបានអនុម័តក្រមព្រហ្មទណ្ឌថ្មីមួយដែលរៀបរាប់នូវចារី និង ការប្រព្រឹត្តរួមគ្នា គឺជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាននៅកម្ពុជា[172]។ ក្រមព្រហ្មទណ្ឌនេះត្រូវបានអនុម័ត ដោយសម្លេង ៩៩ ទល់នឹង ៣ បន្ទាប់ពីបានពិភាក្សាដេញដោលរយៈពេល ៨ ថ្ងៃ[173]។ ចំណុចនេះបង្ហាញថា នេះជាការសម្រេចចិត្តដែលមានព័ត៌មានយ៉ាងប្រុងប្រយ័ត្ន តំណាងនូវឆន្ទៈរបស់ប្រជាជន។ ហេតុនេះ វាជាឆន្ទៈរបស់រដ្ឋាភិបាលកម្ពុជាដែលថា ទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តនៅ

---

និងអ៊ីតាលី។ ជាខ្លឹមសារ ក្នុងពាក្យពេចន៍នៃសេចក្តីសម្រេចជាឯកច្ឆន្ទ័ផ្សេងៗរបស់អង្គជំនុំជម្រះតុលាការកំពូល កំណត់ថាអ្នកចូលរួម "ប្រព្រឹត្តអំពើ [ដោយសត្យានុម័ត] ដែលទទួលបានណែនាំឲ្យអនុវត្តផែនការ ឬគោលបំណងរួម កាន់តែប្រសើរ"។ ដូច្នេះ JCE I ជាទម្រង់មួយនៃការចូលរួម ដែលបានយកគំរូតាមការប្រព្រឹត្តរួមគ្នាក្នុងប្រពន្ធ័civil law និងគម្រោង/គោលបំណងរួមក្នុងប្រពន្ធ័ common law ។

[170] *Simić* មតិដោយឡែករបស់ចៅក្រម Lindholm កថាខ័ណ្ឌ២។

[171] កំណត់សម្គាល់ដែលថា ក.ស.ច.ស បានទទួលស្គាល់ថា ការទទួលខុសត្រូវ JCE មិនឃើញមាននៅក្នុងច្បាប់កម្ពុជាទេ ។ *សូមមើល* ដីកាសេចក្តីសម្រេច JCE កថាខ័ណ្ឌ២២។

[172] *សូមមើល* មាត្រា ២៥-២៦ ក្រមព្រហ្មទណ្ឌកម្ពុជាថ្មី អនុម័តឆ្នាំ ២០០៩ (បកប្រែក្រៅផ្លូវការ)។

[173] សូមមើល **ជន សក្តា** *រដ្ឋសភាជាតិអនុម័តក្រមព្រហ្មទណ្ឌ* ព័ត៌មាន ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ អាចមើលបានក្នុង http://www.voanews.com/khmer/2009-10-12voa9.cfm?renderforprint=1.។

កម្ពុជា ត្រូវតែដើរតាម គំរូនៃការប្រព្រឹត្តបទល្មើស/ការប្រព្រឹត្តរួមគ្នា និង មិនមែនគំរូបែប JCE ទេ។ ជាក់ស្តែង គំរូបែប JCE មិនត្រូវបានគេអនុម័តទទួលយកទេ។

**ឃ. ក.ស.ច.ស មានកំហុសឆ្គងក្នុងការរកឃើញថា JCE គឺជាទម្រង់មួយនៃការ "ប្រព្រឹត្ត"។ JCE មិនអាចត្រូវចាត់ទុកថាជា "ការប្រព្រឹត្ត" ក្រោមមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហេតុនេះមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ។**

៦៦. ទោះបី ការទទួលខុសត្រូវ JCE ត្រូវបានគេរកឃើញថា មាននៅក្នុងទម្លាប់អន្តរជាតិ ក្នុងឆ្នាំ ១៩៧៥-៧៩ ក៏ដោយ ហើយសូម្បីតែមានឧបសគ្គចម្រូងចម្រាស់ជាក់ស្តែងតាមរយៈទស្សនៈអ្នកច្បាប់ និង ការអនុវត្តន៍ជាក់ស្តែង មិនត្រូវបានគេអើពើ ដែលធ្វើប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ និង គោលការណ៍នៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ និង នីត្យានុកូលភាពក៏ដោយ ក៏ JCE មិនអាចត្រូវបានគេចាត់ទុកថាជា ទម្រង់មួយនៃការ "ប្រព្រឹត្ត" តាមមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ទេ។ ដូចបានលើកឡើងដោយអតីតចៅក្រមអង្គជំនុំជម្រះតុលាការកំពូលនៅ ICTY/ICTR មួយរូបឈ្មោះ Wolfgang Schomburg ថា "ការប្រព្រឹត្ត" មានន័យខុសៗគ្នាទៅតាមប្រព័ន្ធច្បាប់ដែលខុសៗគ្នា[174]។ នៅកម្ពុជា ដូចបានពិភាក្សាពីខាងដើម "ការប្រព្រឹត្ត" គឺមានន័យថាជាការប្រព្រឹត្តរួមគ្នា។ ក.ស.ច.ស មិនមានការប៉ុនប៉ងពន្យល់ពីរបៀបដែលទម្រង់ខុសៗគ្នានៃ JCE ដែលបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* អាចស្របទៅនឹងនិយមន័យនេះទេ[175]។

---

[174] គោលគំនិតនៃសហកម្មឧក្រិដ្ឋកម្មរួម មិនត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់ក្នុងលក្ខន្តិកៈ [ICTY] ហើយវាមិនមែនជាលទ្ធភាពតែមួយដើម្បីបកស្រាយ "ការប្រព្រឹត្ត" ដែលមានទំនាក់ទំនងនឹងបទឧក្រិដ្ឋ ក្រោមលក្ខន្តិកៈ ICTR និង ICTY ។ <u>ទោះជាយ៉ាងណា ក្នុងប្រពន្ធ័ច្បាប់ផ្សេងគ្នា "ការប្រព្រឹត្ត" ត្រូវបានបកស្រាយៗខុសគ្នា</u> ។ ចាប់ពីមានករណី Nuremberg និង Tokyo ច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ បានទទួលស្គាល់ ជាពិសេសនូវការប្រព្រឹត្តរួមគ្នា និងចារីដោយប្រយោល (តាមរយៈបទល្មើស) ថាជាទម្រង់មួយនៃ "ការប្រព្រឹត្ត" ។ *Gacumbitsi* ដែលជាមតិដោយឡែករបស់ចៅក្រម Schomburg កថាខ័ណ្ឌ ១៦ (បន្ថែមការសង្កត់ន័យនៃឃ្លា)។ ចំពោះការពន្យល់បន្ថែមពីមូលហេតុដែល JCE មិនមានន័យបង្កប់ក្នុងពាក្យ "ការប្រព្រឹត្ត" ក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក សូមមើល ឧបសម្ព័ន្ធ ក ផ្នែក II ក(២) ។

[175] ដូចបានពិភាក្សាក្នុងផ្នែកមុន ការអះអាងដែលថា JCE ជាសាមញ្ញ ជាទម្រង់នៃការ "ការប្រព្រឹត្ត" រកមិនបានការគាំទ្របន្ថែមក្នុងច្បាប់ករណីសង្គ្រាមលោកលើកទី២ទេ ។ សាលាក្តីយោធាអន្តរជាតិ ចាត់ទុកការទទួលខុសត្រូវនៃអ្នកចូលរួមអនុវត្តផែនការរួមប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមជាអ្នកសមគំនិត S. Pomorski *ការសមគំនិតគំនិត និងការរៀបចំចាត់ចែងបទ*

៦៧. អ.វ.ត.ក មិនអាចគ្រាន់តែជ្រើសរើសគំរូដែលមិនស្របនឹងប្រព័ន្ធ Civil Law នោះទេ។ ទោះបីការទទួលខុសត្រូវ JCE បានអនុវត្តនៅតាមតុលាការ*ពិសេស ad hoc* ដែលតុលាការទាំងនេះប្រើប្រាស់ប្រព័ន្ធចម្រុះដែលមានឥទ្ធិពលខ្លាំងក្លាពីប្រព័ន្ធ Common Law ក៏ដោយ តែ អ.វ.ត.ក មិនដើរតាមប្រព័ន្ធនេះទេ[176]។ ដោយហេតុថា អ.វ.ត.ក អនុវត្តតាមគំរូប្រព័ន្ធ Civil Law វាជាការសមហេតុផលដែលបកស្រាយអត្ថន័យនៃពាក្យ "បានប្រព្រឹត្ត" យ៉ាងតឹងរឹង ថាត្រឹមតែយោងទៅរកការប្រព្រឹត្តរួមគ្នាតែប៉ុណ្ណោះ[177]។

៦៨. ក.ស.ច.ស មិនបានពន្យល់ពីរបៀបដែល JCE ត្រូវបានចាត់ទុកថាជាទម្រង់នៃការប្រព្រឹត្ត តែគ្រាន់តែប្រកាសថា វាអាចចាត់ទុកដូច្នេះបាន ពីព្រោះអង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić*

---

*ឧក្រិដ្ឋ* ក្នុង G. GINSBERG & V. N. KUDRIAVTSEV (EDS.) *សវនការ* NUREMBERG និងច្បាប់អន្តរជាតិ ២២៣ (Martinus Nijhoff Publishers, 1990) ។ ដូច្នេះសាលាក្តីយោធាក្នុងស្រុក បកស្រាយ ខុសគ្នានូវពាក្យការទទួលខុសត្រូវនៃគោលបំណងរួម ដោយផ្អែកលើទម្រង់នៃការចូលរួមដែលទទួលយកដោយប្រពន្ធ័ច្បាប់ជាតិរៀងៗខ្លួនរបស់ពួកគេ។ *សូមមើល e.g., Otto Sandrock et al.* របាយការណ៍ ច្បាប់នៃសវនការនៃឧក្រិដ្ឋជនសង្គ្រាម (UNWCC), Vol. I, London: His Majesty's Stationary Office, 1949, ទំព័រ ៤០-៤៣; *Frantz Holstein et al.*, UNWCC, Vol. VIII, ទំព័រ ២៦-៣៣ ។ *សូមមើលផងដែរ* BOAS, at 141 ដែលលោក Gideon Boas អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ ICTY ពន្យល់ថា ទោះជាទម្រង់ដទៃទៀតនៃការទទួលខុសត្រូវ ដែលត្រូវបានចោទថាមិនដល់កំរិត JCE ក៏ដោយ ក៏ទម្រង់នោះអាចឆ្លុះបញ្ចាំងពីការប្រព្រឹត្តដែលអាចដាក់ទោសបានរបស់ជនជាប់ចោទ ត្រឹមត្រូវជាង "ការប្រព្រឹត្ត" ក្នុងទម្រង់ JCE ។

[176] "ទស្សនៈ ... ថា សហកម្មឧក្រិដ្ឋកម្មរួម គឺប្រហាក់ប្រហែលគ្នានឹង 'ការប្រព្រឹត្ត' បទឧក្រិដ្ឋដែរ។ ... វិវាទចំពោះអត្ថន័យធម្មតានៃពាក្យថា 'ការប្រព្រឹត្ត' គឺជាចារីនៃបទឧក្រិដ្ឋណាមួយ ឬ ជាការលុបចោលដោយកំហុសដែលផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ ហេតុនេះ គោលការណ៍ទូទៅនោះគឺថា រាល់ច្បាប់ព្រហ្មត្រូវតែបកស្រាយក្នុងន័យចង្អៀត"។ Darcy ទំព័រ ៣៨៤។ បើពិចារណាទៅលើន័យសាម័ញ្ញនៃពាក្យថា "បានប្រព្រឹត្ត" វាជាការលំបាកក្នុងការយល់ពីរបៀបដែលទម្រង់ JCE អាចត្រូវបានចាត់ក្រោមអត្ថន័យនៃពាក្យនេះ។ ដូច Powles ពន្យល់ថា "វាជាការងាយស្រួលក្នុងការយល់ពីរបៀបដែលជនណាម្នាក់មានពិរុទ្ធក្នុងការចូលរួមក្នុងប្រភេទទីមួយនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលអាចត្រូវបាននិយាយថាបាន 'ប្រព្រឹត្ត' បទល្មើស។ ក៏ប៉ុន្តែ វាជាការលំបាកពេលឃើញពីរបៀបដែលជនណាម្នាក់មានពិរុទ្ធភាពក្នុងការចូលរួមក្នុងប្រភេទទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម មានន័យថា ពេលដែលបទឧក្រិដ្ឋនោះចេញ *ឆ្ងាយ* ពីកម្មវត្ថុនៃសហកម្មឧក្រិដ្ឋកម្មរួម វាអាចនិយាយបានថា ពិតជា 'បានប្រព្រឹត្ត' បទឧក្រិដ្ឋដែលកំពុងពិភាក្សានេះ ពេលដែលពួកគេមិនមានចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនោះពិតប្រាកដ និង អាចមិនបានដឹងពីបទឧក្រិដ្ឋនោះពីមុនមកទេ ក្នុងពេល និង សូម្បីតែបន្ទាប់ពីបទឧក្រិដ្ឋនោះបានប្រព្រឹត្តក៏ដោយ។ ជាសង្ខេប វាជាការលំបាកក្នុងការមើលឃើញពីរបៀបដែល ជនណាម្នាក់អាចត្រូវបាននិយាយថា 'បានប្រព្រឹត្ត' បទឧក្រិដ្ឋណាមួយដែលខ្លួនគេផ្ទាល់ប្រហែលជាមិនបានដឹង ទោះបីជាគេគួរបានដឹងក៏ដោយ"។ Powles ទំព័រ ៦១១។

[177] Olásolo *សហកម្មឧក្រិដ្ឋកម្មរួម និង ទម្រង់លាតសន្ធឹងរបស់វា (Joint Criminal Enterprise and its Extended Form)* ទំព័រ ២៧៣-៧៤។

អាចបានកំណត់បែបនេះ។ ក៏ប៉ុន្តែ សាស្ត្រាចារ្យ Olásalo និង សាស្ត្រាចារ្យ van Sliedregt បាន គូសបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* មិនបានបញ្ជាក់ច្បាស់ពីលក្ខណៈពិតប្រាកដនៃការទទួលខុសត្រូវនៃ JCE[178]៖ ថាតើវា (១) បានបង្កើតជាទម្រង់នៃការប្រព្រឹត្តរួមគ្នា (២) ការទទួលខុសត្រូវបន្ទាប់បន្សំ ឬ បន្តពីគេ ឬ (៣) ភាពជាដៃគូក្នុងបទល្មើស ឬ ការទទួលខុសត្រូវបែបបសមគំនិតនៅក្នុងន័យនៃប្រព័ន្ធ common law។ នេះក៏ដោយសារតែ អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ប្រើឆ្លាស់ចុះឡើងនូវពាក្យ "ការទទួលខុសត្រូវបែបសមគំនិត" និង "ការប្រព្រឹត្តរួមគ្នា" ក្នុងការនិយាយយោងទៅដល់ ការទទួលខុសត្រូវនៃ JCE[179]។

---

[178] *ដូចខាងលើបន្ទាប់។ សូមមើលផងដែរ* Damgaard ទំព័រ ១៩៨ ពេលដែល Damgaard ពិភាក្សាពីសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* និងកត់សម្គាល់នូវភាពច្របូកច្របល់ដែលតុលាការនេះបានបង្កើតឡើង ជុំវិញបញ្ហាថាតើការទទួលខុសត្រូវ JCE អាចចាត់ទុកថាជាការទទួលខុសត្រូវជាមូលដ្ឋាន ឬ ក្នុងនាមជាការសមគំនិត។ "សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ពីទស្សនវិស័យនៃការបែងចែកប្រភេទនៃទម្រង់នៃការទទួលខុសត្រូវ ហាក់ដូចជាបានប្រើវាក្យស័ព្ទបញ្ច្រាសគ្នា ក្នុងការពណ៌នាអំពី JCED [ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម]។ ជាឧទាហរណ៍ អង្គជំនុំជម្រះនេះថ្លែងថា៖ 'ក៏ប៉ុន្តែ *ការប្រព្រឹត្ត* បទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋ ដែលគ្រោងក្នុង ... លក្ខន្តិកៈ [ICTY] ក៏អាចកើតឡើងតាមរយៈការចូលរួមក្នុងការបង្កើតគំរូ ឬ គោលបំណងរួមមួយ'។ ចំណុចនេះអាចត្រូវបានបកស្រាយតាមការមើលឃើញដំបូងថា ជាការគាំទ្រដល់គោលជំហរថា JCED គឺជាទម្រង់មួយនៃការទទួលខុសត្រូវ*ជាមូលដ្ឋាន* ។ ក៏ប៉ុន្តែ ក្រោយមកទៀត អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានថ្លែងនៅក្នុងសាលដីកានោះថា៖ 'ជាសរុបមក អង្គជំនុំជម្រះតុលាការកំពូលប្រកាន់ជំហរថា សញ្ញាណនៃគំរូរួមនោះគឺជា *ទម្រង់មួយនៃការទទួលខុសត្រូវជាមូលដ្ឋាន* ត្រូវបានបង្កើតឡើងយ៉ាងតឹងរ៉ឹងនៅក្នុងទម្លាប់អន្តរជាតិ ហើយជាងនេះទៅទៀត អង្គជំនុំជម្រះសម្រេចតំកល់ ទោះបីមានការចែងច្បាស់នៅក្នុងលក្ខន្តិកៈ [ICTY] ក៏ដោយ'។ ផ្ទុយមកវិញ អំណះអំណាងនេះអាចត្រូវបានបកស្រាយដើម្បីគាំទ្រដល់សំណើដែលថា JCED គឺជាទម្រង់មួយនៃការទទួលខុសត្រូវ *ក្នុងនាមជាការសមគំនិត*។ ក្នុងការបែងចែកដាច់ពីគ្នារវាង JCED និងទម្រង់នៃការទទួលខុសត្រូវបែបជាការជួយនិងជំរុញ អង្គជំនុំជម្រះតុលាការកំពូលមានការកត់សម្គាល់ *ក្នុងចំណោមនោះ* ថា 'អ្នកជួយនិងជំរុញគឺ *ជានិច្ចកាលជាអ្នកបន្ទាប់បន្សំ* ចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តដោយអ្នកផ្សេង ដែលជាអ្នកដែលដល់' ហេតុនេះ ផ្តល់យោបល់ដោយចង្អុលបង្ហាញថា ចារី JCE ណាម្នាក់មិនមែនជានិច្ចកាលជាអ្នកបន្ទាប់បន្សំ ហើយជួនកាលក៏ជាចារីដែលដល់ផងដែរ។ អង្គជំនុំជម្រះនេះក៏បានកត់សម្គាល់ផងដែរថា 'ដើម្បីឱ្យជនណាម្នាក់ទទួលខុសត្រូវបទឧក្រិដ្ឋក្នុងនាមជាចារី មិនត្រឹមតែអ្នកដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋដោយមធ្យោបាយសម្ភារៈនឹងមិនត្រូវចាត់ទុកថាមាន *តួនាទីជាការប្រព្រឹត្តរួមគ្នា* ចំពោះអ្នកដែលជួយសម្រួលតាមវិធីមួយសម្រាប់ឱ្យចារីអាចអនុវត្តនូវអំពើឧក្រិដ្ឋបាន។ នៅពេលជាមួយគ្នានោះដែរ *ដើម្បីឱ្យជនបន្ទាប់ទទួលខុសត្រូវត្រឹមតែជាអ្នកជួយនិងជំរុញ អាចនឹងត្រូវបង្ហាញពីកំរិតនៃការទទួលខុសត្រូវបទឧក្រិដ្ឋរបស់ពួកគេ*។ សេចក្តីថ្លែងនេះ ទំនងដូចជាគាំទ្រដល់សំណើដែលថា JCED គឺជាការទទួលខុសត្រូវជាអ្នកដែលដល់។ <u>សេចក្តីថ្លែងមានភាពចម្រូងចម្រាស់ដែលមើលឃើញដំបូង ក្លាយជាប្រភពនៃភាពមិនស្រុះស្រួលគ្នានៅចំពោះមុខ ICTY។ យុត្តិសាស្ត្ររបស់ ICTY បានផ្តល់នូវការគាំទ្រដល់ជំហរទាំងពីរនេះ</u>"។

[179] សារណាសង្ខេបរបស់ Ambos កថាខណ្ឌ២១។

ដោយសារមានភាពមិនច្បាស់លាស់បែបនេះហើយបានជា សាស្ត្រាចារ្យ Ambos អះអាងថា សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* "មិនមានភាពច្បាស់លាស់ពេញលេញថាតើ ការចូលរួមក្នុងបទល្មើសតាមរបៀបជា JCE ត្រូវបានបញ្ចូលដោយប្រើពាក្យថា 'បានប្រព្រឹត្ត' តាមមាត្រា ៧(១) នៃលក្ខន្តិកៈរបស់ ICTY ឬក៏អត់នោះទេ"[180]។

៦៩. បើតាមសាស្ត្រាចារ្យ Ambos, JCE III (និង JCE II នៅក្នុងស្ថានភាពដែលវាអាចប្រៀបប្រដូចនឹង JCE III បាន) មិនអាចចាត់ទុកថាត្រូវស្ថិតទៅក្នុង "ការប្រព្រឹត្ត" តាមមាត្រា ៧(១) នៃលក្ខន្តិកៈរបស់ ICTY និង អាចស្ថិតនៅជាប្រព័ន្ធទៅក្នុង "បានជួយនិងជំរុញតាមវិធីផ្សេងទៀត otherwise aided and abetted"[181]។ សាស្ត្រាចារ្យ Ambos កត់សម្គាល់នៅក្នុងសារណារបស់ខ្លួនដែលមិនមែនជាភាគីនៃរឿងក្តី ថា JCE III

> គ្រាន់តែអាចដាក់បញ្ចូលក្នុងរូបមន្ត 'ជួយនិងជំរុញតាមវិធីផ្សេងទៀត' ប្រសិនបើគេបកស្រាយថា 'តាមវិធីផ្សេងទៀត' រួមទាំងភាពស្មុគ្រស្មាញក្នុងការប្រព្រឹត្តបទល្មើសរួម។ ក៏ប៉ុន្តែ ការជួយនិងជំរុញ ដូចពន្យល់នៅក្នុងមាត្រា ៧(១) នៃលក្ខន្តិកៈរបស់ ICTY និង មាត្រា ២៥(៣)(គ) នៃលក្ខន្តិកៈរបស់ ICC ខុសគ្នាចំពោះចេតនាប្រព្រឹត្តបទល្មើសរបស់ JCE II និង III ដោយសារម្យ៉ាងវាតម្រូវឱ្យមានការយល់ដឹង ឬ ចេតនា នៅក្នុងអត្ថន័យនៃមាត្រា ៣០ នៃលក្ខន្តិកៈរបស់ ICC និង ម្យ៉ាងវិញទៀត គឺជា សកម្មភាព 'ក្នុងគោលបំណងសម្រួលការប្រព្រឹត្តនូវបទល្មើសបែបនេះ'។ ហេតុនេះ មានទម្រង់តែមួយគត់នៃការចូលរួមដែលអាចប្រៀបធៀបបានជាមួយ JCE II ឬ III គឺជាទម្រង់នៃការទទួលខុសត្រូវរួម ដែលមានចែងក្នុងមាត្រា ២៥(៣)(ឃ) នៃលក្ខន្តិកៈរបស់ ICC[182]។

ប៉ុន្តែ ការទទួលខុសត្រូវរួមតាមមាត្រា២៥(៣)(ឃ) នៃលក្ខន្តិកៈរបស់ ICC មានភាពខុសគ្នាស្រឡះពីការទទួលខុសត្រូវ JCE ដូចដែលបានបង្កើតនៅក្នុងយុត្តិសាស្ត្ររបស់បណ្តាតុលាការ

---

[180] *ដូចជើងទំព័រខាងលើ* ទំព័រ ១៣-១៤។

[181] *ដូចជើងទំព័រខាងលើ* ទំព័រ ១៤។

[182] *ដូចជើងទំព័រខាងលើ* ទំព័រ ១-២។ ជាសង្ខេប Ambos ថ្លែងថា៖ "ប្រសិនបើគេបកស្រាយថា JCE I មានធាតុផ្សំសត្យានុម័ត និង អត្តនោម័ត នៅក្នុងន័យជាទស្សនទានដែលត្រួតត្រាមានដំណើរការ វាអាចត្រូវបានគេចាត់ទុកថាជាទម្រង់មួយនៃការប្រព្រឹត្តរួមគ្នា តាមអត្ថន័យនៃមាត្រា២៥(៣)(ក) មាត្រា ២ នៃលក្ខន្តិកៈ ICC ជាដើម ជា *ទម្រង់មួយនៃការប្រព្រឹត្ត* អនុលោមតាមមាត្រា៧(១) នៃលក្ខន្តិកៈ ICTY /មាត្រា ៦(១) លក្ខន្តិកៈ ICTR"។

*បណ្ដឹងឧទ្ធរណ៍* ដោយសេចក្ដីសម្រេចនានាពេលថ្មីៗចំនួន ២ របស់ អង្គបុរេជំនុំជម្រះរបស់ ICC (ក្នុងរឿងក្ដី *Lubanga* និង រឿងក្ដី *Katanga*) ដូចបានពិភាក្សារួចមកហើយនៅផ្នែកខាងលើ។

៧០. ហេតុនេះ JCE II និង III មិនអាចត្រូវបានចាត់ទុកថាស្ថិតក្រោម "បានប្រព្រឹត្ត" ក្នុងមាត្រា២៩ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ទេ។ JCE I អាចត្រូវបានចាត់ទុកថាស្ថិតនៅក្រោម "បានប្រព្រឹត្ត" ប្រសិនបើគេបកស្រាយថាវាជាទម្រង់មួយនៃការប្រព្រឹត្តរួមគ្នាក្នុងប្រព័ន្ធ Civil Law[183]។ ដោយសារមានទម្រង់នៃការទទួលខុសត្រូវមួយដែលទទួលស្គាល់ដោយច្បាប់កម្ពុជាទៅហើយថាជា "ការប្រព្រឹត្តរួមគ្នា" មិនមានហេតុផលអ្វីដែលត្រូវធ្វើឱ្យបញ្ហាទាំងនេះមានការច្របូកច្របល់ ដោយសារយោងទម្រង់នៃការទទួលខុសត្រូវនេះដូចជា JCE I ឡើយ។

៧១. ប្រសិនបើ JCE មិនត្រូវបានគេចាត់ទុកថាជា "ការប្រព្រឹត្ត" ស្របតាមគោលបំណងនៃមាត្រា ២៩ នោះវាមិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ។ ស្ថានភាពនេះខុសពីស្ថានភាពនៅ ICTY នៅពេលដែល អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្ដី *Ojdanić* បានកត់សម្គាល់ថា "តាមរូបភាពពីខាងក្រៅ បញ្ជីក្នុងមាត្រា ៧(១) មិនរាយរាប់អោយអស់ដូចការប្រើឃ្លាថា '*ឬ តាមវិធីផ្សេងទៀត* បានជួយនិងជំរុញ' បានស្នើឡើងនោះទេ"[184]។ ប្រការនេះនឹងផ្ដល់ឱកាសក្នុងការចាត់ទុកការទទួលខុសត្រូវ JCE ស្ថិតក្រោមនៃលក្ខន្តិកៈរបស់ ICTY ទោះបីជាវាមិនត្រូវបានចាត់ទុកថាជាទម្រង់មួយនៃការប្រព្រឹត្តក៏ដោយ។ ក៏ប៉ុន្តែ ខុសពីមាត្រា ៧(១) នៃនៃលក្ខន្តិកៈរបស់ ICTY និង មាត្រា ៦(១) នៃលក្ខន្តិកៈរបស់ ICTR ពាក្យពេចន៍ដែលប្រើប្រាស់ក្នុងមាត្រា ២៩ បានធ្វើការបែងចែកដាច់ស្រឡះរវាងពាក្យ "បានប្រព្រឹត្ត" និង ពាក្យ "បានជួយនិងជំរុញ"។ មាត្រានេះបានចែងថា បុគ្គលណាមួយដែល "បានរៀបផែនការញុះញង់ បញ្ជា ជួយនិងជំរុញ ឬ ប្រព្រឹត្ត បទល្មើស"[185] អាចទទួលខុសត្រូវ។ ភាពមានន័យមិនច្បាស់លាស់ទាក់ទងនឹងមាត្រា ២៩ ដែលភាពមានន័យមិន

---

[183] រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Milutinović និងអ្នកផ្សេងទៀត* IT-99-37-ART72 **សេចក្ដីសម្រេចទៅលើបណ្ដឹងតវ៉ារបស់ Dragoljub Ojdanić ទល់នឹងយុត្តាធិការ** - *សហការមូលក្រិមក្រុម* ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣ ("សេចក្ដីសម្រេចលើ JCE ក្នុងរឿងក្ដី *Ojdanić*") កថាខណ្ឌ១៩។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលបានថ្លែងពេលនោះថា ខ្លួនមិនចាំបាច់ពិចារណាថាតើខាងក្រៅទម្រង់នៃការទទួលខុសត្រូវទាំងនោះមានចែងបញ្ជាក់នៅក្នុងលក្ខន្តិកៈឬអត់នោះទេ ចំណែកទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតស្ថិតក្រោមមាត្រា៧(១) ព្រោះអង្គជំនុំជម្រះនេះពេញចិត្តថា ស្ថិតនៅក្នុងបទប្បញ្ញត្តិនៃលក្ខន្តិកៈនេះ។

[184] បន្ថែមការសង្កត់ន័យនៃឃ្លា។

[185] ចំណុចនេះគម្រូវដោយរដ្ឋធម្មនុញ្ញកម្ពុជា ដែលមានចែងក្នុងមាត្រា ៣៨ ថា ក្នុងករណីវិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

00438537



ច្បាស់លាស់អាចនឹងនៅមាន ត្រូវតែដោះស្រាយអនុលោមទៅតាមគោលការណ៍ ការសង្ស័យត្រូវបានជាប្រយោជន៍ដល់ពិរុទ្ធជន (*in dubio pro reo*) ដូចមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា៖ ត្រូវតែបានជាប្រយោជន៍ដល់ចុងចោទ។ ការសំអាងតាមមាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលយោងទៅដល់គោលបំណងនៃការនាំខ្លួនមេដឹកនាំជាន់ខ្ពស់ទៅជំនុំជម្រះ មិនអាចផ្លាស់ប្តូរអត្ថន័យនៃមាត្រា ២៩ ដែលគាំទ្រខាងលើ[186]។

ង. **ក.ស.ច.ស មានកំហុសឆ្គងក្នុងការអះអាងថា ការអនុវត្តន៍ការទទួលខុសត្រូវ JCE នឹងមិនរំលោភបំពានដល់គោលការណ៍នីត្យានុកូលភាព។ ទោះបី ការទទួលខុសត្រូវ JCE ជាផ្នែកមួយនៃទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-៧៩ ក៏ដោយ ក៏គោលការណ៍នីត្យានុកូលភាពមិនអនុញ្ញាតឲ្យយកមកអនុវត្តនៅ អ.វ.ត.ក ដែរ។**

១. **ក.ស.ច.ស មានកំហុសឆ្គងក្នុងការវាយតម្លៃដែលបានប្រើប្រាស់ដើម្បីសម្រេចថា តើគោលការណ៍នីត្យានុកូលភាពអនុញ្ញាតឲ្យអនុវត្តនូវការទទួលខុសត្រូវ JCE នៅ អ.វ.ត.ក។ ការទទួលខុសត្រូវ JCE ត្រូវតែជាផ្នែកមួយនៃច្បាប់កម្ពុជា ក្នុងឆ្នាំ ១៩៧៥-៧៩ ក្នុងការបំពេញតាមគោលការណ៍នីត្យានុកូលភាព។**

៧២. ក.ស.ច.ស មានកំហុសឆ្គងនៅពេលដែលខ្លួនបានធ្វើការសន្និដ្ឋានថា ការអនុវត្តការទទួលខុសត្រូវ JCE មិនរំលោភបំពានគោលការណ៍នីត្យានុកូលភាព ពីព្រោះធាតុផ្សំនៃការទទួលខុសត្រូវ JCE "គឺអាចប្រមើលមើល និង ទទួលបាន <u>ក្រោមច្បាប់អន្តរជាតិ</u>ក្នុងឆ្នាំ ១៩៧៥ នៅកម្ពុជា ..."[187]។ ក.ស.ច.ស បានប្រើការវាយតម្លៃខុស នៅពេលសម្រេចសេចក្តីពីរឿងនេះ។ ក.ស.ច.ស បានធ្វើការសន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពនៃច្បាប់អាចត្រូវបំពេញបាន ប្រសិនបើការទទួលខុសត្រូវ JCE មានក្នុងច្បាប់អន្តរជាតិ ដោយយោងទៅបទប្បញ្ញត្តិក្នុងមាត្រា ១៥ នៃកតិកាអន្តរជាតិស្តី

---

[186] ចំពោះការពន្យល់មួយដែលសំខាន់ទៅលើការផ្តល់ហេតុផល ដែលពោរពេញទៅដោយកំហុស របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ *សូមមើល* Ohlin *បញ្ហាបីនៅក្នុងទស្សនទាន (Three Conceptual Problems)* ទំព័រ ៧២។ ដោយយោងទៅលើការរៀបចំពាក្យពេចន៍នៃលក្ខន្តិកៈ ICTY របស់អង្គជំនុំជម្រះតុលាការកំពូលនានាលើរឿងក្តី *Tadić* តុលាការនេះបានរកឃើញថា ការទទួលខុសត្រូវ JCE គឺជាផ្នែកមួយនៃកម្មវត្ថុនិងគោលបំណងរបស់ខ្លួន។ សាស្ត្រាចារ្យ Ohlin ពន្យល់ថា ទឡ្ហីករណ៍នេះរត់ជុំវិញជារង្វង់ នៅពេលដែលត្រឡប់មកទីតាំងដែលចុងចោទត្រូវតែទទួលការដាក់ទណ្ឌ ដែលបានទុកសំនួរជាច្រើនចំពោះការទទួលខុសត្រូវជាលក្ខណៈបុគ្គល មិនអាចឆ្លើយរួច និង ផ្ទុយពីទ្រឹស្តីនៃនីតិព្រហ្មទណ្ឌជាមូលដ្ឋានផង។

[187] សេចក្តីសម្រេចលើ JCE កថាខណ្ឌ៦៣ (បន្ថែមការសង្កត់ន័យនៃឃ្លា)។

ពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយឆ្នាំ ១៩៦៦ (ICCPR)[188]។ ក៏ប៉ុន្តែ "គេត្រូវបែងចែកឱ្យដាច់ស្រឡះរវាងភាពចាំបាច់ជាមុននៃគោលការណ៍នីត្យានុកូលភាព ដូចដែលបានកំណត់និយមន័យនៅក្នុងកំរិតអន្តរជាតិ និង គោលការណ៍នីត្យានុកូលភាពនៃច្បាប់ជាតិ។ ... មានប្រព័ន្ធជាតិនៅតាមប្រទេសជាច្រើន ឧទាហរណ៍ រដ្ឋធម្មនុញ្ញអាល្លឺម៉ង់ (មាត្រា ១០៣(២)) តម្រូវឱ្យស្របដាច់ខាតទៅនឹងគោលការណ៍នីត្យានុកូលភាព"[189]។ បញ្ហានេះបានលើកឡើងក្នុងរឿងក្តី *Aussaresses* ដូចបានពិភាក្សា*ខាងលើ*។ ភាគីដែលប្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តីនោះបានតវ៉ាថា អាទិភាពនៃវិធានមួយក្នុងទំនៀមទម្លាប់អន្តរជាតិនៅពេលដែលបទល្មើសបានប្រព្រឹត្តឡើង អាចបំពេញបានតាមគោលការណ៍នីត្យានុកូលភាពហើយ។ ទឡ្ហីករណ៍នេះត្រូវបានគេបានច្រានចោល[190]។

៧៣. មាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ បានចែងថា "ច្បាប់ព្រហ្មទណ្ឌគ្មានអានុភាពជាប្រតិសកម្មទេ គឺថា បទល្មើសណាបានប្រព្រឹត្តមុនបទប្បញ្ញត្តិរបស់ច្បាប់ បទល្មើសនោះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ"[191]។ ហេតុនេះ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ តម្រូវឱ្យស្របជាមួយនឹងគោលការណ៍នីត្យានុកូលភាពដាច់ខាត៖ ការទទួលខុសត្រូវ JCE ត្រូវបានបង្កើតឡើងក្នុងច្បាប់កម្ពុជា នៅពេលវេលាមួយដែលពាក់ព័ន្ធ ដើម្បីកុំឱ្យមានការរំលោភបំពានលើគោលការណ៍នេះ[192]។

**២. ក.ស.ច.ស មានកំហុសឆ្គងក្នុងការសម្រេចថាតើ ការទទួលខុសត្រូវ JCE អាចប្រមើលមើល និង ទទួលបានគ្រប់គ្រាន់ឬទេក្នុងឆ្នាំ ១៩៧៥-៧៩។ ការទទួលខុសត្រូវ JCE មិនត្រូវបានផ្តល់និយមន័យគ្រប់គ្រាន់ដែលអាចដឹងបាន និង អាចទទួលយកបាន នៅពេលវេលាមួយដែលពាក់ព័ន្ធទេ។**

៧៤. ក.ស.ច.ស បានកត់សម្គាល់ថា គោលការណ៍នីត្យានុកូលភាពតម្រូវឱ្យមានលក្ខខណ្ឌសំខាន់ពីរគឺ៖ ថាតើការទទួលខុសត្រូវក្នុងបទឧក្រិដ្ឋដែលកំពុងដេញដោល គឺអាចដឹងបានយ៉ាងគ្រប់គ្រាន់ និង

---

[188] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ១៩។

[189] Kreicker ទំព័រ ៣២០ (បន្ថែមការសង្កត់ន័យនៃឃ្លា)។

[190] *សូមមើល* Lelieur-Fischer ទំព័រ ២៣២-៣៦។

[191] ការបកប្រែក្រៅផ្លូវការពីភាសាបារាំង។

[192] ចំពោះការពិភាក្សាបន្ថែមទៀត *សូមមើល* ឧបសម្ព័ន្ធ ក ផ្នែក II ក(១)។

ថាតើវាអាចទទួលយកបានគ្រប់គ្រាន់ នៅពេលវេលាមួយដែលពាក់ព័ន្ធ[193]។ ក៏ប៉ុន្តែ ក.ស.ច.ស ខកខានក្នុងការរកឱ្យឃើញនូវអត្ថន័យនិងតម្រូវការនៃលក្ខខណ្ឌសំខាន់ទាំងពីរនេះ[194]។ ដោយមិនបានបង្ហាញពីការវិភាគថាតើការទទួលខុសត្រូវ JCE ពិតជាអាចដឹងបាន និង ទទួលយកបាន នៅពេលវេលាមួយដែលពាក់ព័ន្ធទេ តែ ក.ស.ច.ស គ្រាន់តែអះអាងថា "បើពិចារណាទៅលើទិដ្ឋភាពអន្តរជាតិរបស់ អ.វ.ត.ក និង <u>យុត្តិសាស្ត្រគាំទ្រក្នុងការបង្ហាញថា JCE មានតាំងពីមុនព្រឹត្តិការណ៍ដែលស្ថិតក្រោមការស៊ើបអង្កេត</u>នៅ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតរកឃើញថាមានមូលដ្ឋានមួយក្រោមច្បាប់អន្តរជាតិ សម្រាប់អនុវត្ត JCE ..."[195]។

៧៥. លក្ខខណ្ឌដែលថា ការទទួលខុសត្រូវបទឧក្រិដ្ឋ ពិតជាអាចដឹងបាន និង ទទួលយកបានយ៉ាងគ្រប់គ្រាន់ នៅពេលវេលាមួយដែលបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ត្រូវបានពន្យល់យ៉ាងច្បាស់ដោយ អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY លើរឿងក្តី *Vasiljević* ៖

> នៅពេលមានការពេញចិត្តថា អំពើមួយឬច្រើនពិតជាអំពីឧក្រិដ្ឋក្រោមទំនៀមទម្លាប់អន្តរជាតិ <u>អង្គជំនុំជម្រះសាលាដំបូងត្រូវបំពេញចិត្តខ្លួនឯងថា បទល្មើសដែលជនជាប់ចោទកំពុងត្រូវទទួលការចោទប្រកាន់នោះ ត្រូវបានកំណត់ជានិយម</u>

---

[193] សេចក្តីសម្រេចលើ JCE កថាខណ្ឌ១៩។ ក៏ប៉ុន្តែ ដូចបានកត់សម្គាល់ដោយសាស្ត្រាចារ្យ Ambos ស្របជាមួយនឹងលក្ខខណ្ឌនៃភាពដែលអាចដឹងបាន និង អាចទទួលបានតែប៉ុណ្ណេះ <u>មិនទាន់គ្រប់គ្រាន់ទេ</u> ព្រោះការទទួលខុសត្រូវក៏ត្រូវតែមានចែងក្នុងច្បាប់ដែលមានជាធរមានដែរ។ សារណាសង្ខេបរបស់ Ambos កថាខណ្ឌ២១។ ដូចបានពិភាក្សាមយខាងលើ នៅក្នុងទម្រង់នីមួយៗរបស់វា JCE មិនអាចត្រូវយកមកនិយាយថា វាស្ថិតក្រោមពាក្យថា "បានប្រព្រឹត្ត" តាមមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[194] សេចក្តីសម្រេចលើ JCE កថាខណ្ឌ២០។ ក.ស.ច.ស គ្រាន់តែអះអាងថា "ការសាកល្បងនៃភាពដែលអាចដឹងបាន និង អាចទទួលបាន អាចជាការពេញចិត្តនៅពេលដែលសកម្មភាពល្មើសណាមួយក្លាយជាបទឧក្រិដ្ឋក្រោមច្បាប់ជាតិ ឬ ក្រោមច្បាប់អន្តរជាតិ នៅក្នុងពេលវេលាដោយឡែកណាមួយ។ សេចក្តីសម្រេចនានារបស់តុលាការ និង លិខិតូបករណ៍អន្តរជាតិនឹងក្លាយជាគោលការណ៍ណែនាំ ក្នុងការវាយតម្លៃចំពោះភាពដែលអាចដឹងបាន និង អាចទទួលបាន នៃបទដ្ឋានឧក្រិដ្ឋនានា ដូចជាលក្ខណៈ និង ស្ថានទម្ងន់នៃអំពើល្មើសទាំងនោះ"។ ក៏ប៉ុន្តែ អត្ថន័យនៃសញ្ញាណនៃភាពដែលអាចដឹងបាន និង អាចទទួលបានគឺមានសារៈសំខាន់ណាស់ ពីព្រោះ "ការវិភាគនៃវិធីដែលអង្គជំនុំជម្រះតុលាការកំពូល [ក្នុងសេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić*] យល់ពីអត្ថន័យនៃសញ្ញាណនៃភាពដែលអាចដឹងបាន និង អាចទទួលបាន - ដែលទស្សនៈរបស់តុលាការនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងទស្សនៈនៃភាពពិសេស - បង្ហាញថា<u>សញ្ញាណទាំងនេះត្រូវបានផ្តល់និយមន័យដោយអង្គជំនុំជម្រះតុលាការកំពូល ក្នុងវិធីមួយដែលកាន់តែមានលក្ខណៈរួម និង តឹងរ៉ឹងតិចជាងមុន ជាអ្វីដែលកើតមានជាធម្មតានៅក្នុងច្បាប់ជាតិ</u>"។ Olásolo *គោលការណ៍នីត្យានុកូលភាព* ទំព័រ ៣១៧ (បន្ថែមការសង្កត់ពាក្យ)។

[195] សេចក្តីសម្រេចលើ JCE កថាខណ្ឌ២១ (បន្ថែមការសង្កត់ពាក្យ)។

ន័យដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ *ក្រោមច្បាប់ទម្លាប់អន្តរជាតិ* សម្រាប់លក្ខណៈទូទៅរបស់វា ចរិតលក្ខណៈព្រហ្មទណ្ឌរបស់វា និង ស្ថានទម្ងន់របស់វាត្រូវអាចដឹងបាន និង ទទួលយកបាន។ នៅពេលធ្វើការវាយតម្លៃ អង្គជំនុំជម្រះសាលាដំបូងពិចារណាទៅដល់លក្ខណៈពិសេសរបស់ច្បាប់អន្តរជាតិ ជាពិសេសគឺលក្ខណៈពិសេសនៅក្នុងទំនៀមទម្លាប់អន្តរជាតិ។ តម្រូវការឱ្យមានភាពច្បាស់លាស់គ្រប់គ្រាន់ចំពោះនិយមន័យនៃបទល្មើសព្រហ្មទណ្ឌ ដែលការពិតវាជាផ្នែកមួយនៃគោលការណ៍ *មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege)* ហើយវាត្រូវវាយតម្លៃនៅក្នុងបរិបទនោះ។ ប្រសិនបើទម្លាប់អន្តរជាតិមិនបានផ្តល់នូវនិយមន័យមួយច្បាស់លាស់គ្រប់គ្រាន់ចំពោះបទឧក្រិដ្ឋ ដែលរៀបរាប់នៅក្នុងលក្ខន្តិកៈទេ អង្គជំនុំជម្រះសាលាដំបូងនឹងមិនមានជម្រើសអ្វីក្រៅពីបញ្ឈប់ការអនុវត្តនូវយុត្តាធិការរបស់ខ្លួនទៅលើករណីនេះទេ ដោយមិនគិតដល់អង្គហេតុដែលថាបទឧក្រិដ្ឋ ដែលចាត់ទុកជាបទល្មើសដែលអាចដាក់ដាក់ទោសបាន នៅក្នុងលក្ខន្តិកៈនេះ។ នេះដោយសារតែកម្ពីពាក្យពីតុលាការយោធាសហរដ្ឋអាមេរិកនៅទីក្រុង Nuremberg អ្វីៗដែលមាននៅក្នុងលក្ខន្តិកៈរបស់តុលាការលើសពីអ្វីដែលមាននៅក្នុងទំនៀមទម្លាប់អន្តរជាតិ គឺជាការប្រើអំណាច មិនមែនច្បាប់ទេ[196]។

៧៦. អង្គជំនុំជម្រះសាលាដំបូងក៏បានពន្យល់បន្ថែមទៀតថា “បើនិយាយពីទិដ្ឋភាពនៃគោលការណ៍ *មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege)* វាជាការមិនអាចទទួលយកបានទាំងស្រុងសម្រាប់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចទោសដល់ជនជាប់ចោទ ឈរលើគោលការណ៍នៃការហាមឃាត់មួយដែល ពិចារណាទៅដល់លក្ខណៈពិសេសនៃទម្លាប់អន្តរជាតិ និង អនុញ្ញាតឱ្យមានការពន្យល់ច្បាស់ជាបណ្តើរៗនៃវិធាននានានៅក្នុងច្បាប់ព្រហ្មទណ្ឌ គឺទាំងមិនមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីសម្រេចដឹកនាំ និង បែងចែកអំពើឧក្រិដ្ឋពីការទទួលការអនុញ្ញាត ឬ មិនអាចទទួលបានគ្រប់គ្រាន់ នៅពេលវេលាមួយដែលពាក់ព័ន្ធ។ ជាការពិតការផ្តន្ទាទោសលើបទឧក្រិដ្ឋមិនត្រូវផ្អែកទៅលើបទដ្ឋានមួយមួយ ដែលជនជាប់ចោទម្នាក់មិនបានដឹងដោយសមហេតុផល នូវពេលអំពើទាំងនោះបានកើតឡើង ហើយ បទដ្ឋាននេះត្រូវតែមាន

---

[196] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Vasiljević*, IT-98-32-T សេចក្តីសម្រេច ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ២០១-០២ (បន្ថែមការសង្កត់ន័យ)។

00438541



លក្ខណៈច្បាស់លាស់គ្រប់គ្រាន់ អំពីអំពើ ឬ ការប្រព្រឹត្តបែបណាដែលនាំឱ្យគាត់មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ”[197]។

៧៧. ការទទួលខុសត្រូវ JCE ទោះបីវាអាចត្រូវបានគេចាត់ទុកថាជាផ្នែកមួយនៃទម្លាប់អន្តរជាតិក៏ដោយ នៅពេលវេលាដែលពាក់ព័ន្ធ តែវាមិនត្រូវបានគេផ្តល់និយមន័យយ៉ាងជាក់លាក់ ច្បាស់លាស់ គ្រប់គ្រាន់ ថាមានការទទួលខុសត្រូវ*តាមរយៈ* JCE មួយដែលអាចប្រមើលមើលបាន ចំពោះជនត្រូវចោទនោះទេ។ មានការបង្ហាញពីការមិនឯកភាពជាច្រើនជុំវិញធាតុផ្សំនានារបស់វា ដូចជាថាតើ JCE II អាចប្រៀបប្រដូចទៅនឹង JCE I បានឬទេ[198] ថាតើចេតនាប្រព្រឹត្តបទល្មើសសម្រាប់ JCE III ផ្អែកលើការសម្រេចចិត្តបែបអត្តនោម័ត ឬ សត្យានុម័តឬទេ[199] ថាតើវាអាចមានការជួយនិងជំរុញឬទេ[200] ថាតើមានការចូលរួមចំណែកក្នុងការរៀបចំផែនការរួមនៃ JCE ដែលត្រូវមានសារធាតុជាមួយឬទេ[201] ។ល។

៧៨. នៅក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹង JCE នៃរឿងក្តី *Ojdanić* ដែលដកស្រង់ដោយ ក.ស.ច.ស អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃថាតើ ការទទួលខុសត្រូវបទឧក្រិដ្ឋអាចប្រមើលមើលបានចំពោះ Ojdanić ឬទេ។ ក្នុងការគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួនដែលថា Ojdanić អាចនឹងការទទួលខុសត្រូវបទល្មើស ដោយផ្អែកលើក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសង្គមនិយមសហព័ន្ធយូហ្គោស្លាវី រួមមានបទប្បញ្ញត្តិមួយដែល “ស្រដៀងគ្នាជាខ្លាំង” ទៅនឹងការទទួលខុសត្រូវ JCE[202]។ ហេតុនេះ អាទិភាពនៃការទទួលខុសត្រូវ JCE នៅក្នុងច្បាប់ក្នុងស្រុកត្រូវយកមក

[197] *ខាងលើបន្ទាប់* កថាខណ្ឌ១៩៣ (បន្ថែមការសង្កត់ន័យនៃឃ្លា)។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* IT-01-47-PT **បណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំស្តីពីការតតាំងរួមគ្នាទល់នឹងយុត្តាធិការ** ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ១៥។ “មានការបង្កើតឡើងយ៉ាងត្រឹមត្រូវក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលថា គោលការណ៍នីត្យានុកូលភាពតម្រូវថា បទឧក្រិដ្ឋដែលចោទប្រកាន់ត្រូវបានបង្កើតឡើងនៅក្នុងច្បាប់មួយដែលអាចទទួលបាន និង ថា វាត្រូវអាចដឹងបានថា ការប្រព្រឹត្តបែបនេះអាចនឹងនាំឱ្យមានការដាក់ទោសទណ្ឌជាបទឧក្រិដ្ឋ នៅពេលដែលអំពើឧក្រិដ្ឋនោះត្រូវបានគេប្រព្រឹត្តរួច។”

[198] *សូមមើល* ការពិភាក្សា *ខាងលើ*។

[199] *សូមមើល* ការពិភាក្សា *ខាងលើ*។

[200] *សូមមើល* សារណាសង្ខេបរបស់ Ambos កថាខណ្ឌ១០។

[201] *សូមមើល ខាងលើ* ទំព័រ ៥-៦ លេខយោង ១០។

[202] សេចក្តីសម្រេចលើ JCE ក្នុងរឿងក្តី *Ojdanić* កថាខណ្ឌ៤០។

ពិចារណាអំពីភាពដែលអាចដឹងបាន និង ភាពអាចទទួលយកបាន[203]។ ការទទួលខុសត្រូវ JCE មិនមានក្នុងច្បាប់កម្ពុជាទេ។ ដូចជាមិនទំនងជាខ្លាំងដែលថា ជនជាប់ចោទទាំងឡាយនឹងបានដឹងថាខ្លួននឹងត្រូវទទួលខុសត្រូវក្រោមទម្រង់នៃការទទួលខុសត្រូវមួយ ដែលមិនមាននៅក្នុងប្រទេសនេះទេ។ *ប្រសិនបើ* ការទទួលខុសត្រូវ JCE ជាផ្នែកមួយនៃទម្លាប់អន្តរជាតិ ហើយ *ប្រសិនបើ* មានការសន្មតថា ជនជាប់ចោទណាម្នាក់បានដឹងពីរឿងនេះ គាត់ក៏អាចត្រូវគេសន្មតថា ប្រទេសរបស់គាត់មិនបានអនុវត្តដោយផ្ទាល់នូវទំនៀមទម្លាប់អន្តរជាតិ ចំពោះបទល្មើសដែលស្ថិតក្នុងយុត្តាធិការរបស់ប្រទេសនោះដែរ។

៧៩. វាត្រូវបានគេពន្យល់ថា "តម្លៃយូរអង្វែងរបស់ ICC គឺថា តុលាការនេះនឹងបង្រៀនប្រទេសនានានៅលើពិភពលោកពីរបៀបស្វែងរកយុត្តិធម៌ ខណៈដែលប្រទេសទាំងនោះស្វែងរកវិធានការគាបសង្កត់នានាក្នុងនាមអ្នកការពារសង្គម។ ប្រសិនបើ ICC ងាកចេញពីគោលការណ៍នីតិវិធីច្បាប់ និង នីត្យា

---

[203] *ដូចខាងលើ* កថាខណ្ឌ៤៣។ ក៏ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលពិតជាបានកត់សម្គាល់ថា "នៅក្នុងរឿងក្ដីបច្ចុប្បន្ន និង ទោះបីបទប្បញ្ញត្តិបែបនេះក្នុងស្រុកមិនមានក្ដី មានសេចក្ដីសម្រេចជាច្រើននិងស៊ីសង្វាក់គ្នារបស់តុលាការ លិខិតូបករណ៍អន្តរជាតិ និង ច្បាប់ក្នុងស្រុក ដែលបានផ្ដល់ឲ្យគាត់នូវការកត់សម្គាល់ដែលសមហេតុផល ប្រសិនបើមានការបន្ទុចបង្អាក់ បទដ្ឋាននោះអាចបង្ហាញឲ្យឃើញពីការទទួលខុសត្រូវបទឧក្រិដ្ឋរបស់គាត់។" *ដូចខាងលើ*។ ក៏ប៉ុន្តែ "ប្រទេសមួយចំនួនមិនទទួលស្គាល់ JCED ថាជារបៀបនៃការទទួលខុសត្រូវមួយទេ ឬ គ្រាន់តែទទួលស្គាល់ទោតាមកាលៈទេសៈមានកំរិតប៉ុណ្ណោះ។ តើនៅមានន័យថា ជនជាតិរបស់រដ្ឋទាំងនោះអាចនិយាយប្រឆាំងបានយ៉ាងជោគជ័យថា JCED មិនអាចដឹងបាន ឬ មិនអាចទទួលបានយ៉ាងគ្រប់គ្រាន់ចំពោះពួកគេទេ ហេតុនេះពួកគេមិនត្រូវទទួលបានការដាក់ទោស ដោយផ្អែកលើមូលដ្ឋានថា មិនចំពោះតែជនជាតិនៃប្រទេសអង់គ្លេស សហរដ្ឋអាមេរិក និង យូហ្គោស្លាវី ដែលច្បាប់ជាតិបានទទួលស្គាល់ JCED មិនអាចរំពឹងថានឹងទទួលបានជោគជ័យនៅពេលមានទឡ្ហីករណ៍ដូចគ្នានេះឬមួយយ៉ាងណា? ... តើគេអាចនិយាយបានថាតើរបៀបនៃការទទួលខុសត្រូវ JCE ចំពោះបទឧក្រិដ្ឋអន្តរជាតិចម្បងៗគឺ 'អាចដឹងបានគ្រប់គ្រាន់' និងថាតើ ច្បាប់ដែលចែងដូចគ្នានេះ គឺ 'អាចដឹងបានគ្រប់គ្រាន់'ឬទេ? តាមទស្សនៈរបស់អ្នកនិពន្ធ វាជាការគួរឲ្យសង្ស័យ។ ជាការពិត បច្ចុប្បន្ននេះ JCED ក្លាយជាការចាប់អារម្មណ៍ជាងមុនពេលមានសាលដីការបស់តុលាការកំពូលលើរឿងក្ដី *Tadić*។ ក៏ប៉ុន្តែ ការចរចាទាក់ទងនឹងមាត្រា ២៥(៣) នៃលក្ខន្តិកៈរបស់ ICC បង្ហាញថា ទោះបីក្នុងចំណោមអ្នកឯកទេសច្បាប់ និង មន្ត្រីការទូតដែលមានតួនាទីខ្ពស់ៗ ក៏ JCED នៅតែជាបញ្ហាដែលមានវិវាទនៅឡើយ។ ជាងនេះទៅទៀត ទំនងជាមិនមានភាពយុត្តិធម៌ក្នុងការរំពឹងថា បុគ្គលណាម្នាក់ ជាពិសេសអ្នកដែលមិនមានការអប់រំ និង ប្រហែលជាអនក្ខរជនផង មានការយល់ដឹងពី JCED នៅពេលដែលមានមេធាវីខាងបទឧក្រិដ្ឋអន្តរជាតិឱកាសនិយមជាច្រើននៅតែមិនទាន់យល់ច្បាស់ពីដែនសមត្ថកិច្ចរបស់វា។ ការរំពឹងទុកចំពោះការយល់ដឹងពីការទទួលខុសត្រូវដ៏មានសក្ដានុពលបែបនេះ ដែលជាលទ្ធផលពីរបៀបនៃការទទួលខុសត្រូវ JCED ឆ្លុះបញ្ចាំងពីទិដ្ឋភាពមួយដាច់ដោយឡែកតែឯង។" Damgaard ទំព័រ ២៤០។ *សូមមើលផងដែរ* ទំព័រ ២៤១ សម្រាប់ការពិភាក្សាបន្ថែមចំពោះទស្សនៈរបស់អ្នកនិយមដែលថាការយក JCE មកអនុវត្ត គឺជាការរំលោភបំពានដល់គោលការណ៍ *មិនមែនជាបទល្មើសបើគ្មានច្បាប់ចែង (nullum crimen sine lege)*។

នុក្ខលភាព នោះតុលាការនេះនឹងក្លាយជាគ្រូដែលនាំមហន្តរាយដល់ពិភពលោកមិនខាន។ ICC មិនត្រូវត្រឹមតែដំណើរការឱ្យស្របទៅនឹងវិធានការជំនុំជម្រះប្រកបដោយយុត្តិធម៌ តែតុលាការនេះត្រូវតែបង្កើនការអនុវត្តន៍បែបប្រពៃណីរបស់បណ្តាប្រជាជាតិ និង បង្កើតជាគំរូសម្រាប់ពិភពលោកពីរបៀបដំណើរការតុលាការព្រហ្មទណ្ឌមួយ"[204]។ សហមេធាវីសូមដាក់សំណើថា អំណះអំណាងនេះគួរតែយកទៅអនុវត្តឱ្យមានស្មើគ្នាចំពោះ អ.វ.ត.ក ក្នុងន័យសំដៅដល់គោលដៅរបស់ អ.វ.ត.ក ក្នុងការដើរតួនាទីជាគំរូសម្រាប់ប្រព័ន្ធតុលាការនៅកម្ពុជា[205]។ អ.វ.ត.ក មិនត្រូវរំលោភបំពានទៅលើគោលការណ៍និត្យានុក្ខលភាព ដោយអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវមួយដែលមិនមាននៅក្នុងច្បាប់កម្ពុជាក្នុងឆ្នាំ ១៩៧៥-៧៩ និង មិនមានក្នុងច្បាប់កម្ពុជាបច្ចុប្បន្ននេះទេ។

## IV. សេចក្តីសន្និដ្ឋាន និង សំណូមពរ

៨០. អ.វ.ត.ក គឺជាតុលាការក្នុងប្រទេសមួយរបស់កម្ពុជា។ ហេតុនេះ តុលាការនេះមិនអាចអនុវត្តនូវទម្លាប់អន្តរជាតិបានទេ។ ការទទួលខុសត្រូវ JCE មិនអាចត្រូវបានចាត់ទុកថាជាទម្រង់មួយនៃ "ការប្រព្រឹត្ត" សម្រាប់ជាគោលបំណងរបស់មាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយការទទួលខុសត្រូវ JCE មិនមែនជាផ្នែកមួយនៃទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-៧៩ទេ។ ទោះបីមានការសម្រេចថា អ.វ.ត.ក អាចអនុវត្តដោយផ្ទាល់នូវទម្លាប់អន្តរជាតិ និង ថា JCE

[204] Fletcher & Ohlin *ការទាមទារជាថ្មីនូវគោលការណ៍នានាជាមូលដ្ឋាន* *(Reclaiming Fundmental Principles)* ទំព័រ ៥៤០។ "កើតចេញពីគំនរផេះផង់នៃអំពីហោរឃៅក្នុងសតវត្សទី២០ នីតិព្រហ្មទណ្ឌអន្តរជាតិបានបញ្ចូលគ្នាទៅជាការឆ្លើយតបនឹងអំពើនិទណ្ឌភាពចំពោះបទឧក្រិដ្ឋធំៗ ដែលបានគេចផុតពីសំណាញ់ច្បាប់។ នោះហើយជាការកកើតឡើងនៃបណ្តុំច្បាប់មួយ។ តែគេមិនអាចការពារនូវកំហុសឆ្គងរបស់វា ដោយអះអាងថា ការភ្ជាប់ជាមួយនឹងគោលការណ៍ទាំងនេះ មានការលំបាកនេះទេ។ យើងអះអាងថា នីតិព្រហ្មទណ្ឌអន្តរជាតិ ដែលវាបំផុសមិនត្រឹមតែច្បាប់អន្តរជាតិនោះទេ តែត្រូវមានច្បាប់ព្រហ្មទណ្ឌផងដែរ ត្រូវគោរពដល់គោលការណ៍មូលដ្ឋានមួយចំនួននៃភាពយុត្តិធម៌ និង នីត្យានុក្ខលភាព។ ហេតុផលចំពោះអំណះអំណាងនេះគឺថា គោលការណ៍មូលដ្ឋានទាំងនេះ ជាតម្រូវការខាងគុណធម៌នៅក្នុងប្រព័ន្ធនីតិព្រហ្មទណ្ឌពិតប្រាកដ ដោយមិនគិតអំពីរចនាសម្ព័ន្ធរបស់វា និង មិនគិតថាតើវាស្ថិតក្នុងកំរិតច្បាប់ក្នុងស្រុកឬអន្តរជាតិនោះទេ។ តម្រូវការនៃភាពយុត្តិធម៌ គឺជាលក្ខខណ្ឌចាំបាច់របស់នីតិរដ្ឋ ហើយដោយសារនីតិព្រហ្មទណ្ឌអន្តរជាតិស្វែងរកនូវការពង្រីកវិសាលភាពនៃនីតិរដ្ឋចំពោះអំពើឃោរឃៅ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាក៏ត្រូវតែគោរពដល់តម្រូវការចាំបាច់នៃភាពយុត្តិធម៌ផងដែរ។ ជាងនេះទៅទៀត មិនមានហេតុផលអ្វីដែលត្រូវជឿថា បើច្បាប់ព្រហ្មទណ្ឌនៅកំរិតអន្តរជាតិកាន់តែតឹងរ៉ឹង នឹងមិននាំមកនូវជោគជ័យក្នុងការសម្រេចឱ្យបាននូវយុត្តិធម៌ និង មិនអាចបញ្ចប់នូវនិទណ្ឌភាពនៃអំពើឃោរឃៅនោះទេ។" *ដូចជើងទំព័រខាងលើ* ទំព័រ ៥៤១។

[205] *សូមមើល* សេចក្តីផ្តើមទៅកាន់ អ.វ.ត.ក *ដែលមាននៅគេហទំព័រ* http://www.eccc.gov.kh/english/about_eccc.aspx.។

អាចត្រូវបានគេចាត់ទុកថាជាទម្រង់នៃការប្រព្រឹត្តមួយក្រោមទំនៀមទម្លាប់អន្តរជាតិក៏ដោយ តែការអនុវត្តន៍ការទទួលខុសត្រូវ JCE នៅតែរំលោភបំពានដល់គោលការណ៍នីត្យានុកូលភាពដដែល។ JCE មិនមែនជាទម្រង់នៃការទទួលខុសត្រូវមួយដែលទទួលស្គាល់នៅក្នុងច្បាប់កម្ពុជាក្នុងចន្លោះឆ្នាំ ១៩៧៥-៧៩ ទេ។ ការទទួលខុសត្រូវ JCE មិនអាចប្រមើលមើល និង ទទួលបានគ្រប់គ្រាន់នាសម័យកាលនោះទេ។

៨១. អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ទទួលស្គាល់ការទទួលខុសត្រូវ JCE ទោះបីភស្តុតាងទាំងអស់ដែលបង្ហាញថា វាមិនត្រូវបានបង្កើតឡើងដោយទំនៀមទម្លាប់អន្តរជាតិ ផ្តល់នូវចំណាប់អារម្មណ៍ថា អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ទទួលយកតែភស្តុតាងអ្វីដែលខ្លួនអាចរកបាន ដើម្បីសម្រេចឱ្យបាននូវលទ្ធផលជាក់លាក់ណាមួយ ដើម្បីឱ្យបុគ្គលម្នាក់ៗទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ នៅពេលដែលបុគ្គលទាំងនោះត្រូវបានគេទាញចេញឆ្ងាយពីការប្រព្រឹត្តអំពើបទល្មើសណាមួយ[206]។

៨២. អ.វ.ត.ក មិនត្រូវដើរតាមទាំងងងឹតងងុលនូវការវិភាគខុសរបស់អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* ទេ[207]។ ការធ្វើបែបនេះជាការរំលោភបំពានទៅដល់គោលការណ៍នីត្យានុកូលភាព និង ពិរុទ្ធភាព ក្នុងគោលបំណងឆ្ពោះទៅពិរុទ្ធភាពជាក្រុម[208]។ គោលការណ៍នីត្យានុកូលភាព និង

---

[206] "គេមិនអាចលុបបំបាត់នូវគំនិតដែលថា តុលាការកំពុងពឹងផ្អែកទៅលើរបៀបនៃការទទួលខុសត្រូវដែលបន្ថែមទោស ដើម្បីធានាពីការដាក់ទោសដល់បុគ្គលណាម្នាក់ដែលត្រូវគេចោទប្រកាន់ ហេតុនេះនៅក្នុងទស្សនៈរបស់តុលាការទាំងនោះ ការបំពេញភារកិច្ចដោយស្វ័យប្រវត្តិ ក្នុងទិសដៅទូលំទូលាយ ដោយសំអាងថាជាតុលាការអន្តរជាតិ។ មិនចាំបាច់និយាយអ្វីទេ វាជាការមិនអាចទទួលយកបានចំពោះតុលាការបែបនេះ ក្នុងការយកទៅប្រើជាមធ្យោបាយដល់ទីបញ្ចប់ ក្នុងការសម្រេចឱ្យបាននូវគោលដៅបែបទាសីនេះ ដោយមិនគិតដល់គោលបំណងដើមក្នុងការឱ្យជនណាម្នាក់ទទួលខុសត្រូវ <u>ស្របទៅតាមគោលការណ៍នៃការទទួលខុសត្រូវបទឧក្រិដ្ឋដែលបានបង្កើតឡើងរួចហើយ</u> និង ការជំនុំជម្រះប្រកបដោយយុត្តិធម៌។" Darcy ទំព័រ ៤០៣ (បន្ថែមការសង្កត់ពាក្យ)។

[207] *សូមមើល* Ohlin *បញ្ហាបីនៅក្នុងទស្សនទាន (Three Conceptual Problems)* ទំព័រ ៦៩ សម្រាប់ជាទឡ្ហីករណ៍ដែលថា JCE ត្រូវបានបង្កើតឡើងដោយ អង្គជំនុំជម្រះតុលាការកំពូលលើរឿងក្តី *Tadić* មិនគួរបង្កើតជាយុត្តិសាស្ត្រដោយសារមានបញ្ហាចំនួនបី នៅពេលតុលាការព្រហ្មទណ្ឌអន្តរជាតិបកស្រាយលក្ខន្តិកៈរបស់ខ្លួន និង ផ្តល់នូវការវិភាគរបស់ខ្លួនចំពោះ JCE ។

[208] "វិធីដែលទ្រឹស្តីនេះត្រូវបានយកមកប្រើ ធ្វើឱ្យមានការលំបាកក្នុងការចៀសវាងនូវចំណាប់អារម្មណ៍ដែលថា មានសមីការរវាងការប្រព្រឹត្តបទល្មើសជារួម ឬបទល្មើសជាក្រុមជាមួយនឹងការទទួលខុសត្រូវបទល្មើសរួម។ វាមានការលំបាកក្នុងការមិនយល់ថាការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម ដែលលាយឡំនូវទម្រង់មួយនៃពិរុទ្ធភាពជាក្រុម។" Darcy ទំព័រ ៣៨៦។ "ទ្រឹស្តីនេះស្រដៀងគ្នានឹងច្បាប់ស្តីពីការសមគំនិត និង សមាជិកភាព ឬ ការទទួលខុសត្រូវរបស់អង្គការដែលបានយកមកអនុវត្តនៅ

សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ គឺជាធាតុដ៏សំខាន់របស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[209] ដែលហាមឃាត់មិនឱ្យធ្វើការពន្លាតនូវទ្រឹស្តីនៃការទទួលខុសត្រូវបទល្មើស ក្នុងគោលបំណងចៀសវាងនូវការខ្វះខាតភ័ស្តុតាងចំពោះតួនាទីពិសេសមួយដែលបុគ្គលម្នាក់ៗ បានជាប់ពាក់ព័ន្ធក្នុងការរៀបផែនការ ការត្រៀមរៀបចំ និង ការប្រតិបត្តិ នូវយុទ្ធាការទ្រង់ទ្រាយធំ ឬ រាលដាលនៃអំពើល្មើស។

៨៣. ក.ស.ច.ស បានដកស្រង់សាលដីកាលើរឿងក្តី *Tadić* សម្រាប់ជាសំណើថា "បទឧក្រិដ្ឋអន្តរជាតិ

---

Nuremberg។ ភាពស្រដៀងគ្នាគឺមានភាពពិតប្រាកដជាងគេនៅក្នុង JCE III ដោយហេតុថា នៅក្នុងករណីនេះ អ្នកចូលរួមណាម្នាក់ដែលចូលរួមក្នុង JCE ណាមួយ អាចនឹងទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលអ្នកចូលរួមផ្សេងទៀតមិនបានព្រមព្រៀងជាមុនយ៉ាងជាក់លាក់ជាមួយ ប្រសិនបើបទឧក្រិដ្ឋទាំងនោះគ្រាន់តែអាចដឹងបាន។ ហេតុនេះ ការទទួលខុសត្រូវរបស់គាត់គឺមានមូលដ្ឋានជាសំខាន់ទៅលើភាពសមាជិកភាពរបស់គាត់ នៅក្នុងក្រុមនោះស្របទៅតាម JCE។" Kai Ambos, *សហឧក្រិដ្ឋកម្មរួម និង ការទទួលខុសត្រូវក្នុងការបញ្ជា (Joint Criminal Enterprise and Command Responsibility)*, 1 J. INT'L CRIM. JUST. `, 10 (2007)។ "ជាឧទាហរណ៍ ជនជាប់ចោទអាចត្រូវបានគេកំណត់ថាមានទោសជាពិសេស ចំពោះការសម្លាប់ ឬ រាប់ទាំងអំពើប្រល័យពូជសាសន៍ផង ទោះបីគាត់មិនដែលមានចេតនាចាំបាច់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ និង ទោះបីបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្តខាងក្រៅ JCE និងដោយជនដែលគាត់មិនអាចគ្រប់គ្រងបានក៏ដោយ។ ពិរុទ្ធភាពរបស់គាត់គឺមានតវ៉ាផ្អែកលើគោលការណ៍នៃការទទួលខុសត្រូវរួម។ គាត់កំពុងត្រូវបានគេដាក់ទោសចំពោះបទឧក្រិដ្ឋមួយដែលគាត់មិនបានប្រព្រឹត្តដោយខ្លួនឯង និង ទៅតាមអ្វីដែលគាត់មិនដែលមានចេតនាចាំបាច់ក្នុងការប្រព្រឹត្ត គាត់កំពុងត្រូវបានគេដាក់ទោសចំពោះក្រុមរបស់គាត់ដែលមានចារីប្រព្រឹត្តបទឧក្រិដ្ឋនោះ។ នេះជាការវិវត្តន៍មួយដែលគួរឱ្យមានការព្រួយបារម្ភ នៅក្នុងច្បាប់។ ដូចបានកត់សម្គាល់ដោយ Patricia McGowan Wald ដែលជាអតីតចៅក្រមមួយរូបនៅ ITCY ថា '... ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ត្រូវតែមានកំរិតពីខាងក្រៅ ប្រសិនបើសញ្ញាណនៃពិរុទ្ធភាពបទឧក្រិដ្ឋរបស់បុគ្គលម្នាក់ៗត្រូវរក្សាបាន ជាជាងជំនួសដោយសញ្ញាណផ្សេងៗនៃពិរុទ្ធភាពរួម ដែលវាជាចំណុចអាក្រក់ណាស់នៅក្នុងតុលាការនានាដែលបង្កើតឡើងឱ្យចៀសវាង" Damgard ទំព័រ ២៣៨។ "មិនមានអ្វីសោះនៅក្នុងទស្សនៈ ឬ ទ្រឹស្តីនៃការចូលរួមរួមគ្នាដែលធានានូវ ... ការកំរិត។ នោះជាការបញ្ចូលយ៉ាងត្រឹមត្រូវឱ្យចូលរួមពិរុទ្ធភាពដោយក្រុម ដែលចុងចោទត្រូវបានដកចេញជាច្រើនជំហ៊ានពីបណ្តាតួអង្គដែលកំណាចបំផុត ដូចនៅក្នុងបណ្តាញចូរលុងមួយដែលរីករាលដាលពេញបណ្តាប្រទេសជាច្រើន ដូចជា al-Qaeda ជាដើម។ ក្នុងការអនុវត្តន៍ការចូលរួមរួមគ្នាគឺជាសញ្ញាណមួយដែលមានន័យទូលំទូលាយយ៉ាងមានសក្តានុពល ដែលវាតម្រូវឱ្យមានការរាំងខ្លួនឯង ដោយពួករដ្ឋអាជ្ញាដែលអាចការពារខ្លួនបាន។" Mark J. Osiel, *របៀបនៃការចូលរួមក្នុងអំពើសាហាវយង់ឃ្នងធំៗ (Modes of Participation in Mass Atrocity)*, 38 CORNELL INT'L L.J. 793, 799-800 (2005) (បន្ថែមការសង្កត់ពាក្យ)។ *សូមមើលផងដែរ* van der Wilt ទំព័រ ៩៧ ពេលដែលសាស្ត្រាចារ្យ van der Wilt ថ្លែងថា តុលាការនៅ Nuremberg បាត់បង់នូវចក្ខុវិស័យនៃគោលការណ៍ពិរុទ្ធភាពរបស់បុគ្គល និងថា ហេតុនេះហើយបានជាលទ្ធផលនៅ Nuremberg មិនគួរឱ្យមោទនភាពសោះ។

[209] R. CRYER ET AL., **នីតិ និង នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ៣០១** (INTERNATIONAL CRIMINAL LAW AND PROCEDURE 301) (Cambridge University Press 2007)។

... ពាក់ព័ន្ធដោយឡែកតែទៅលើបុគ្គលណាដែលទទួលខុសត្រូវខ្ពស់បំផុត ដែលបានធ្វើប្រតិបត្តិការណ៍ ហួសពីអំពើប្រព្រឹត្តជាក់លាក់នៃអំពើល្មើស។ ច្បាប់ព្រហ្មទណ្ឌអន្តរជាតិបានគូសបញ្ជាក់ពីរឿងនេះ តាមរយៈទម្រង់នានានៃការទទួលខុសត្រូវ ដូចជាការការទទួលខុសត្រូវក្នុងការបញ្ជា ឬ JCE"[210]។ បញ្ហាដែលថា បទល្មើសអន្តរជាតិមានបំណងធ្វើឱ្យមានលក្ខណៈរួមគ្នា និង បញ្ចូលជនដែលមិនមានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ មិនមែនជាហេតុផលដែលត្រូវអនុវត្តការទទួលខុសត្រូវ JCE នោះទេ ខណៈដែលទម្រង់នៃការទទួលខុសត្រូវផ្សេងៗទៀតដែលមានចែងជាពិសេសក្នុងមាត្រា ២៩ និងជាផ្នែកមួយនៃច្បាប់កម្ពុជា អាចយកមកប្រើប្រាស់បាន[211]។ "ជំនួសឱ្យការចាក់ពុម្ពជាថ្មីនៃទស្សនៈទានរបស់ច្បាប់ដើម្បីសម្របតាមសភាពជាក់ស្តែង គេត្រូវតែយល់ឱ្យបានប្រសើរថា ទ្រឹស្តី JCE មិនសុទ្ធតែជាលិខិតូបករណ៍មួយដែលសមស្របក្នុងការតតាំងនឹងរចនាសម្ព័ន្ធការិយាធិបតេយ្យ និង អង្គការធំៗដែលមានពាក់ព័ន្ធនឹងអំពើល្មើសអន្តរជាតិនោះទេ"[212]។ ក្រមព្រហ្មទណ្ឌថ្មីរបស់កម្ពុជាឆ្លុះបញ្ចាំងនូវឆន្ទៈនៃសភាជាតិដែលត្រូវបានគេបោះឆ្នោតជ្រើសតាំងទាំងស្រុង ដែលវាបញ្ជាក់ថា ការដាក់បញ្ចូលការប្រព្រឹត្តរួមគ្នានៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ជាជាងដាក់អនុម័តទទួលយកនូវទ្រឹស្តីដែលបង្កើតដោយតុលាការ ដែលផ្អែកតាមច្បាប់ Common Law។

៨៤. ជាសរុបមក អង្គបុរេជំនុំជម្រះគួរចងចាំអំពីតួនាទី និង មុខងាររបស់ អ.វ.ត.ក ជាតុលាការមួយរបស់កម្ពុជាដែលបានបង្កើតឡើងដោយប្រព័ន្ធច្បាប់ក្នុងស្រុក។

> សេចក្តីសម្រេចដែលទុកឱកាសឱ្យមានវិមតិសង្ស័យ អំពីពិរុទ្ធភាពរបស់ជនណាម្នាក់ នឹងនាំឱ្យអន្តរាយដល់សុពលភាពនៃអត្ថន័យរបស់សេចក្តីសម្រេចនោះ និង

---

[210] ដីកាសម្រេច JCE កថាខណ្ឌ២២។

[211] ជាងនេះទៅទៀត អំណះអំណាងដែលដាក់បញ្ចូលដោយ ក.ស.ច.ស ដើម្បីឱ្យការទទួលខុសត្រូវ JCE កាន់តែមានប្រសិទ្ធភាពក្នុងច្បាប់អន្តរជាតិ បានវិវត្តទៅជាមធ្យោបាយមួយក្នុងការសំរែង ពីទំទួលខុសត្រូវខ្ពស់របស់ជនដែលទទួលខុសត្រូវខ្ពស់ចំពោះបទឧក្រិដ្ឋនានាដែលមានប្រព្រឹត្ត[211] គឺមិនត្រឹមត្រូវទេ។ នៅក្នុងសាលដីកាលើរឿងក្តី *Tadić* ការទទួលខុសត្រូវ JCE ត្រូវបានប្រមើលមើលថាអាចអនុវត្តដើម្បីដាក់ជាក្រុមនូវបទឧក្រិដ្ឋនៅកំរិតប្រតិបត្តិការណ៍ប៉ុណ្ណោះ[211] ដោយពាក់ព័ន្ធទៅនឹងសមាជិកប្រតិបត្តិដែលជិតស្និទ្ធគ្នាបំផុត។ *សូមមើល* Elies van Sliedregt *ឧក្រិដ្ឋភាពជាប្រព័ន្ធនៅ ICTY (System Criminality at the ICTY)* ក្នុង A. NOLLKAEMPER & H. G. VAN DER WILT, **ឧក្រិដ្ឋភាពជាប្រព័ន្ធនៅក្នុងច្បាប់អន្តរជាតិ ១៩៨** (SYSTEM CRIMINALITY IN INTERNATIONAL LAW 196) (Cambridge University Press, 2009)។

[212] van der Wilt ទំព័រ ៩៣។

អាចជួយបំរើដល់ការបន្ថែមសាំងទៅលើភ្លើង ចំពោះអ្នកដែលបានប្រយោជន៍នៃចំណែករបស់ខ្លួនក្នុងប្រវត្តិសាស្ត្រ។ តាមរយៈការពណ៌នាពិស្តារអំពីមូលហេតុ និង ការដឹកនាំជម្លោះនាពេលថ្មីៗនេះ សេចក្តីសម្រេចបែបនេះ អាចនឹងបន្ទុចបង្អាក់នូវសមិទ្ធិកម្មនៃគោលបំណងរក្សាសន្តិភាព និង ផ្សះផ្សារជាតិ។ ចេតនានៅក្នុងបរិបទបែបនេះ ដើម្បីក្លាយជាឧបករណ៍សម្រាប់ចែករំលែកនូវយុត្តិធម៌ និង ការព្យាបាលស្នាមរបួសដែលបន្សល់ទុកដោយសារសង្គ្រាម តែផ្ទុយទៅវិញ ច្បាប់ និង យន្តការតាមផ្លូវច្បាប់ ជាការបញ្ចេះស្ថានការណ៍ឲ្យកាន់តែមានភាពតានតឹងទៅវិញ។ គោលការណ៍នៃការទទួលខុសត្រូវបទល្មើសដែលបានអនុវត្តនៅបណ្តាតុលាការអន្តរជាតិនានា[213] គួរតែបានក្លាយជាមូលដ្ឋានមួយដ៏រឹងមាំនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក ដើម្បីបង្កើននូវភវនីយភាពដែលសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះទាំងនោះ អាចទទួលយកបានដោយប្រជាជនក្នុងប្រទេស។ ភាពខ្វះនិរន្តភាពរវាងច្បាប់ព្រហ្មទណ្ឌក្នុងស្រុក និង អន្តរជាតិ អាច 'ជះឥទ្ធិពលយ៉ាងគំហុកទៅលើការគាំទ្រពីសាធារណជន ចំពោះប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ'[214]។

**អាស្រ័យហេតុនេះ** ដោយយោងទៅតាមហេតុផលដូចបានរៀបរាប់ជូនខាងលើ សហមេធាវីការពារសូមលើកសំណើទៅអង្គបុរេជំនុំជម្រះធ្វើការ៖

ក. **ប្រកាស** ថាបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបានតាមវិធាន៧៤(៣)(ក) វិធាន៥៥(១០) និង វិធាន៧៤(៣)(ខ) ឬ វិធាន២១

ខ. **ផ្តល់** សវនាការផ្ទាល់មាត់ចំពោះបញ្ហានេះ និង

គ. **ច្រានចោល** សេចក្តីសម្រេចដែលប្រកាសថា ការទទួលខុសត្រូវ JCE អាចអនុវត្តបានចំពោះបទឧក្រិដ្ឋអន្តរជាតិ ដែល អ.វ.ត.ក មានយុត្តាធិការទៅលើ។

[213] ជាការពិត អ.វ.ត.ក គឺជាតុលាការក្នុងស្រុក ស្ថិតក្នុងប្រព័ន្ធច្បាប់ក្នុងប្រទេសរបស់កម្ពុជា មានកាតព្វកិច្ចខ្លាំងក្លាក្នុងការធានាថាច្បាប់ដែលតុលាការនេះយកមកអនុវត្ត មានមូលដ្ឋានរឹងមាំនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុក។

[214] Darcy ទំព័រ ៤០០-០១។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកបណ្ដឹងនេះដោយក្ដីគោរព។

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២២ ខែមករា ឆ្នាំ ២០១០